# ជីវប្រវត្តិសង្ខេប
# របស់មេដឹកនាំអ៊ិស្លាមទាំងបួន
# បន្ទាប់ពីណាពីមូហាំម៉ាត់

# مختصر سيرة الخلفاء الراشدون

## អារម្ភកថា

នេះជាសមិទ្ធិផលថ្មីមួយទៀតដែលបង្ហាញពីប្រវត្តិរបស់ថ្នាក់ដឹកនាំ( ឥស្សរៈជនបន្តវេណ) នៃមិត្តសំលាញ់មូហាំម៉ាត់ទាំងបួន ដែលពួកគេបានបន្តរក្សាផ្សព្វផ្សាយនិងដឹកនាំសាសនាអ៊ីស្លាមបន្ទាប់ពីមគ្គុទ្ទេសដ៏ប្រពៃដែលត្រូវបានអល់ឡោះជ្រើសតាំងសំរាប់ដឹកនាំបរិស័ទដែលព្រមទទួលយកសាសនាដ៏ល្អនេះមកធ្វើកិច្ចប្រតិបត្តិនោះ ។មិត្តសំលាញ់របស់រ៉ស៊ូលុលឡោះគឺតំណាងអោយរ៉ស៊ូលុលឡោះនូវរាល់កិច្ចការសាសនាអ៊ីស្លាមទាំងអម្បាលម៉ាន បន្ទាប់ពីមរណភាពរបស់រ៉ស៊ូលុលឡោះ ។ ពួកគេជាគំរូសំរាប់ការអនុវត្តតាមក្រឹត្យក្រមច្បាប់សាសនាអ៊ីស្លាម ។កិច្ចប្រតិបត្តិរបស់ ពួកគេជាច្បាប់សំរាប់បរិស័ទអ៊ីស្លាមជំនាន់បន្ទាប់តរៀងមកដូចនេះវាជាការចាំបាច់របស់បរិស័ទអ៊ីស្លាមគ្រប់ៗរូបត្រូវតែអនុវត្តតាមការដឹកនាំរបស់បណ្តាមិត្តសំលាញ់របស់រ៉ស៊ូលុលឡោះជាពិសេសថ្នាក់ដឹកនាំទាំងបួនគឺលោកអាហ្ពូហ្ពើកើរ លោកអ៊ូម៉ើរ លោកឧស្មាន និងលោកអាលី

### តួនាទីរបស់មិត្តសំលាញ់រ៉ស៊ូលុលឡោះទាំងបួន

អ្នកទាំងបួនរូបនេះ គឺជាសរសរទ្រទ្រង់សាសនាអ៊ីស្លាមយ៉ាងសំខាន់បំផុតតាំងពីពេលដែលរ៉ស៊ូលុលឡោះចាប់ផ្តើមអំពាវនាវមនុស្សមកកាន់សាសនាដ៏ល្អឥតខ្ចោះនេះ រហូតជីវិតពួកគេដល់សង្ខារពួកគេត្រូវបានអល់ឡោះកោតសរសើរ និងយល់ព្រមចំពោះទង្វើរបស់ពួកគេដូចអ្វីដែលអល់ឡោះ និងរ៉ស៊ូលរបស់ទ្រង់មានបន្ទូល និងប្រសាសន៍ក្នុងគម្ពីរអាល់គួរអាន និងហាហ្ទីសថា:



**قال تعالى : ( والسابِقُونَ الْأولُونَ من الْمهاجِرِين والْأنصار والذين اتبعوهم بِإِحسان رضي الله عنهم ورضوا عنه وأعد لَهم جنات تجرِي تحتها الْأنهار خالدين فيها أبدا ۚ ذَٰلك الْفَوز الْعظيم )سورة التوبة:100**

មានន័យថា: ពពួកមូហ៊ើជីរីន និងពពួកអាន់សរមុនៗហើយ និងពួកអ្នកដែលតាមពួកទាំងពីរក្រុមនេះ ហើយដែលពួកគេបានសាងនូវកុសលផលបុណ្យទៀតនោះ គឺអល់ឡោះបានយល់ព្រមដល់ពួកគេ (ត្រៀមទុកអោយពួកគេនូវឋានសួគ៌) ហើយពួកនោះក៏ពេញចិត្តចំពោះអល់ឡោះវិញដែរ ( ពេញចិត្តនូវអ្វីដែលអល់ឡោះត្រៀមទុកសំរាប់ពួកគេ) ។អល់ឡោះបានត្រៀមសំរាប់ពួកគេនូវឋានសួគ៌ដែលមានទន្លេជាច្រើនហូរកាត់ខាងក្រោមដែលពួកគេត្រូវរស់នៅទីនោះជាអមតៈនេះហើយ ជាជោគជ័យមួយយ៉ាងធំសំបើមនោះ ។

**قال صلى الله عليه وسلم : ( ما من نبِي إِلا ولَه وزِيران من أَهلِ السماءِ و وزِيران من أَهلِ الْأَرضِ فَأَما وزِيراي من أَهلِ السماءِ فَجِبرِيلُ وميكَائيلُ وأَما وزِيراي من أَهلِ الْأَرضِ فَأَبو بكْرٍ وعمر) الترمذي .**

មានន័យថា: ណាហ្ពីគ្រប់ៗរូបតែងតែមានមន្ត្រីពីររូបនៅលើមេឃ និងមន្ត្រីពីររូបនៅលើផែនដី ចំណែកឯមន្ត្រីពីររូបនៅលើមេឃរបស់ខ្ញុំគឺជីបរ៉អ៊ីល និងមីកើអ៊ីល និងមន្ត្រីនៅលើផែនដីពីររូបរបស់ខ្ញុំគឺលោកអាហ្ពូហ្ពើកើរ និងលោកអ៊ូម៉ើរ ។

**قال صلى الله عليه وسلم : ( اَللهم أَعز اَلْإِسلَام بِأَحب هذَينِ الرجلَينِ إِلَيك بِأَبِي جهلٍ أَو بِعمر بنِ الْخطاب) قَالَ وكَانَ أَحبهما إِلَيه عمر**

មានន័យថា៖ "រ៉សូលុលឡោះបានបួងសួងសុំពីអល់ឡោះ ដើម្បីអោយអុីស្លាមបានរឹងមាំថា៖( ឱអល់ឡោះជាម្ចាស់! សូមទ្រង់អោយសាសនាអុីស្លាមរឹងមាំតាមរយៈបុរសដែលជាទីស្រលាញ់របស់ទ្រង់ម្នាក់ក្នុង ចំណោមអ្នកទាំងពីរនេះផងគឺលោកអាប៊ូជើហ៊ុល ឬលោកអ៊ូម៉ើរ ហ៊្កិនខត្តប) ។អាប់ឌុលឡោះកូនអ៊ូម៉ើរបាននិយាយថា៖ អល់ឡោះបានទទួលយកលោកអ៊ូម៉ើរក្នុងចំណោមអ្នកទាំងពីរនោះ ។

**فَقَالَ النبِي صلى الله عليه وسلم:(إِن اللهَ بعثَنِي إِلَيكُم فَقُلْتم كَذَبت ، وقَالَ أبو بكْر صدق وواساِني بِنفْسِه وماله ، فَهلْ أنتم تاركُوالي صاحِبِي )رواه البخاري**

មានន័យថា៖ណាពី្បមានប្រសាសន៍ថា៖ អល់ឡោះបានជ្រើសតាំងរូបខ្ញុំអោយដឹកនាំពួកអ្នក តែពួកអ្នកបែរជាបំផ្លើសថាខ្ញុំនិយាយកុហកតែក្នុងពេលនោះលោកអាប៊ូប៉ាកើរបាននិយាយថា៖អ្វីដែលរូបខ្ញុំនិយាយនោះគឺជាព្រឹត្តិការណ៍ពិតហើយលោកអាប៊ូប៉ាកើរបានលះបង់ខ្លួន ប្រាណនិងលុយកាក់ដើម្បីរូបខ្ញុំ តើពួកអ្នកទាំងអស់គ្នាចង់បំបែករូបខ្ញុំអោយចេញពីមិត្តសំលាញ់របស់ខ្ញុំឬ?

**قال أنس بن مالك رضي الله عنه : صعد النبِي صلى الله عليه وسلم أُحدا،ومعه أبو بكْر وعمر وعثْمانَ فَرجف، فَقَالَ:( اُسكُن أُحداً - أَظُنه : ضربه بِرِجله فَلَيس علَيك إِلا نبِي، وصديق ، وشهيدان ) البخاري .**

មានន័យថា៖លោកអាណាសកូនម៉ាលិកបាននិយាយថា៖ណាពី្ប អាប៊ូប៉ាកើរ អ៊ូម៉ើរ និងឧស្មានបានឡើងលើភ្នំអ៊ូហ៊ុដ ភ្នំអ៊ូហ៊ុដក៏ឡើងញ័រខ្លួនរបស់វា។



ពេលនោះ( លោកអាណាសគិតថា៖ប្រហែលជាពេលនោះណាពី្បបានយកជើងរបស់លោកធាក់ភ្នំអ៊ូហ៊ុដ ) ណាពី្បបានមានប្រសាសន៍ទៅកាន់ភ្នំអ៊ូហ៊ុដថា៖នៅលើខ្នងរបស់ឯងមានតែណាពី្បមួយរូបនិងអ្នកសច្ចៈម្នាក់( គឺ អាប៊ូប៉ាកើរ) និងអ្នកដែលត្រូវគេសំលាប់ជាសែតពីរនាក់ប៉ុណ្ណោះ (គឺសំដៅទៅ លើអ៊ូម៉ើរ និងឧស្មាន) ។

**أن رسولَ اللِه صلى الله عليه وسلم قَال: « لكُل نبِي رفيق في الْجنة، ورفيقي فيها عثْمانُ بن عفان » الترمذي .**

មានន័យថា៖«រ៉សូលុលឡោះមានប្រសាសន៍ថា៖ ណាពី្បគ្រប់រូបតែងតែមានអ្នកហែរហមនៅក្នុងឋានសួគ៌ ចំណែកឯអ្នកហែរហមខ្ញុំនៅក្នុង ឋានសួគ៌ គឺ ឧស្មាន ហ៊្កិនអាហ្វាន» ។

**قال رسولُ الله صلى الله عليه وسلم : « غَفَر اللهُ لَك يا عثْمانُ ما أَسررت وما أَعلَنت ،وما أَخفَيت وما هو كَائن إِلَى أَنْ تقُوم الساعةُ وما يبالي عثْمانُ ما عملَ بعد هذَا » الدارقطني .**

មានន័យថា៖"រ៉សូលុលឡោះមានប្រសាសន៍ថា៖ឧស្មាន!អល់ឡោះបានសណ្តោសប្រណីដល់រូបអ្នកហើយ គឺទាំងអ្វីដែលអ្នកមិនចង់អោយគេដឹង ឬអ្វីដែលអ្នកលាតត្រដាង និងរាល់ប្រការទាំងឡាយណាដែលអ្នកលាក់កំបាំង និងរាល់ប្រការទាំងអស់រហូតដល់ថ្ងៃបរលោក ហើយឧស្មាននឹងគ្មានផលប៉ះពាល់អ្វីដល់រូបគាត់ឡើយក្រោយពីពេលនេះ ទៅ។

ឧស្មានក៏ត្រូវបានគេប្រសិទ្ធិនាមថាជាអ្នកដែលមានពន្លឺរស្មីពីរពោលគឺដោយសារលោកត្រូវបាន រ៉ស៊ូលុលឡោះរៀបការកូនស្រីពីររូបរបស់ណាហ្គីអោយទៅឧស្មានពោលគឺរ៉ូក័យយ៉ះហើយក្រោយពីរ៉ូក័យយ៉ះស្លាប់រ៉ស៊ូលុលឡោះក៏បានរៀបការអ៊ុមមូកាល់សូមអោយទៀតនេះក៏ដោយសារតែ ឧស្មានជាមិត្តសំលាញ់ដែលល្អរបស់លោក ។

**قال النبي صلى الله عليه وسلم : ( من أحب عليا فَقَد أحبنِي ومن أحبنِي فَقَد أحب اللهَ ومن أبغض عليا فَقَد أبغضنِي ومن أبغضنِي فَقَد أبغض اللهَ )**

មានន័យថាៈ បុគ្គលណាហើយស្រលាញ់លោកអាលី មានន័យថាគេស្រលាញ់ខ្ញុំហើយបើគេស្រលាញ់ខ្ញុំមានន័យថាគេស្រលាញ់អល់ឡោះផ្ទុយទៅវិញបុគ្គលណាហើយស្អប់អាលីមានន័យថាគេស្អប់ខ្ញុំ ហើយបើជនណាស្អប់ខ្ញុំមានន័យថាគេស្អប់អល់ឡោះ ។

**قال رسول الله صلى الله عليه وسلم لعلي : ( أنت مني بِمنزِلَة هارونَ من موسى إِلا أنه لاَ نبِي بعدي) رواه مسلم .**

មានន័យថាៈរ៉ស៊ូលុលឡោះបាននិយាយទៅកាន់អាលីថាៈ (រូបឯងបើគិតមកខ្ញុំនេះប្រៀបបាននឹងណាហ្គីហ៊ើរូនជាមួយណាហ្គីមូសើ (ហ៊ើរូន និងមូសើជាណាហ្គីទាំងពីរនាក់) ប៉ុន្តែដោយសារវាគ្មានណាហ្គីទៀតទេ បន្ទាប់ពីខ្ញុំទៅ ។

**ភារកិច្ចរបស់សាសនិកអ៊ីស្លាមចំពោះមិត្តសំលាញ់រ៉ស៊ូលុលឡោះ**

សំរាប់អ្នកមានជំនឿនឹងអល់ឡោះមានជំនឿនឹងរ៉ស៊ូលរបស់ទ្រង់គឺត្រូវតែដើរតាមលំអានរបស់មិត្តសំលាញ់រ៉ស៊ូលុលឡោះ ផ្ទុយទៅវិញបើបុគ្គលណា



ហើយបដិសេធសមាសភាពមិត្តសំលាញ់ រ៉ស៊ូលុលឡោះ ដោយចេតនាបុគ្គលនោះនឹងត្រូវឃ្លាតចេញពីសាសនាអ៊ីស្លាមដ៏បរិសុទ្ធព្រោះមិត្តសំលាញ់រ៉ស៊ូលុលឡោះជាតំណាងរបស់លោកក្នុងកិច្ចការអនុវត្តចំពោះអល់ឡោះជាម្ចាស់ ។ សូមពិនិត្យមើលប្រសាសន៍របស់ណាហ្គីដែល ជាបណ្តាំដល់ប្រជាពលរដ្ឋរបស់លោកថាៈ

**قال صلى الله عليه وسلم : (اقْتدوا بِالذَين من بعدي أَبِي بكْر وعمر ) رواه الترمذي**

មានន័យថាៈ (ចូរពួកអ្នកធ្វើតាមអ្នកទាំងពីរបន្ទាប់ពីខ្ញុំទៅ គឺអាហ្ពូហ្គើកើរ និង អ៊ូម៉ើរ) ។

**(علَيكُم بِسنتي وسنةَ الْخلفَاءِ الراشدين الْمهديين عضوا علَيها بِالنواجِذ )**

មានន័យថាៈចាំបាច់លើពួកអ្នកទាំងអស់គ្នាប្រកាន់តាមមាគ៌ារបស់ខ្ញុំនិងមាគ៌ារបស់ថ្នាក់ដឹកនាំរបស់ខ្ញុំដែលទទួលបានការចង្អុលបង្ហាញហើយចូរពួកអ្នកត្រូវខាំវានឹងធ្មេញថ្គាម(ខាំមាគ៌ានោះ) ។

**عن محمد بنِ جبيرِ بنِ مطعمٍ عن أَبِيه : أن امرأَةً سأَلت رسولَ اللهِ صلى اللهُ عليه وسلم شيئًا ، فَأَمرها أَنْ ترجِع إِلَيه ، فَقَالَت : يارسولَ اللهِ أَرأَيت إِنْ جِئْت فَلَم أَجِدك؟ قَالَ أَبِي كَأَنها تعنِي الْموت- قَالَ : ( فَإِنْ لَم تجِدنِي فَأْتي أَبا بكْر) رواه مسلم**

មានន័យថាៈ ពីមូហាំម៉ាត់ ហ្ពិនជូពៃរ ហ្ពិនមុតអិម ពីឪពុករបស់លោកបានបញ្ជាក់ថាៈមានស្ត្រីម្នាក់បានសួររ៉ស៊ូលុលឡោះពីអ្វីមួយ ។ រ៉ស៊ូលុលឡោះបានប្រើអោយនាងមកជួបលោកម្តងទៀតនៅពេលក្រោយ ពេលនោះស្ត្រីម្នាក់នេះ

បាននិយាយទៅកាន់រ៉ស៊ូលុលឡោះថាៈឱរ៉ស៊ូលុលឡោះ!តើលោកយល់ឃើញយ៉ាងណាដែរបើខ្ញុំវិលមកវិញហើយមិនបានជួបនឹងលោកនោះ? ត្រង់ចំនុចនេះឪពុករបស់ខ្ញុំបាននិយាយថាៈស្ត្រីនោះចង់សំដៅទៅដល់ការស្លាប់ ។ ពេលនោះរ៉ស៊ូលុលឡោះបាននិយាយថាៈ( បើមិនបានជួបខ្ញុំទេ ចូរទៅជួបអាប៊ូហ្ពើកើរចុះ) ។

**قال الإمام أبو حنيفة: إِذاَ جاَءَ الْحديثُ عن رسولِ اللهِ صلى الله عليه وسلم فَعلى الرأسِ والْعينِ وإِذَا جاَءَ عنِ الصحابة رضي اللهُ عنهم فَعلى الرأسِ والْعينِ و إِذَا جاَءَ عنِ التابِعين فَنحن رِجالٌ وهم رِجالٌ .**

មានន័យថាៈអ៊ីម៉ាំហាណាហ្វីបាននិយាយថាៈ ពេលណាហាហ៊ីសរ៉ស៊ូលុលឡោះបានមកដល់ពួកអ្នកត្រូវតែទទួលយកទាំងដៃដប់និងពេលណាហើយដែលរឿងពិតមកពីមិត្តសំលាញ់( សាហាហ្ពាត)រ៉ស៊ូលុលឡោះ ពួកអ្នកត្រូវតែទទួលយកទាំងដៃដប់ និងបើពេលណាព័តិមាននោះបានមកពីអ្នកដែលទាន់សំលាញ់របស់រ៉ស៊ូលុលឡោះ គឺពួកយើងជាមនុស្សប្រុសដូចពួកគេដែរ ។

**បាបកម្មធំចំពោះអ្នកជេរប្រមាថនិងមាក់ងាយដល់មិត្តសំលាញ់ទាំងអស់របស់រ៉ស៊ូលុលឡោះ :**

ចំពោះបុគ្គលណាហើយជេរប្រមាថដល់មិត្តសំលាញ់របស់រ៉ស៊ូលុលឡោះគឺបុគ្គលនោះត្រូវបានច្បាប់សាសនាអ៊ីស្លាមចាត់ទុកជាជនបរាជ័យពីសាសនាអ៊ីស្លាមហើយពីព្រោះថាការប្រមាថមើលងាយដល់មិត្តសំលាញ់រ៉ស៊ូលុលឡោះប្រៀបបាននឹងការមើលងាយដល់រ៉ស៊ូលុលឡោះបើគេមាក់ងាយរ៉ស៊ូលុលឡោះមានន័យថាៈ គេមាក់ងាយដល់ម្ចាស់តែមួយគត់គឺអល់ឡោះម្ចាស់ **លើអ្វីៗទាំងអស់ដូច្នេះតើ**



អ៊ីស្លាមរបស់គេនៅឯណា? រ៉ស៊ូលុលឡោះ មានប្រសាសន៏ថាៈ

**قال صلى الله عليه وسلم : (لاَ تسبوا أَصحاِبي لاَ تسبوا أَصحاِبي فَوالذي نفْسِي بِيده لَو أَن أَحدكُم أَنفَق مثْلَ أُحد ذَهبا ما أَدرك مد أَحدهم ولاَ نصيفَه ) مسلم**

មានន័យថាៈពួកអ្នកទាំងអស់គ្នាកុំជេរមិត្តសំលាញ់របស់ខ្ញុំពួកអ្នកទាំងអស់គ្នាកុំជេរមិត្តសំលាញ់របស់ខ្ញុំ ខ្ញុំសូមស្បថនឹងអល់ឡោះចុះថាៈទោះបីបុគ្គលណាម្នាក់ក្នុងចំណោមពួកអ្នកទាំងអស់គ្នា បរិច្ចាគទានជាមាសដែលមានទំហំប៉ុនភ្នំអ៊ូហ៊ុដក៏ដោយក៏មិនបានស្មើនឹងមួយជ្រុង ឬតិចជាងមួយជ្រុងរបស់ពួកគេដែរ ( មិត្តសំលាញ់របស់ខ្ញុំ) ។

**عبدالله بن عباس قال : قال رسول الله صلى الله عليه وسلم : ( من سب أَصحاِبي لَعنه اللهُ والْملاَئكَةُ والناس أَجمعونَ ) مجمع الزوائد.**

មានន័យថាៈ បុគ្គលណាហើយជេរមិត្តសំលាញ់របស់ខ្ញុំគឺបុគ្គលនោះត្រូវទទួលនូវការប្រទេចបណ្តាសារពីអល់ឡោះជាម្ចាស់ពីពពួកម៉ាឡើអ៊ីកាត់ និងពីមនុស្សទូទៅ ។

قال صلى الله عليه وسلم : ( خَيْرُ النَّاسِ قَرْنِيْ ، **ثُم الذين يلُونهم ، ثُم الذين يلُونهم ....) البخاري**

មានន័យថាៈមនុស្សល្អគឺអ្នកដែលទាន់ជំនាន់ខ្ញុំបន្ទាប់មកគឺអ្នកដែលទាន់មនុស្សជំនាន់ខ្ញុំ និងបន្ទាប់មកទៀត គឺអ្នកដែលទាន់មនុស្សដែលទាន់ជំនាន់របស់ខ្ញុំ ។

**សរុបសេចក្តីមក** គឺអ្នកអ៊ីស្លាមគ្រប់ៗរូបត្រូវតែស្រលាញ់លើកតំកើង និង

រក្សាកិត្តិនាមរបស់មិត្តសំលាញ់រ៉ស៊ូលុលឡោះព្រោះតាមរយៈ ការស្រលាញ់ និងលើកតំកើងពួកគេគឺជាចំណែកមួយនៃការថែរក្សាសាសនាអ៊ីស្លាមដ៏បរិសុទ្ធ។

❁ សារៈសំខាន់នៃសៀវភៅនេះគឺសំដៅទៅលើការនិយាយអំពីដំណើរប្រវត្តិនៃសាសនាអ៊ីស្លាមដែលប្រកបដោយគុណតំលៃដ៏ល្អបំផុត ដើម្បីជាគំរូសំរាប់ការរស់នៅក្នុងសង្គមមួយប្រកបដោយសេចក្ដីសុខសុភមង្គល និងឈរលើគោលការអ៊ីស្លាមដែលអល់ឡោះជាម្ចាស់ចក្រវាឡជ្រើសរើសសំរាប់មនុស្សលោក។ហើយមិនមែនជាសាសនាសំរាប់បុគ្គល ក្រុម ឬជនណាមួយយកធ្វើជាខែល ឬជាឈ្នាន់ប្រើប្រាស់សំរាប់បំរើមហិច្ឆតា តាមទំនើងចិត្ត របស់ខ្លួន ឬក្រុមរបស់ខ្លួនដែលបំពេញទៅដោយចំណង់និងផ្ទុយពីគោលការអ៊ីស្លាមនោះឡើយ។

❁តាមរយៈសៀវភៅនេះដែរយើងអាចដឹងអំពីដំណើរប្រវត្តិនៃឥស្សរៈជនកំពូល៧ ដែលជាមិត្តភ័ក្តិឬសហការី (សហាហ្ព័ត) របស់មូហាំម៉ាត់ដែលជាអ្នកដឹកនាំសាសនា បន្ទាប់ពីណាពីមូហាំម៉ាត់ប្រកបដោយគុណធមិដោយឈរលើមាគ៌ារបស់មូហាំម៉ាត់និងគម្ពីរអាល់គួរអានដោយគ្មានការងាករេ និងនៅលើវិថីមួយដែលមានពន្លឺភ្លឺស្វាងបំផុត។



## អ្នកមានជំនឿដ៏ប្រាកដគឺខលីហ្វះរបស់សារហារីមូហាំម៉ាត់

**ឪពុក:** ថ្ងៃនេះចិត្តរបស់យើងភ្លឺស្វាងតាមរយៈជីវៈប្រវត្តិរបស់ស៊ិតហ្ទីកគឺយើងនឹងពណ៌នាអំពីអាហ្ពូហ្ពាកើរអាស៊ិតហ្ទីក។ មុននឹងពេលពួកយើងចាប់ផ្ដើមពណ៌នាអំពីជីវប្រវត្តិដ៏ប្រពៃរបស់លោកនោះ តើនរណាម្នាក់ក្នុងចំណោមពួកអ្នកទាំងអស់គ្នារំលឹកពួកយើងនូវហាហ្ទីស[១] ណាហ្ពីស្ដីអំពីឃូឡាហ្វារ៉ស៊ីឌីន[២] ?

**សាឡាម:** គឺខ្ញុំ ខ្ញុំបានអានហាហ្ទីស្សនោះ ដែលវាមានន័យថា: ចូរអ្នកទាំងអស់គ្នាដើរតាមមាគ៌ារបស់ខ្ញុំនិងមាគ៌ាខលីហ្វះ[៣] ដែលជាមេដឹកនាំត្រឹមត្រូវប្រកបដោយគតិបណ្ឌិតការចង្អុលបង្ហាញបន្ទាប់ពីខ្ញុំ( អត់ពីខ្ញុំទៅ) ។ចូរពួកអ្នកខាំវា( មាគ៌ាខលីហ្វះ) ដោយធ្មេញថ្គាមរបស់ពួកអ្នក។

---

*១ - ហាហ្ទីស: រាល់ពាក្យសំដី កាយវិការ និងការឯកភាពរបស់សារហារីមូហាំម៉ាត់។*

*២-ឃូឡាហ្វារ៉ស៊ីឌីន:មិត្តភក្តិជិតស្និទ្ធរបស់សារហារីមូហាំម៉ាត់ ហើយជាអ្នកដឹកនាំអ៊ីស្លាមបន្ទាប់ពីលោក។ពួកគាត់ទាំងនោះមាន:អាហ្ពូហ្ពាកើរ អ៊ូម៉ើរ ឧស្មាន អាលី ហើយសាសនវិទូអ៊ីស្លាមបានឯកភាពគ្នាថា អ្នកទីប្រាំនោះគឺ អ៊ូម៉ើរ កូន អាប់ឌុលអាហ្ស៊ីស ។*

*៣-ខលីហ្វះ:មិត្តភក្តិជិតស្និទ្ធរបស់សារហារីមូហាំម៉ាត់ ហើយជាអ្នកដឹកនាំអ៊ីស្លាមបន្ទាប់ពីលោក។*

# អាហ្គូហ្គាគើរអាស្ស៊ិតហ្វីក

(១១-១៣ ម.ស / ៦៣២-៦៣៤ គ.ស)

**ឪពុក:** ពេលនេះយើងចាប់ផ្តើមសករាជល្អ ហើយរាល់ជីវប្រវត្តិរបស់អ្នកដឹកនាំ និងជាមិត្តសំលាញ់ទាំងអស់របស់រ៉ស៊ូលុលឡោះគឺជាពន្លឺរស្មីត្រចះត្រចង់។

**ម៉ាស់មូដ :** នែ៎ សំលាញ់ ! ដំបូងអនុញ្ញាតអោយខ្ញុំបានសួរនូវសំនួរដែលខ្ញុំចង់ដឹងថា តើនរណាជាអាហ្គូហ្គាគើរនោះ ? ហេតុអ្វីបានជាគេហៅគាត់ថាអាហ្គូហ្គាគើរអាស្ស៊ិតហ្វីក ? ពិសេស គឺខ្ញុំធ្លាប់បានអាន ហើយដឹងថាគេដាក់ឈ្មោះអោយគាត់ថា: អាប់ឌុលកាក់ហ្គះ តែខ្ញុំមិនបានដឹងថាឈ្មោះនោះត្រឹមត្រូវ ឬមិនត្រឹមត្រូវនោះទេ ?

**អ៊ីស្លាមះ** មុនដំបូង គាត់ឈ្មោះអាប់ឌុលកាក់ហ្គះ ហើយក្រោយមកណាហ្គីបានដាក់ឈ្មោះគាត់ថាអាប់ឌុលឡោះ ។

**អាំម៉ាដ :** គាត់ឈ្មោះអាប់ឌុលឡោះ កូន អាហ្គូកូហាហ្វះ ហើយគាត់ត្រូវបានគេហៅនូវឈ្មោះជាច្រើន តែឈ្មោះល្បីដែលគេប្រសិទ្ធិនាមអោយនោះគឺអាទីក ព្រោះរ៉ស៊ូលុលឡោះបានប្រាប់អាប់ឌុលឡោះថាគឺជាអ្នកដែលត្រូវបានអល់ឡោះដោះលែងពីឋាននរកមក។

**ហ្វៃទីម៉ាស់:** អ្នកទាំងអស់គ្នា! ខ្ញុំចង់បង្ហាញអ្នកទាំងអស់គ្នាពីហាហ្វីសដែលរាយការណ៍ដោយអ្នកស្រី អាអ៊ីស្ហះ ថា: ណាហ្គីបានមានប្រសាសន៍ថា: អ្នកណាចង់ឃើញអ្នកដែលត្រូវបានអល់ឡោះលើកលែងទោសពីឋាននរកមកចូរអោយគេមើលទៅអាហ្គូហ្គាកើរចុះ។

**ហ៊ូសាម :** ប៉ុន្តែ គេស្គាល់អាហ្គូហ្គាកើរ ជាអាស្ស៊ិតហ្វីក និង អាទីក តាំងពីនៅមុនចូលអ៊ីស្លាម និងក្រោយពេលចូលអ៊ីស្លាមមកម្ល៉េះ។

**អាំម៉ាដះ** ឈ្មោះអាស្ស៊ិតហ្វីកវាល្បីរន្ទឺតាំងពីនៅមុនអ៊ីស្លាមមកម្លេះ ដោយសារតែភាពខ្ពង់ខ្ពស់ និងការស្អាតស្អំរបស់គាត់។

**ហ្វាទីម៉ះ :** មូលហេតុដែលគេហៅគាត់ថា អាស្ស៊ិតហ្វីក បន្ទាប់ពីគាត់ចូលអ៊ីស្លាមខណៈពេលពួកមូសរីគីន[១] ទៅជួបជាមួយអាហ្គូហ្គាកើរ ហើយពួកគេបាននិយាយទៅកាន់អាហ្គូហ្គាកើរថា: ពិតណាស់មិត្តសំលាញ់របស់ឯង (សំដៅលើណាហ្គីមូហាំម៉ាត់) បានអះអាងថា " ពិតណាស់រូបលោកត្រូវបានគេនាំនៅពេលរាត្រី (ពីក្រុងម៉ាក្កះ) ទៅកាន់ហ្គៃទុលមិកហ្វីស[២] រួចឡើងទៅលើមេឃាហើយត្រឡប់មកដល់ដីវិញនាពេលព្រឹក"។អាហ្គូហ្គាកើរបាននិយាយទៅកាន់ពួកនោះថា"បើលោកមានប្រសាសន៍យ៉ាងនេះមែន ខ្ញុំពិតជាជឿ "។ (អ្នកដែលនៅជាមួយអាហ្គូហ្គាកើរ នាពេលនោះមាន អាប់ឌុលឡោះ កូន ឧស្មាន ឧស្មានកូនអាមៀរ អាមៀរកូនអាំរូ អាំរូកូនកាអាប់ កាអាប់កូនសាអាត់ សាអាត់កូនតៃម៏ តៃម៏កូនម៉ើរ៉ោះ ហើយត្រកូលរបស់លោកជួបនឹងត្រកូលរ៉ស៊ូលុលឡោះត្រង់លោកម៉ើរ៉ោះដែលជាជីតាទី៦ របស់អាប់ឌុល

---

*១ - មូសរីគីន :ពួកពហុទេពនិយមនៃអំបូរគូរ៉ៃស៏ ។*

*២- ហ្គៃទុលមិកហ្វីស : វិហារអ៊ីស្លាមដ៏ពិសិដ្ឋនៅបាលីស្ទីន ។*

ឡោះ)។ អាប់ឌុលឡោះមានកំណើតនៅក្រុងម៉ាក្កះ បន្ទាប់ពីកំណើតរបស់រ៉ស៊ូលលុលឡោះបានជាងពីរឆ្នាំ។

## ការចូលអ៊ីស្លាមរបស់អាហ្គូហ្គាកើរ

**អ៊ីស្លាម:**លោកស៊ិតហ្ទិកគឺជាជនចូលសាសនាអ៊ីស្លាមមុនគេក្នុងចំណោមបុរស ខ្ញុំមានព័ត៌មានល្អៗទាក់ទងនឹងមិត្តសំលាញ់របស់ណាហ្គី ហើយជាមេដឹកនាំដំបូងរបស់អ៊ីស្លាម(បន្ទាប់ពីណាហ្គីមូហាំម៉ាត់) គឺអាហ្គូហ្គាកើរអាស្ស៊ិតហ្ទិក ដែលរួមមានពតិមានអ៊ីស្លាមរបស់ឪពុកម្តាយរបស់គាត់និងកូនៗទាំង៦ របស់គាត់ផងដែរ។ អល់ឡោះមានបន្ទូលក្នុងបញ្ហានេះថាៈ (ឱម្ចាស់របស់ខ្ញុំសូមទ្រង់អនុញ្ញាតអោយរូបខ្ញុំសំដែងការអរគុណចំពោះនៀកម៉ាត់របស់ទ្រង់ដែលទ្រង់បានផ្តល់មកលើរូបខ្ញុំ និងមកលើមាតាបិតារបស់ខ្ញុំ)។

**អាប់ឌុរ៉ស់ម៉ាន:** ពិតណាស់ពតិមាននេះត្រូវតែប្រកាសអោយដឹង ហើយពួកយើងត្រៀមទទួលយកទាំងស្រុង ។

**ហ៊ូសាម:** បងប្អូនជាទីស្រលាញ់! ចំណែករូបខ្ញុំវិញ ពេលណាពួកយើងនិយាយដល់មិត្តសំលាញ់របស់រ៉ស៊ូលុលឡោះ ខ្ញុំមានអារម្មណ៍ថាសប្បាយរីករាយជាពន់ពេកហើយខ្ញុំប្រាថ្នាចង់ដឹងពតិមានពីសំលាញ់របស់ រ៉ស៊ូលុលឡោះអោយបានច្រើនថែមទៀត។

**ពួកកូនៗ:** ពួកយើងទាំងអស់គ្នាក៏ដូចហ៊ូសាមដែរ ពោលគឺយើងត្រៀមខ្លួនទទួលយកនូវពតិមានរបស់មិត្តសំលាញ់របស់រ៉ស៊ូលុលឡោះ ហើយពួកយើង



សុំអោយទទួលបាននូវពន្លឺរស្មីពីការចង្អុលបង្ហាញរបស់ពួកគេ ។

**អ៊ីស្លាម:** តើបងប្អូនយល់យ៉ាងណាដែរ បើពួកយើងនាំគ្នារំលឹកពីការរស់នៅរបស់លោកស៊ិតស្ទីកមុនការចូលកាន់សាសនាអ៊ីស្លាម ដើម្បីពួកយើងអាចទាញយកផលប្រយោជន៍ និងពតិមានគ្រប់គ្រាន់សំរាប់ពួកយើងពីពន្លឺរស្មីនៃការរំលឹកមិត្តសំលាញ់របស់រ៉ស៊ូលុលឡោះ។

**អាប់ឌុរ៉ស់ម៉ាន:** លោកស៊ិតហ្ទិកគឺបានបំពេញអាម៉ាណាស់(ការទទួលខុសត្រូវខ្ពស់)ក្នុងសម័យមុនអ៊ីស្លាម ជាពិសេសលោកបង្កើនការយកចិត្តទុកដាក់ក្នុងការទទួលខុសត្រូវសំរាប់ខ្លួនឯង។ លោកគឺជាអ្នកជំនួញដ៏ធំម្នាក់ ហើយលោកមានតួនាទីជាអ្នកទទួលបន្ទុកកិច្ចការ ផាកពិន័យក្នុងសម័យមុនអ៊ីស្លាម និងលោកក៏ជាមេដឹកនាំរបស់ពពួកគូរ៉ៃស៍ម្នាក់ផងដែរ ។

## ចរិយាសម្បត្តិរបស់លោកអាស្ស៊ិតហ្ទិក

**ហ៊ូសាម:** ពិតណាស់អាហ្គូហ្គាកើរអាស្ស៊ិតហ្ទិក នៅក្នុងសម័យអវិជ្ជាគាត់មានសីលធម៌ដ៏ប្រពៃ។ លោកមានលក្ខណៈល្អជាច្រើនពីបណ្តាប្រការដែលល្អជាមនុស្សក្លាហាន មានចិត្តជាកូនប្រុសពិត មានកិត្តិយស និងភាពល្អបរិសុទ្ធ ហើយជាមនុស្សមានទំនាក់ទំនងល្អជាមួយសាច់សាលោហិត និងមានសេចក្តីសណ្តោសប្រណី។ លោកជាមនុស្សម្នាក់ ក្នុងចំណោម១០នាក់ពីអំបូរគូរ៉ៃស៍ដែលមានឋានៈខ្ពង់ខ្ពស់និងជាមេដឹកនាំដែលត្រូវបានគេទទួស្គាល់និងកត់ចំណាំនូវភាពទន់ភ្លន់និងសណ្តោសប្រណី។

**ម៉ាស់ម៉ូដះ**បងប្អូនទាំងអស់! យោងតាមពាក្យសំដីដែលពួកអ្នកបាននិយាយបង្ហាញអោយឃើញថា ជាការពិតណាស់លោកមិនដែលប្រព្រឹត្តនូវប្រការអាក្រក់សោះឡើយ ។

## អាបូហ្គាកើរមិនគោរពរូបបដិមា

**អាប់ឌុរ៉ស់ម៉ាន:**កាលពីនៅកុមារភាព ឪពុករបស់លោកបាននាំលោកទៅទស្សនារូបបដិមាដែលពួកគេកំពុងគោរពសក្ការៈ ។ តាំងពីរកុមារភាពមកហើយអាបូហ្គាកើរយល់ឃើញថារូបបដិមាទាំងនោះគឺជាថ្មគ្មានលទ្ធភាពបង្កផលលំបាកឬផ្តល់ផលប្រយោជន៍អ្វីបានឡើយ ។ ឪពុករបស់លោកក៏បានទុកនៅជាមួយរូបបដិមាទាំងនោះ និងបានណែនាំលោកអោយធ្វើការគោរពចំពោះបដិមានោះ ។ ខណៈនោះលោកបានពោលទៅកាន់រូបបដិមាធំជាងគេថា : ឥឡូវនេះខ្ញុំឃ្លាន សូមអ្នកផ្តល់ចំណីអាហារអោយខ្ញុំទទួលទានផងតើឯងអាចផ្តល់សំលៀកបំពាក់អោយខ្ញុំបានទេ? ពេលនោះរូបបដិមាទាំងនោះមិនអាចឆ្លើយតបបានឡើយ ។ អាបូហ្គាកើរយកដុំថ្មចោលទៅលើរូបទាំងនោះ ។

## សច្ចៈភាពរបស់អាស្សិុតហ្វីក

យើងមិនទាន់បញ្ចប់ការរំលឹកពីបញ្ហាក្រមសីលធម៌ដ៏ខ្ពង់ខ្ពស់របស់អាស្សិុតហ្វីកនៅឡើយទេ ។ យើងនិយាយបន្តពីលក្ខណៈសម្បត្តិនៃសច្ចៈភាពដែលមានភាពល្បីល្បាញក្នុងសម័យមុនអ៊ីស្លាមហើយបន្តនូវរហ័ស្សនាមដែល



គេបានដាក់ថា"អាស្សិុតហ្វីក" ក្រោយពេលលោកចូលកាន់សាសនាអ៊ីស្លាម ។ ហាហ្គីសរាយការណ៍ដោយអ៊ីមុាំហ្គូខរីថា: នៅពេលដែលភ្នំអ៊ូហ៊ុដគ្រហ៊ៀងខ្លួនខណៈនោះអាបូហ្គាកើរ អ៊ូមើរនិងឧស្មានទៅជាមួយណាហ្ពី ។ ពេលនោះណាហ្ពីបានមានប្រសាសន៍ថា:.ចូរឯង(ភ្នំអ៊ូហ៊ុដ)នៅអោយស្ងៀម ពីព្រោះនៅលើខ្នងឯងនេះមានតែណាហ្ពី ស៊ិតហ្វីក និងអ្នកដែលត្រូវស្លាប់ដោយសាហ៊ីតពីរនាក់ប៉ុណ្ណោះ ។

## កូនចៅអាបូហ្គាកើរ

**អាប់ឌុរល៉ស់ម៉ាន:**អាបូហ្គាកើរមានកូនចំនួន៦នាក់ ។ កូនប្រុសមានបីនាក់គឺអាប់ឌុលឡោះ អាប់ឌុរ៉ស់ម៉ាន និងមូហាំម៉ាត់ ហើយកូនស្រីមានចំនួនបីនាក់ដែរ គឺអាសម៉ាក អាអ៊ីស្ហះ និងអុំមូកាល់ស៊ូមដែលចាប់កំណើតក្រោយការទទួលមរណភាពរបស់ឪពុកខ្លួន ។

**ហ្វារ៉ស់:** អញ្ចឹង! ហេតុអ្វីបានជាគេមិនរំលឹកនូវពាក្យហ្គាកើរដែលជាឈ្មោះល្បីល្បាញរបស់លោកស៊ិតហ្វីកនោះ?

**អាប់ឌុរ៉ស់ម៉ាន:**ព្រោះដោយសារលោក អាបូហ្គាកើរអាស្សិុតហ្វីក គ្មានកូនឈ្មោះហ្គាកើរទេ ។ តែផ្ទុយទៅវិញគេប្រសិទ្ធិនាមអោយលោកថា អាបូហ្គាកើរ ដោយភាពថ្មីថ្មោងរបស់លោក ។

**កូន១:** ឱ! ម្ចាស់អើយ អស្ចារ្យណាស់ មែនទេហ្វារ៉ស់ ? មែនហើយអាប់ឌុរ៉ស់ម៉ាន!

**ហ៊ូសាមៈ**គេបានដាក់ងារអោយលោកជាអាហ្ពូហ្ពាកើរ ពីព្រោះលោកមានលក្ខណៈច្រើនដែលគួរអោយកោតសរសើរ លុះពេលលោកចូលកាន់សាសនាអ៊ីស្លាមលោកបានចូលរួមជាមួយរ៉ស៊ូលុលឡោះនៅក្នុងការជួយផ្សព្វផ្សាយ និងការពារសាសនារបស់អល់ឡោះ(សាសនាអ៊ីស្លាម)។

**ហ្វាទីម៉ះ:** នៅពេលអាហ្ពូហ្ពាកើរអាស៊្សិតហ្ពីកចូលសាសនាអ៊ីស្លាម លោកក៏ចាប់ផ្តើមអំពាវនាវដោយសំដៅទៅលើបុរស៧នៅឯក្រុងម៉ាក្កះអោយពួកគេចូលសាសនារបស់អល់ឡោះ។ បណ្តាមិត្តសំលាញ់របស់ណាហ្ពីដ៏ឧត្តុងឧត្តមមួយចំនួនបានចូលអ៊ីស្លាម ក្រោមការអំពាវនាវរបស់លោកដូចជាៈ លោកឧស្មានកូនអាហ្វានលោកអាប់ឌុររ៉ស់ម៉ាន កូន អៅហ្វ លោកសាអាត់ កូនអាហ្ពីវ៉ាកស លោកតល់ហាស់ កូនអ៊ូហ្បៃឌិលឡើហ៏ និងលោក ស៊ូហ្បៃរ៍ កូនអាល់អៅវ៉ាម។

**មូហាំម៉ាត់:** ខ្ញុំធ្លាប់បានអានឯកសារមួយបញ្ជាក់ថា លោកអើរកំបានចូលអ៊ីស្លាមដោយការអំពាវនាវរបស់អាហ្ពូហ្ពាកើរដែរ។

**ហ្សុយ៉ាដ:** តើពុំមែនលោកអើរកំជាម្ចាស់ផ្ទះ ដែលបណ្តាមូស្លីមបានប្រមូលផ្តុំគ្នាដើម្បីគោរពប្រណិប័តន៍ចំពោះអល់ឡោះដោយលាក់លៀមខណៈដែលពួកគេមានការភ័យខ្លាចការធ្វើបាបពីសំណាក់ពួកគូរ៉ៃស៏នោះទេឬ?!

**អ៊ីស្លាម:** ពិតមែនហើយ! ជាការពិត ហេតុការណ៏មួយបានកើតមានចំពោះលោកអាហ្ពូហ្ពាកើរនៅពេលដែលលោកធ្វើការអំពាវនាវអោយមកចូលកាន់សាសនារបស់អល់ឡោះ ខណៈនោះពួកគ្មានជំនឿបាន ប្រើអំពើហិង្សាចាប់



វាយធ្វើបាបលោករហូតដល់សន្លប់ ពួកគេថែមទាំងបានយកជើងជាន់ឈ្លីមកលើលោកទៀត។ ពេលនោះមានអន្តរាគមន៍ពីសំណាក់សាច់ញាតិរបស់លោករួចក៏បានសែងលោកទៅកាន់គេហដ្ឋាន។ លុះពេលលោកដឹងខ្លួន លោកក៏សួរកណាហ្ពីហើយមិនព្រមបរិភោគអាហារទេ ទាល់តែមានដំណឹង ពីសុវត្ថិភាពរបស់ណាហ្ពីសិន។ ម្តាយរបស់លោក បានបញ្ជូនលោកទៅកាន់ហ្វាទីម៉ះកូនស្រីអាល់ខត្តប(លោកស្រីគឺជាបងស្រីរបស់លោកអ៊ូម៉ើរកូនអាល់ខត្តប)។ ពេលនោះលោកស្រីក៏មកដល់ ហើយទាំងអស់គ្នា គឺអាហ្ពូហ្ពាកើរ និងម្តាយរបស់លោកបានរួមដំណើរជាមួយលោកស្រីហ្វាទីម៉ះ។ ពេលដឹងពីសុវត្ថិភាពរបស់ណាហ្ពី លោកក៏សំនូមពរណាហ្ពីជួយបួងសួងសុំអោយម្តាយរបស់លោកបានចូលសាសនាអ៊ីស្លាម។ ពេលនោះណាហ្ពីក៏បួងសួងសុំអោយលោកស្រីក្រោយមកលោកស្រីក៏ចូលអ៊ីស្លាម។

## ការលោះខ្ញុំបំរើគេ អោយមានសេរីភាព

**ស៊្សុម៉ាក:**លោកអាហ្ពូហ្ពាកើរអាស៊្សិតហ្ពីក បានបំពេញនូវកិច្ចការជាទីមោទនៈជាច្រើន ដែលក្នុងនោះអាល់គួរអានបញ្ជាក់ពីទង្វើរបស់លោកដូចជា : ការចំណាយទ្រព្យសម្បត្តិផ្ទាល់ខ្លួន ក្នុងការលោះខ្ញុំបំរើគេអោយមានសេរីភាព។

**ឌុំពុកៈ** ត្រូវហើយ! សូមអល់ឡោះផ្តល់ភាពរីកចំរើនដល់អ្នក។អល់ឡោះបានមានបន្ទូលក្នុងជំពូកអាល់ឡៃល៏វាក្យខ័ណ្ឌ១៧ដល់២១ដែលមានន័យថាៈ"ពួកអ្នកដែលគោរពកោតខ្លាចនឹងត្រូវដាក់ឆ្ងាយពីនរក។ អ្នកដែលបរិច្ចាគទ្រព្យ

សម្បត្តិរបស់គេដើម្បីជំរះសម្អាតខ្លួនរបស់គេហើយជនដែលមិនចង់បានសំណង ពីនរណាម្នាក់វិញ លើកលែងតែចំពោះមុខម្ចាស់ដ៏ខ្ពង់ខ្ពស់របស់គេហើយរូបគេនឹងពេញចិត្ត(សួគ៌ាដែលទ្រង់ប្រទានអោយនោះ)”។ពិតណាស់លោកបានលោះខ្ញុំបំរើគេចំនួន៧នាក់។ ពួកគេទាំងនោះត្រូវបានគេធ្វើទារុណកម្មដោយពួកគាត់បានបំពេញតួនាទីក្នុងបុព្វហេតុអល់ឡោះ។លោកមានប្រាក់ចំនួន ៤០០.០០០ ដារ៉ហាំ(លុយអារ៉ាប់ជាប្រាក់សុទ្ធ)។លោកបានចំណាយថវិកាទាំងនោះលុះដល់ពេលដែលលោកធ្វើការភៀសខ្លួនពីម៉ាក្កះទៅម៉ាឌីណះ គឺលោកនៅសល់ត្រឹមតែ ៥ ០០០ដារ៉ហាំប៉ុណ្ណោះ។

## ការផ្លាស់ទីពីម៉ាក្កះទៅម៉ាឌីណះរបស់ណាប៊្លីមូហាំម៉ាត់

**អះម៉ាត់ :** អល់ឡោះបានមានបន្ទូលនៅក្នុងជំពូកអាត់តាវប៉ះវាក្យខ័ណ្ឌ៤០ ដែលមានន័យថា: “បើពួកអ្នកមិនជួយមូហាំម៉ាត់ក៏ដោយ ក៏អល់ឡោះជួយលោកដែរ”។ នៅពេលដែលពួកគ្មានជំនឿបានបណ្តេញលោក(មូហាំម៉ាត់) ចេញខណៈពេលដែលអ្នកទាំងពីរ (រ៉ស៊ូលុលឡោះនិងអាប៊ូប៊ាកើរ) នៅក្នុងរូងភ្នំ។ ពេលនោះណាប៊្លីបានមានប្រសាសន៍ទៅកាន់មិត្តសំលាញ់របស់លោកថា: “កុំខ្លាច! អល់ឡោះជួយពួកយើង” ។ ពេលណាប៊្លីដើរចេញពីគេហដ្ឋានរបស់លោក លោកក៏បានយកធូលីរោយលើក្បាលរបស់ពួកមូសរីគីន។ អល់ឡោះបានធ្វើឱ្យភ្នែករបស់ពួកនោះស្រវាំង មើលណាប៊្លីមិនឃើញក្នុងពេលដែលលោកដើរកាត់មុខរបស់ពួកគេ។ណាប៊្លីបានដើរទៅជួបអាប៊ូប៊ាកើរ



ហើយលោកបានប្រាប់អាប៊ូប៊ាកើរថា:”អល់ឡោះបានអនុញ្ញាតិអោយលោកធ្វើចំណាកស្រុក(ណាប៊្លីបានអនុញ្ញាតអោយអាប៊ូប៊ាកើរ រួមដំណើរជាមួយលោក)។ពេលបានលឺដូចនេះអាប៊ូប៊ាកើរយំដោយក្តីសប្បាយឥតឧបមាដែលបានធ្វើដំណើរចំណាកស្រុកជាមួយណាប៊្លី។

**ហ្វាទីម៉ះ:** អាប៊ូប៊ាកើរបានជួលអាប់ឌុលឡោះកូនអ៊ូរ៉យគិតធ្វើជាអ្នកបង្ហាញផ្លូវពួកគាត់ទាំងពីរ។

**អាសស្មាក :** ខណៈនោះក្មេងស្រីអាសស្មាកជាអ្នកលបយកអាហារជូនអ្នកទាំងពីរ។

**អ៊ីស្លាម :** និយាយពីអាប៊ូប៊ាកើរវិញ ខណៈពេលដែលអ្នកទាំងពីរ (ណាប៊្លីនិងអាប៊ូប៊ាកើរ)ចូលលាក់ខ្លួនក្នុងរូងភ្នំ(រូងភ្នំសៅរ៍) លោកបានបង្ហាញពីការយកចិត្តទុកដាក់ខ្ពស់ និងការអាណិតស្រលាញ់មកលើណាប៊្លីយ៉ាងជ្រាលជ្រៅពោលគឺលោកបាននិយាយទៅកាន់រ៉ស៊ូលុលឡោះថា:” ឱរ៉ស៊ូលុលឡោះ! សូមចាំបន្តិចទុកអោយខ្ញុំចូល និងពិនិត្យមើលអោយសព្វគ្រប់ទីកន្លែងនៅក្នុងរូងភ្នំនោះជាមុនសិន។ អាប៊ូប៊ាកើរធ្វើដូចនេះព្រោះដោយក្តីបារម្ភក្រែងមានអ្វីធ្វើអោយគ្រោះថ្នាក់ដល់ណាប៊្លីហើយលោកបានយកសំលៀកបំពាក់ទៅបិទតាមរន្ធនិងយកខ្លួនពាំងរន្ធនោះទៀត។

**អាប់ឌុររ៉ស់ម៉ាន :** លោកអាប៊ូប៊ាកើរជាឪពុករបស់អ្នកស្រីអាអ៊ីសះដែលត្រូវជាភរិយារបស់ណាប៊្លីមូហាំម៉ាត់។

**ហ្ស៊ីយ៉ាដ :** លោកអាហ្ពូហ្គាកើរមិនដែលនៅឆ្ងាយពីណាហ្ពីឡើយ នៅរាល់សមរភូមិ ពោលគឺលោកប្រឈមជាមួយសត្រូវជាមួយណាហ្ពី ដូចជានៅសមរភូមិបាឌើរ សមរភូមិអ៊ូហ៊ុដ និងនៅសមរភូមិហ្វូណៃន៍ជាដើម ។

**អះម៉ាត់ :** នៅពេលដែលណាហ្ពីធ្លាក់ខ្លួនឈឺកាន់តែធ្ងន់ លោកបានប្រើអោយអាហ្ពូហ្គាកើរដឹកនាំសឡាហ៍ជាអ៊ីម៉ាំក្រោយមកណាហ្ពីក៏ទទួលមរណភាពទៅ ។

## ការតែងតាំងអាហ្ពូហ្គាកើរជាមេដឹកនាំ

**ម៉ាស់មូដ :** ក្នុងព្រឹត្តិការណ៍ដ៏រន្ធត់ លាយឡំនឹងដំណក់ទឹកភ្នែកពីការសោកស្តាយឥតគណនា ហើយនិងជំនឿដ៏រឹងមាំចំពោះអល់ឡោះជាម្ចាស់តែមួយ អាហ្ពូហ្គាកើរបានក្រោកឈរជំនះនឹងទឹកភ្នែករបស់ខ្លួន រួចពោលថាៈបងប្អូនទាំងអស់គ្នា នេះគឺអ៊ូម៉ើរនិងអ៊ូហៃ្ពឌះ! ក្នុងចំណោមអ្នកទាំងពីរនេះ បើម្នាក់ណាដែលពួកអ្នកត្រូវការយកធ្វើជាមេដឹកនាំ ចូរពួកអ្នកផ្តល់សច្ចាប្រណិធានលើរូបគេចុះ ? ខណៈនោះអ៊ូម៉ើរនិងអ៊ូហៃ្ពឌះបាននិយាយព្រមគ្នាថាៈ"ទេ! ខ្ញុំសូមស្បថចំពោះអល់ឡោះថាៈ គ្មាននរណាម្នាក់ត្រូវបានគេតែងតាំងសំរាប់កិច្ចការនេះក្រៅពីរូបអ្នកឡើយ ព្រោះលោកជាអ្នកចូលអ៊ីស្លាមមុនគេ ហើយរូបលោកគឺជាអ្នកទីពីរក្នុងចំណោមមនុស្សពីរអ្នកដែលនៅក្នុងរូងភ្នំ ។ ដូចនេះសូមលោកលាដៃមក ពួកយើងទាំងអស់គ្នាគាំទ្រនិងសច្ចាប្រណិធានយកលោកធ្វើជាមេដឹកនាំ ។



## ភាពជាអ្នកដឹកនាំរបស់អាហ្ពូហ្គាកើរអាស្ស៊ិតហ្ទីក

**ហ្ស៊ីយ៉ាដៈ** អាហ្ពូហ្គាកើរធ្លាប់បូតទឹកដោះពពែយកទៅចែកចាយឱ្យអ្នកស្រុកភូមិ លុះពេលដែលរូបលោកត្រូវបានគេតែងតាំងជាមេដឹកនាំ ស្ត្រីនៅក្នុងភូមិម្នាក់បានសួរលោកថាៈឥឡូវនេះ លែងបូតទឹកដោះពពែចែកចាយអោយពួកយើងទៀតហើយមែនទេ? ។ពេលលឺដូចនោះអាហ្ពូហ្គាកើរពោលថាៈខ្ញុំនឹងបូតទឹកដោះពពែចែកចាយអោយពួកអ្នកទៀត វាគ្មានអ្វីផ្លាស់ប្តូរដោយសារមុខតំណែងរបស់ខ្ញុំនោះទេ! លោកក៏បានបូតទឹកដោះពពែចែកចាយអោយពួកគេដូចមុនដដែល ។

**អាប់ឌុររ៉ស់ម៉ានៈ** អាហ្ពូហ្គាកើរបានដាក់ខ្លួនបំផុត! ដែលក្នុងនោះគឺការយល់ព្រមចំពោះការសុំអនុញ្ញាតរបស់លោកអ៊ូសាម៉ះកូនហ្សៃត អោយអ៊ូម៉ើរកូនអាល់ខត្តបរស់នៅម៉ាឌីណះជាមួយលោក ។លោកអ៊ូសាម៉ះធ្លាប់ជិះសេះរបស់អាហ្ពូហ្គាកើរក្នុងពេលអាហ្ពូហ្គាកើរដើរថ្មើជើង ។ លក្ខណៈបែបនេះក៏ធ្លាប់កើតមានជាមួយនឹងយ៉ើហ្ស៊ីតកូនអាហ្ពីសហ្វយ៉ានដែរ ខណៈដែលលោកបានចាត់តាំងយ៉ើហ្ស៊ីតទៅកាន់ស្រុកស្ហាម ។

**អ៊ីស្លាម :** អាហ្ពូហ្គាកើរបានដាក់ខ្លួនបំផុត! ពេលមួយលោកអ៊ូសាម៉ះបាននិយាយទៅកាន់អាហ្ពូហ្គាកើរទាំងអៀនខ្មាស់ថាៈ ឱមេដឹកនាំរបស់រ៉ស៊ូលុលឡោះ! សូមលោកឡើងជិះមក ខ្ញុំចុះដើរវិញ? អាហ្ពូហ្គាកើរបានឆ្លើយតបដោយលក្ខណៈទន់ភ្លន់ថាៈ វាគ្មានអ្វីលំបាកដល់រូបខ្ញុំ គ្រាន់តែដើរហុយដីក្នុង

បុព្វហេតុរបស់អល់ឡោះមួយរយៈនោះឡើយ! ។

**ហ្វាទីម៉ះ :** ភាពទន់ភ្លន់របស់លោកកាន់តែខ្ពស់ទៅទៀតនោះ គឺពេលលោកបានបែរមុខទៅកាន់អ៊ូសាម៉ះរួចពោលថាៈ "ប្រសិនបើអ្នកយល់ថារូបអ្នកជួយខ្ញុំដូចជាជួយអ៊ូម៉ើរដែរនោះសូមអ្នកធ្វើចុះ" ។

**ម៉ាស់មូដះ**លោកអ៊ូសាម៉ះបានសុំការអនុញ្ញាតិអោយអ៊ូម៉ើររស់នៅម៉ាឌីណះ ។ ជាងនេះទៅទៀតលោកជាមេដឹកនាំដែលគេគោរពប្រតិបត្តិតាម ។

## ស្តីពីការប្រមូលគម្ពីរអាល់គួរអាន

**ហ៊្សឺយ៉ាដ :** លោកអាហ្គួហ្គាកើរបានប្រើហ្សៃតកូនសាហ៊ិតដែលអាឌិតជាអ្នកកត់ត្រាវ៉ាហ៊ី(អាយ៉ាត់គួរអាន) បន្ទាប់ពីសង្គ្រាមយ៉ាម៉ាម៉ះអោយរៀបចំប្រមូលផ្តុំអាល់គួរអាន ។សាសនវិទូអ៊ីស្លាមមូលមតិគ្នាថាកិច្ចការដែលមិនអាចកាត់ថ្លៃបានរបស់អាហ្គួហ្គាកើរគឺការរៀបចំអោយមានការប្រមូលផ្តុំអាល់គួរអាន ។

## កិច្ចការដ៏ឧត្តុងឧត្តមរបស់អាហ្គួហ្គាកើរ

**អ៊ីស្លាមះ** ត្រឹមត្រូវណាស់! ការរៀបចំអោយមានការប្រមូលផ្តុំ អាល់គួរអានគឺជាទង្វើចំបងមួយរបស់អាហ្គួហ្គាកើរ ដែលប្រកបដោយបរមសុខបំផុតសំរាប់សាសនាអ៊ីស្លាម និងសាសនិកអ៊ីស្លាមទាំងអស់ ។

**ម៉ាស់មូដ :** បងប្រុស! កុំភ្លេចថា ក្នុងចំណោមទង្វើចំបងរបស់អាហ្គួហ្គាកើរផងដែរនោះ គឺការចាត់វិធានការទៅលើជនដែលបានក្បត់សាសនា ។

**អ៊ីស្លាម :** ក្នុងចំណោមកិច្ចការចំបងរបស់លោកផងដែរ គឺលោកបានរំដោះ



អោយមានជោគជ័យនៅទឹកដីអ៊ីរ៉ាក់ និងស្វាម ។ តាមរយៈការរំដោះអោយមានជោគជ័យនេះ វាបានក្លាយជាចក្រភពអ៊ីស្លាមនាសម័យនោះ ។

## អាហ្គួហ្គាកើរដ៏ខ្វែតាមមាគ៌ារបស់រ៉ស៊ូលុលឡោះ

**ហ្វាទីម៉ះ:** រ៉ស៊ូលុលឡោះបានតែងតាំងអ៊ូសាម៉ះជាមេទ័ពប្រចាំស្រុកស្វាម ពេលនោះអ៊ូសាម៉ះនៅវ័យក្មេងនៅឡើយ ។មិត្តសំលាញ់របស់រ៉ស៊ូលុលឡោះជាច្រើនស្ថិតក្រោមបញ្ជារបស់អ៊ូសាម៉ះ ក្នុងនោះមានៈ អាហ្គួហ្គាកើរ អ៊ូម៉ើរកូនខត្តប អាហ្គួអ៊ូហ្វៃឌះកូនអាល់យ៉ារ៉ោះ និងសាអាត់កូនអាហ្គីវ៉ាកស្ស ហើយក៏មានពពួកមូហ៊ើជីរីន(អ្នកបំលាស់ទីពីម៉ាក្កះមកកាន់ម៉ាឌីណះ)និងពពួកអាន់សរី(អ្នកម្ចាស់ស្រុកនៅម៉ាឌីណះ)ផងដែរ ។ នៅពេលជំងឺរ៉ស៊ូលុលឡោះកាន់តែធ្ងន់ធ្ងរ១ឡើង អ៊ូសាម៉ះក៏បានវិលត្រឡប់មកវិញ ។

**ហ៊្វូសាមះ** នៅថ្ងៃច័ន្ទលោកអ៊ូសាម៉ះបានជួបណាហ្វី ក្នុងស្ថានភាពសុខភាពល្អ ខណៈនោះណាហ្វីបានមានប្រសាសន៍ទៅកាន់លោកថាៈ ចូរតស៊ូលើការប្រសិទ្ធិពរជ័យពីអល់ឡោះ ។ ក្រោយមកមិនយូរប៉ុន្មានផង នៅពេលអ៊ូសាម៉ះបានត្រៀមរៀបចំទ័ពចេញទៅហើយនោះ ស្រាប់តែភរិយារបស់លោកបានប្រាប់លោកពីជំងឺណាហ្វីថាវាកាន់តែធ្ងន់ធ្ងរហើយ ពេលនោះអ៊ូសាម៉ះមិនចេញទៅទេ ។ ពេលនោះណាហ្វីក៏ទទួលមរណៈភាពទៅហើយ ។ ក្រោយមកអ៊ូម៉ើរកូនអាល់ខត្តប ក៏បានផ្តល់មតិដល់លោកអាហ្គួហ្គាកើរក្នុង បំណងសុំកុំអោយអាហ្គួហ្គាកើរចាត់តាំងអ៊ូសាម៉ះនាំទ័ពទៅ ។ ពេលនោះអាហ្គួហ្គាកើរ

ខឹង ហើយបានពោលថាៈវ៉ស៊្ហ៊ូលុលឡោះបានតែងតាំងអ៊្ហូសាម៉ះ ហើយរូបខ្ញុំរារាំងគេទៅវិញឬ? ខ្ញុំសូមស្បថនឹងអល់ឡោះថា បញ្ហានេះនឹងមិនអាចកើតមានជាដាច់ខាត( ការប្រឆាំងនឹងបញ្ជារបស់វ៉ស៊្ហ៊ូលុលឡោះ) ។

**ម៉ាស់មូដៈ** នៅចំពោះមុខលោកអាហ្ពូហ្ពាកើរមានចំនុចជាច្រើនដែលត្រូវបានជ្រើសរើសតាមបំណងរបស់លោកនោះគឺតើត្រូវរក្សាទ័ពរបស់អ៊្ហូសាម៉ះដើម្បីទុកការពារតែម៉ាឌីណះ បន្ទាប់ពីពួកក្បត់សាសនាបានបង្កភាពចលាចល? ឬលោកត្រូវបញ្ជូនទ័ពអ៊្ហូសាម៉ះដើម្បីទៅចាត់វិធានការលើពួកក្បត់សាសនា? ឬលោកត្រូវចាត់បញ្ជូនទ័ពអ៊្ហូសាម៉ះទៅកាន់ប្រទេសអ៊ីរ៉ាក់ ដើម្បីធ្វើសង្គ្រាមតទល់នឹងពួកហ្វូរស៊ី?ក៏ប៉ុន្តែលោកបែរជាជ្រើសរើសយកតាមអ្វីដែលណាហ្ពីបានបញ្ជាទៅវិញ( គឺបញ្ជូនទ័ពអ៊្ហូសាម៉ះទៅកាន់ប្រទេសស្ហាម) ។

**ហ្ស៊ីយ៉ាដ** : នេះជាឥរិយាបទបែបម៉ឺងម៉ាត់របស់អាហ្ពូហ្ពាកើរ ពោលគឺលោកធ្វើតាមបញ្ជារបស់ណាហ្ពីទាំងស្រុង ដូចអ្វីដែលមានបញ្ជាក់ក្នុងសំដីរបស់លោកថាៈរូបខ្ញុំជាអ្នកប្រតិបត្តិតាម មិនមែនជាអ្នកបង្កើតរឿងថ្មីទេ ។ ខ្ញុំនឹងមិនព្រងើយកន្តើយនូវកិច្ចការណាមួយដែលខ្ញុំបានឃើញវ៉ស៊្ហ៊ូលុលឡោះធ្វើយ៉ាងម៉េច គឺខ្ញុំត្រូវតែធ្វើដូចនោះដែរ ។

**ឪពុកៈ** ពិតមែនហើយ! ការសំរេចភារកិច្ចត្រឹមត្រូវនិងគតិបណ្ឌិតរបស់លោកអាហ្ពូហ្ពាកើរខណៈដែលលោកបានចាត់តាំងអ៊្ហូសាម៉ះនោះ។ តាមការរាយការណ៏របស់ពួកប្រវត្តិសាស្ត្របញ្ជាក់ប្រាប់ថាៈ ការចាត់តាំងអ៊្ហូសាម៉ះនិងការបំពេញបេសកកម្មរបស់លោក ទៅលើពួកដែលមានបំណងក្បត់សាសនា



អ៊ីស្លាម ពោលគឺរាល់ពេលដែលលោកនិងក្រុមរបស់លោកដើរកាត់ពួកដែលមានបំណងក្បត់ពួកគេតែងតែនិយាយថាៈ បើអ្នកមានជំនឿមិនម៉ឺងម៉ាត់ទេច្បាស់ជាមានអ្នកចង់ក្បត់សាសនាអ៊ីស្លាមច្រើនមិនខាន។ ភាពម៉ឺងម៉ាត់នេះហើយធ្វើអោយពួកចង់ក្បត់នោះនៅរក្សាភាពជាអ្នកកាន់សាសនាវិញ ។

**ម៉ាស់មូដៈ** ចង់បញ្ជាក់អោយបានច្បាស់ថែមទៀតថាៈការចាត់តាំងអ៊្ហូសាម៉ះនោះ គឺជាការដាក់គំនាបមួយដល់កុលសម្ព័ន្ធមួយចំនួនទៅតំបន់ចន្លោះស្រុកស្ហាមនិងតំបន់ម៉ាក្កះម៉ាឌីណះ ដែលវាជារង្វាន់មួយរបស់សាសនាអ៊ីស្លាម ។

## ការបង្ក្រាបទៅលើអ្នកក្បត់សាសនា

**ម៉ាស់មូដៈ**ការក្បត់សាសនាបានកើតឡើង បន្ទាប់ពីមរណភាពរបស់ណាហ្ពី ។

**ហ្វាទីម៉ះ** : ខ្ញុំសូមសួរថា តើពាក្យ" អ្នកក្បត់សាសនា" មានន័យដូចម្តេច?

**ឪពុក** : ពាក្យនេះសំដៅលើអ្នកដែលដើរចេញពីជំនឿលើសាសនាអ៊ីស្លាមទៅជំនឿសាសនាផ្សេង ។ការបង្ក្រាបពួកនោះបានកើតមានឡើង ដោយសារមានពួកកុលសម្ព័ន្ធអារ៉ាប់បានចាកចេញពីសាសនាអ៊ីស្លាមបន្ទាប់ពីណាហ្ពីបានទទួលមរណៈភាព ដោយពួកគេត្រឡប់ទៅគោរពសក្ការៈអ្វីមួយផ្សេងពីអល់ឡោះម្ចាស់ មិនតែប៉ុណ្ណោះ មានពួកគេមួយចំនួនបានចាត់ទុកខ្លួនឯងជាណាហ្ពីទៀតផង និងមានមួយចំនួនទៀតមិនព្រមចេញហ្ស៊ាកាត់( ការបរិច្ចាគទានសម្បត្តិសល់ផ្ទាល់ខ្លួន) ។ ពួកគេអះអាងថាពួកយើងនឹងមិនសឡាហ៍ និងមិនបរិច្ចាគទានហ្ស៊ាកាត់ឡើយ ។ ខណៈនោះអាហ្ពូហ្ពាកើរបានពោលថាៈ

ខ្ញុំសូមស្បថនឹងអល់ឡោះថា ប្រសិនបើពួកគេរារាំងខ្ញុំទំហំប៉ុនអ៊ីកល(ខ្សែមួយកងតូចសំរាប់ទាក់ជើងសត្វអូដ្ឋ) ដែលពួកគេធ្លាប់ធ្វើចំពោះរ៉ស៊ូលគឺខ្ញុំត្រូវតែបង្ក្រាបពួកនោះអោយខាងតែបាន ។

**មូហាំម៉ាត់ :** បើអញ្ចឹង ! ពេលនេះយើងចាប់ផ្ដើមនិយាយអំពីពួកដែលចាត់ទុកខ្លួនថាជាណាហ្ពី។ តើពួកគេជានរណាខ្លះ? ចុះហេតុអ្វីបានជាពួកនេះហ៊ានធ្វើអញ្ចឹង?

**អ៊ីស្លាម :** បងប្រុស ! សូមរង់ចាំបន្តិច។ ជាការពិតណាស់ខ្ញុំបានអានឯកសារមួយបញ្ជាក់ថា: សាសនវិទូអ៊ីស្លាមមួយចំនួនបានលើកឡើងថា: ពិតណាស់បន្ទូលរបស់អល់ឡោះក្នុងជំពូកអាល់ម៉ាអ៊ីឌះវាក្យខ័ណ្ឌ៥៤ដែលមានន័យថា : ឱ! បណ្ដាអ្នកដែលមានជំនឿទាំងឡាយ បុគ្គលណាក៏ដោយក្នុងចំណោមពួកអ្នកទាំងអស់គ្នាដែលគេបានចាកចេញពីសាសនាអ៊ីស្លាមនោះ អល់ឡោះនឹងប្ដូរមកវិញនូវក្រុមផ្សេងដែលទ្រង់ពេញចិត្តនឹងពួកគេ ហើយពួកនោះក៏ពេញចិត្តចំពោះទ្រង់ផងដែរ។ ពួកគេបន្ទាបខ្លួនជាមួយអ្នកមានជំនឿតែពួកគេម៉ឺងម៉ាត់ចំពោះអ្នកគ្មានជំនឿ ។ពួកគេនឹងតស៊ូក្នុងមាគ៌ាអល់ឡោះ ហើយពួកគេគ្មានការភ័យខ្លាចការស្ដីបន្ទោសអ្វីឡើយ ។នេះគឺជាឧត្ដមភាពរបស់អល់ឡោះដែលទ្រង់ផ្ដល់ដល់បុគ្គលណា ដែលទ្រង់ប្រាថ្នាអល់ឡោះមហាធំធេង និងដឹងបំផុត ។វាក្យខ័ណ្ឌនេះសំដៅទៅលើការគ្រប់គ្រងរបស់អាហ្ពូហ្ពាកើររួចបំពេញភារកិច្ចសំរាប់រ៉ស៊ូលរបស់អល់ឡោះទាំងរូបលោក និងមិត្តសំលាញ់ទាំងអស់



របស់រ៉ស៊ូលុលឡោះ ដែលបានតស៊ូបង្ក្រាបពួកដែលមានបំណងក្បត់សាសនាអ៊ីស្លាមរហូតធ្វើអោយពួកគេវិលមករកផ្លូវត្រឹមត្រូវវិញ។

**អាប់ឌុររ៉ស់ម៉ាន :** ខ្ញុំក៏បានអាននូវវាក្យខ័ណ្ឌទី១៦ ក្នុងជំពូកអាល់ហ្វាត់ហ៏ដែលមានន័យថា: ឱមូហាំម៉ាត់ ! ចូរអ្នកមានប្រសាសន៏ ទៅកាន់ពួកជនបទដែលបោះបង់ការធ្វើសង្គ្រាម ដោយអ្នកសំណូមពរអោយពួកគេចូលរួមធ្វើសង្គ្រាមចំពោះក្រុមណាដែលអាចច្បាំងបាន។ ពួកអ្នកអាចសំលាប់ពួកគេឬក៏ពួកគេអាចចុះចូលជាមួយយើងក៏បាន ។ប្រសិនបើពួកអ្នកគោរពតាមអល់ឡោះនឹងផ្ដល់នូវកុសលដ៏ប្រពៃដល់ពួកអ្នក ។ប្រសិនបើពួកអ្នកបោះបង់ដូចដែលពួកអ្នកធ្លាប់បានបោះបង់កន្លងនោះពួកអ្នកនឹងទទួលនូវទារុណកម្មយ៉ាងខ្លោចផ្សាបំផុត ” ។ វាក្យខ័ណ្ឌនេះសំដៅទៅលើការគ្រប់គ្រងរបស់អាហ្ពូហ្ពាកើររួចបំពេញភារកិច្ចសំរាប់រ៉ស៊ូលរបស់អល់ឡោះ ព្រោះលោកបានចាត់វិធានការទៅលើពពួកដែលចាត់ទុកខ្លួនឯងថាជារ៉ស៊ូលបន្ទាប់ពីរ៉ស៊ូលមូហាំម៉ាត់ ដូចជាមូសៃឡាម៉ាស់អាល់កាហ្សាប់(ប្រកាសខ្លួនឯងថាជារ៉ស៊ូល) ។

**ហ្វាទីម៉ះ :** មុនពេលរ៉ស៊ូលុលឡោះទទួលមរណៈភាព លោកបានប្រើថា: (ចូរពួកអ្នកប្រើអោយអាហ្ពូហ្ពាកើរធ្វើជាអ៊ីម៉ាំសឡាហ៏) នេះគឺជាភស្ដុតាងបង្ហាញពីការគ្រប់គ្រងរបស់អាហ្ពូហ្ពាកើរក្រោយពីណាហ្ពីផងដែរ។

**ហ៊ូសាមៈ** ពួកយើងត្រូវវិលទៅរកពួកក្បត់សាសនាវិញ។ លោកអាហ្ពូហ្ពាកើរបានយកចិត្តទុកដាក់ខ្ពស់ចំពោះការការពារម៉ាឌីណះ។ ពេលនោះលោកបានរៀបចំលោកអាលី លោកតល់ហះ លោកហ្ស៊ូហ្ពៃរ៏ និងលោកអាប់ឌុលឡោះ

កូនម៉ាសអ៊ូដអោយការពារច្រកចូលក្រុងម៉ាឌីណះ និងប្រើអោយអ្នកមានជំនឿនៅតាមម៉ាស្ជិតត្រៀមប្រយុទ្ធ។ បន្ទាប់មកពួកគេទាំងអស់បាននាំគ្នាចេញទៅតាមគោលដៅរៀងៗខ្លួន។ ពួកគេក៏ប្រយុទ្ធជាមួយពួកសត្រូវដែលបានសំលាប់អ្នកមានជំនឿរហូតទទួលជ័យជំនះ។ ក្រោយមកក៏វិលត្រឡប់ទៅកាន់ម៉ាឌីណះ វិញស្របពេលនោះដែរអ៊ូសាម៉ះកូនហ្សៃតក៏បានវិលត្រឡប់ពីប្រទេសរ៉ូម ដោយនាំមកនូវជ័យជំនះយ៉ាងត្រចះត្រចង់ព្រមទាំងមានមកជាមួយនូវជ័យភ័ណ្ឌជាច្រើនសន្ធឹកសន្ធាប់ទៀតផង។ ខណៈពេលដែលកងទ័ពរបស់អ៊ូសាម៉ះបញ្ចប់បេសកកម្មដោយជោគជ័យរួច អាហ្ពូហ្ពាកើរក៏បានបែងចែកទ័ពនេះទៅជា១១កងពលតូច។ ក្នុងនោះកងពលដែលរឹងមាំជាងគេគឺកងពលដែលដឹកនាំដោយខលីដកូនអាល់វ៉ាលីដ។ អាហ្ពូហ្ពាកើរបានបញ្ជូនកងពលនេះទៅកំទេចលោកតូលៃហះអាល់អាសាត់មុនគេបង្អស់។

**អ៊ីស្លាម :** លោកខលីដកូនអាល់វ៉ាលីដត្រូវបានរ៉ស៊ូលុលឡោះដាក់ងារអោយថា: សៃហ្វុលឡោះអាល់ម៉ាសលូល( ដាវរបស់អល់ឡោះដែលគ្មានស្រោម)

**ណាដា :** តើតូលៃហះនោះពុំមែនជាជនដែលបានចាត់ទុកខ្លួនគេថាជាណាហ្ពីតាំងពីពេលដែលរ៉ស៊ូលុលឡោះនៅមានជីវិតរស់នៅទេឬ?រូបគេជាអ្នកដែលរ៉ស៊ូលុលឡោះបានបញ្ជូនឌីរ៉តអាល់អាហ្សូរអោយទៅធ្វើឃាតនោះឬ?

**ឪពុក :** ពិតមែនហើយ! តូលៃហះនេះហើយដែលបានអះអាងថា:ជិបរ៉អ៊ីលបាននាំវ៉ាហ៊ីមកអោយខ្លួន។ លោកខលីដកូនអាល់វ៉ាលីដបានយកជ័យជំនះហើយក៏បានដោះស្រាយនូវការបង្កភាពចលាចលរបស់តូលៃហះផងដែរ។



នៅពេលនោះតូលៃហះក៏បានរត់គេចខ្លួនទៅកាន់ស្រុកស្ហាម។ កូនៗជាទីស្រលាញ់! ក្រោយមកតូលៃហះក៏បានវិលមកទទួលយកសាសនាអ៊ីស្លាមវិញហើយបានធ្វើដំណើរទៅម៉ាក្កះដើម្បីធ្វើអ៊ុំរោះ ក្នុងសម័យអាហ្ពូហ្ពាកើរជាមេដឹកនាំ។ នៅពេលតូលៃហះធ្វើដំណើរឆ្លងកាត់ម៉ាឌីណះមានគេប្រាប់ដំណឹងនេះដល់អាហ្ពូហ្ពាកើរដែរ តែអាហ្ពូហ្ពាកើរបាននិយាយថា: សូមកុំធ្វើអ្វីគេអោយសោះ ព្រោះអល់ឡោះចង្អុលបង្ហាញគេអោយចូលកាន់សាសនាអ៊ីស្លាមវិញហើយ។ អ៊ីស្លាមរបស់តូលៃហះកាន់តែប្រសើរឡើងៗក្រោយមកទៀតតូលៃហះក៏បានចូលរួមនៅក្នុងសមរភូមិអាល់កាឌីស៊ីយ៉ះ ផងដែរ ”។

**ហ្សៃយ៉ាដ:** ចំពោះលោកអាត់ឌីកូនហាទិមវិញ ខ្ញុំបានអានជីវប្រវត្តិរបស់គាត់បញ្ជាក់ថា: គាត់បានចាប់កំណើតក្នុងតំបន់ពិសិដ្ឋមួយ។ អ្នកមានកំណើតនៅតំបន់នេះភាគច្រើនជាមនុស្សល្អ ត្រង់នេះហើយទើបលោកអាត់ឌីបានក្លាយជាអ្នកដាស់តឿនរំលឹកដល់ក្រុមរបស់គាត់ ហើយបានធ្វើឱ្យពួកនោះវិលមករកកាន់សាសនាអ៊ីស្លាមវិញ។

**ម៉ាស់មូដ:** ឱ បងប្អូនទាំងអស់គ្នា! ខ្ញុំដឹងត្រឹមថា: អ្នកដែលចាត់ទុកខ្លួនឯងជារ៉ស៊ូលគឺមូសៃឡាម៉ះអាល់កែសហ្ស៊ាប់ប៉ុណ្ណោះ ។

**មូហាំម៉ាត់:** ទេ ! មូសៃឡើម៉ះអាល់កែសហ្សាប់ជាបុគ្គលម្នាក់ក្នុងចំណោមពួកគេប៉ុណ្ណោះ។ ជនដែលអះអាងខ្លួនជាណាហ្ពីមុនលោកមូសៃឡើម៉ះនោះគឺអាល់អាស់វ៉ាដអាល់អាន់ស៊ី និងស៊ូជ៉ើហ៍។ សូជ៉ើហ៍នេះជាស្ត្រីម្នាក់ដែលបាន

អះអាងខ្លួនថាជាណាហ្ពី ហើយនាងបានបញ្ជាអោយអ្នកអាហ្សាន( អ្នកស្រែកប្រកាសពេលសឡាហ៍ )បញ្ចូលឈ្មោះរបស់នាងនៅក្នុងឃ្លាអាហ្សាន ។

**ហ្វាទីម៉ះ :** ( لاحولا ولا قُوةَ إِلا بِالله الْعليِ الْعظيِم )
មានន័យថាៈគ្មានអំណាចនិងគ្មានកំលាំងពលំអ្វី ក្រៅពីអល់ឡោះដ៏ខ្ពង់ខ្ពស់ឧត្តុងឧត្តមបំផុត ។

**ណាជា :** សូជ៉ើហ៍កូនស្រីហារីសអាត់តៃមីនេះហើយដែលបានអះអាងថាខ្លួនជាណាហ្ពី បន្ទាប់ពីណាហ្ពីមូហាំម៉ាត់បានទទួលមរណៈភាព ក្រោយមកនាងបានមានគោលបំណងសំលាប់មេដឹកនាំ របស់រ៉ស៊ូលុលឡោះគឺអាហ្ពូហ្គាកើរ ។ បន្ទាប់មកនាងបានធ្វើដំណើរទៅកាន់តំបន់អាល់យ៉ាម៉ាម៉ះ ក្នុងគោលបំណងធ្វើឃាតម៉ូសៃឡើម៉ះអាល់កែសហ្សាប់ ។ តែផ្ទុយទៅវិញនាងបែរទៅជាព្រមរៀបអាពាហ៍ពិពាហ៍ជាមួយម៉ូសៃឡើម៉ះអាល់កែសហ្សាប់ទៅវិញ ក្រោយពីអ្នកទាំងពីរបានឯកភាពគ្នាក្នុងការបែងចែកតួនាទីជាណាហ្ពី ។ អ្នកទាំងពីរឈានដល់ការបែងចែកផ្ទៃដីផ្តល់ផលច្រើនឬតិចទៅតាមតំបន់ផ្សេងៗទៀត ។

**ហ៊ូសាម :** ប្រាក់ខាន់ស្លានាង( ហ៊ិស្ហាមសើចហើយពោលបន្តថា ) គេយកសឡាហ៍អាល់ហ្វាជើរ ហើយភាពងងឹតសូនឈឹងគ្របដណ្តប់លើជនណាដែលសំរេចដើរតាមពួកគេទាំងពីរនោះ ។

**កូនៗពោលថា:** ( سبحان الله العظيم ) អល់ឡោះបានចាត់បញ្ជូនសារហារីរបស់ទ្រង់ គឺមូហាំម៉ាត់ ដើម្បីនាំមកនូវ មាគ៌ាដ៏ត្រឹមត្រូវនិងសច្ចៈភាព ។



**ព្រឹត្តិការណ៍នៅតំបន់អាល់យ៉ាម៉ាម៉ះ**

**អ៊ិស្លាម :** លោកខលីដបានចេញដំណើរទៅតាមការបញ្ជារបស់លោកអាហ្ពូហ្គាកើរដើម្បីទៅសំលាប់មូសៃឡើម៉ះអាល់កែសហ្សាបនៅយ៉ាម៉ាម៉ះ ។លោកអាហ្ពូហ្គាកើរបានដឹងថាកំលាំងពួកវាមានចំនួនច្រើន ខណៈនោះលោកបានផ្តាំផ្ញើលោកខលីដអោយបួងសួងសុំអំពីអល់ឡោះ អោយជួយក្នុងការកំទេចពួកវាជាពិសេសសំដៅទៅលើបុគ្គលមូសៃឡើម៉ះអាល់កែសហ្សាប់តែម្តង ដែលបុគ្គលរូបនេះធ្លាប់យកជ័យជំនះលើ អិករីម៉ះកូនអាហ្ពីយើហ៊ិល ។ អិករីម៉ះជាមេទ័ពពូកែម្នាក់ ជាអ្នកជំនាញខាងជិះសេះ និងជាអ្នកប្រយុទ្ធមួយរូបផងដែរ មិនតែប៉ុណ្ណោះក៏មានមេទ័ពអ៊ិស្លាមជំនាញផ្សេងៗទៀត ក៏នៅតែចាញ់ដៃមូសៃឡើម៉ះដដែល ។

**ម៉ាស់មូដះ** ព្រឹត្តិការណ៍នៅយ៉ាម៉ាម៉ះគឺជាព្រឹត្តិការណ៍ក្តៅគគុកនិងសំខាន់បំផុតនៅក្នុងប្រវត្តិសាស្ត្ររបស់អ៊ិស្លាមនិងប្រវត្តិសាស្ត្ររបស់អារ៉ាប់ ។

**ហ្វាទីម៉ះ** ពិតមែនហើយកាលនោះកងទ័ពរបស់មូសៃឡើម៉ះអាល់កែសហ្សាប់មានចំនួនច្រើនជាង៤0000នាក់ ដោយឡែកកងទ័ពរបស់ពួកមូស្លីមវិញមានត្រឹមតែ១៣000នាក់ប៉ុណ្ណោះ ។ ជីវិតមូសៃឡើម៉ះអាល់កែសហ្សាប់ត្រូវបានបញ្ចប់នៅក្នុងសង្គ្រាមអាល់យ៉ាម៉ាម៉ះដែលមានមេទ័ពខលីដកូនអាល់វ៉ាលីដ ។ អ្នកមូស្លីមបានបាត់បង់ជីវិតនៅក្នុងសង្គ្រាមនោះមានចំនួនដល់ទៅ១២00នាក់ក្នុងចំណោមអ្នកទទួលមរណភាពនោះមាន ៣៩នាក់ ជាសាហាហ្ព័តជំនិត និងជាអ្នកចងចាំគម្ពីរអាល់គួរអានទាំងមូលតែម្តង ។ ដោយឡែកពពួកសត្រូវវិញ

ត្រូវបានសំលាប់ជាច្រើនក្នុងនោះគ្រាន់តែអំបូរហានីហ្វះមួយ ដែលមានស្វាមីភក្តិចំពោះម៉ូសៃឡើម៉ះ ត្រូវសំលាប់ចំនួន ៧០០០ នាក់ នៅហាឌីកាទុលម៉ោត (ចំការមរណៈ)និងចំនួន៧០០០នាក់ទៀតនៅទីលានផ្សេងៗហើយនិង៧០០០នាក់ទៀតត្រូវសំលាប់នៅម៉ាត់រ៉ទុលហ្វើរិន ។

**អ៊ីស្លាម :** អល់ឡោះបានបំភ្លឺរស្មីរបស់ទ្រង់ ។ ទ្រង់បានពង្រឹងកងទ័ពរបស់ទ្រង់(ពួកម៉ូស្លីម) និងទ្រង់ជួយសាសនាអ៊ីស្លាមអោយមានជ័យជំនះដោយសំលាប់ម៉ូសៃឡើម៉ះអាល់កែសហ្សាប និងបំបាត់ភាពចលាចលផ្សេងៗ ។

**ហ៊ូសាម :** សង្គ្រាមនៅអាល់យ៉ាម៉ាម៉ះមានទ្រង់ទ្រាយធំជាងគេក្នុងការកំចាត់ពួកក្បត់សាសនា ។

## ការរំដោះនៅសម័យអាស្សិតហ្វ៊ីក

**ហ្ស៊ីយ៉ាដ:**បន្ទាប់ពីសង្គ្រាមនៅយ៉ាម៉ាម៉ះលោកអាស្សិតហ្វ៊ីកបានបញ្ជូនខលីដកូនវ៉ាលីដទៅរំដោះប្រទេសអ៊ីរ៉ាក់ដោយដាក់បញ្ជាថាៈ មិនត្រូវសុំជំនួយពីបុគ្គលដែលធ្លាប់ក្បត់សាសនាឡើយ ទោះបីគេវិលត្រឡប់មកអ៊ីស្លាមវិញហើយក៏ដោយ ។ អ៊ីស្លាមជាសាសនាសន្តិភាព និងសុវត្ថិភាព ។

**ឪពុកៈ** ពិតមែនហើយ! លោកអាហ្ពូហ្គាកើរអាស្សិតហ្វ៊ីកបានផ្តាំផ្ញើក្នុងពេលធ្វើសង្គ្រាមនោះថាៈ " សូមពួកអ្នកកុំក្បត់គ្នា កុំបំពារបំពាន(រឹបអូសយកអ្វីដែលមិនមែនជាកម្មសិទ្ធិ) កុំក្បត់ពាក្យសន្យា កុំកំទេចសាកសព (សាសនាអ៊ីស្លាមហាមឃាត់ការធ្វើបែបនេះ) កុំសំលាប់ក្មេង ចាស់ជរា និងស្ត្រីភេទ



កុំដុតបំផ្លាញដើមល្មើ ឬដើមឈើផ្សេងៗ កុំសំឡេះសត្វចៀម សត្វគោ សត្វអូដ្ឋ លើកលែងតែសំរាប់បរិភោគ ហើយនៅពេលណាពួកអ្នកធ្វើដំណើរឆ្លងកាត់បានជួបអ្នកដែលកំពុងគោរពព្រះនៅក្នុងវិហាររបស់គេ សូមកុំបំផ្លាញពួកគេអោយសោះ ចូរទុកពួកគេតាមជំនឿរបស់ពួកគេចុះ ។

**ហ្វាទីម៉ះ:** លោកខលីដនិងបណ្តាអ្នកដែលរួមដំណើរជាមួយលោកបានអំពាវនាវមនុស្សអោយទទួលយកសាសនាអ៊ីស្លាម ។ប្រសិនបើពួកគេបានបដិសេធហើយនៅតែប្រកាន់យកជំនឿដដែលនោះ លោកបានកំណត់អោយពួកគេបង់ពន្ធលើខ្លួនគេម្នាក់ៗ ។

**ហ៊ូសាម :**នេះបង្ហាញយ៉ាងច្បាស់ថាៈ សាសនាអ៊ីស្លាមមិនបានបង្ខំមនុស្សដោយប្រើអាវុធនោះទេ ព្រោះសាសនាអ៊ីស្លាម សាសាសនាសច្ចៈភាព ជាសាសនាសុវត្ថិភាព និងជាសាសនាស្មោះត្រង់ ។

**ឪពុកៈ**ត្រឹមត្រូវហើយ! អ្នកម៉ូស្លីមមិនបានដាក់កំហិតទៅលើប្រទេសដែលខ្លួនបានរំដោះនេះត្រូវតែកាន់សាសនាអ៊ីស្លាមនោះឡើយ ។ ផ្ទុយទៅវិញពួកគេត្រូវបានគេផ្តល់សិទ្ធិសេរីភាពក្នុងជំនឿសាសនាដល់មនុស្សលោកទាំងអស់ចំពោះអ្នកព្រមទទួលយកសាសនាអ៊ីស្លាមគឺពួកគេស្ថិតក្នុង ចំណោមពួកអ្នកកាន់សាសនាអ៊ីស្លាម តែបើគេគ្មានជំនឿទេ គឺពួកគេត្រូវបង់ពន្ធលើខ្លួនគេ ។

**ម៉ាស់មូដ :** ការបង់ពន្ធលើខ្លួនគេ! វាជាអ្វីទៅ ?

**ឪពុកៈ**ការបង់ពន្ធលើខ្លួនគេ គឺជាទ្រព្យសម្បត្តិដែលគេត្រូវបង់ពន្ធដើម្បីប្តូរនឹងការធានាសន្តិសុខសង្គម ហើយការហូតពន្ធនេះកំណត់លើអ្នកដែលមិនទាន់

ទទួលយកសាសនាអ៊ីស្លាមប៉ុណ្ណោះ។ រួចគេបានកត់ត្រាកិច្ចសន្យាមួយ ដែលធានាពីសន្តិសុខ ហើយពួកគេគ្មានសិទ្ធិចូលរួមជាមួយកងទ័ពមូស្លីមឡើយ ហើយថែមទាំងមិនអាចជួយធ្វើសង្គ្រាមដើម្បីប្តូរនឹងប្រាក់ពន្ធលើខ្លួនផងដែរ ដរាបណាគេមិនទាន់មានជំនឿនឹងសាសនាអ៊ីស្លាមនោះ។

**អ៊ីស្លាម:** សំរាប់ពួកគេមានសេរីភាពពេញលេញក្នុងការអនុវត្តច្បាប់សាសនារបស់ពួកគេ។

**កូន១ :** អល់ឡោះ! ការអនុគ្រោះរបស់សាសនាអ៊ីស្លាមប្រពៃខ្លាំងណាស់! ហើយការលើកតំកើងចំពោះក្រិតក្រមសាសនាក៏យកចិត្តទុកដាក់ដែរ! ។

**ណាជា :** ចុះបើគេជ្រើសរើសយកការបង់ពន្ធលើខ្លួន ដើម្បីបានចូលទៅក្នុងកិច្ចការកងទ័ពនោះយ៉ាងណាដែរ?

**ឪពុក :** ករណីនេះគេមិនទទួលយកទេ យើងសូមបញ្ជាក់លើករណីនេះថា: ការបង់ពន្ធលើខ្លួនគឺជាប្រាក់ដែលត្រូវគេចំណាយប្តូរនឹងការគាំពារទូទៅពីសំណាក់រដ្ឋាភិបាល ហើយរដ្ឋាភិបាលក៏យកថវិកាមូស្លីម សំរាប់ចំណាយលើការគាំពារនេះដែរ វាមិនមែនជាប្រាក់ចាប់បង្ខំឬជាបំណុលដែលគេដាក់កាតព្វកិច្ចក្នុងន័យបន្ទាបបន្ថោក ឬការចុះចូលនោះទេ។ ការបង់ពន្ធលើខ្លួននេះគឺស្មើនឹងការបរិច្ចាគទានហ្សាកាត់របស់អ្នកកាន់សាសនាអ៊ីស្លាម ហើយហ្សាកាត់វាជាបំណុលចំពោះអ្នកកាន់សាសនាអ៊ីស្លាមដើម្បីអនុវត្តច្បាប់ប្រទេស ហើយនិងការការពារច្បាប់ទាំងនោះ ហើយហ្សាកាត់សំរាប់ជួយដល់ទុគ៌តជន។

**ហ្ស៊ីយ៉ាដ:** សំរាប់រូបខ្ញុំផ្ទាល់មានពតិមានពាក់ព័ន្ធអំពីការបង់ពន្ធលើខ្លួននេះ



ដែលពេលនេះខ្ញុំមានបំណងចង់បញ្ជាក់ប្រាប់ថា: ការបង់ពន្ធលើខ្លួននៅក្នុងសាសនាអ៊ីស្លាមគេបានកំណត់លើតែប្រុសៗប៉ុណ្ណោះ។

**ណាជា :** តើវាមានន័យដូចម្តេចទៅ ?

**ហ្ស៊ីយ៉ាដ:** គឺគេមិនបានដាក់កំណត់មកលើក្មេង ស្ត្រីភេទ ឬមនុស្សវិកលចរិត និងអ្នកដែលមិនមានលទ្ធភាពដូចជា ចាស់ជរា ជនទីទ័លក្រដែលរស់ដោយសារការបរិច្ចាគទាន ឬពីជនពិការនោះឡើយ។

**សើម៉ាហ៍ :** អល់ឡោះ ! ..... សាសនាអ៊ីស្លាមអស្ចារ្យណាស់! ផ្តល់សេរីភាពដល់មនុស្សលោកក្នុងការជ្រើសរើសជំនឿរបស់ខ្លួនដោយមិនបានដាក់គំនាបលើនរណាម្នាក់អោយប្រកាន់យកសាសនាអ៊ីស្លាមដោយការបង្ខិតបង្ខំឡើយ។ ដូចអល់ឡោះបានមានបន្ទូលនៅក្នុងជំពូកអាល់ហ្គាការ៉ោះវាក្យខ័ណ្ឌ២៥៦ ដែលមានន័យថា: (មិនមានការកៀបសង្កត់ (បង្ខិតបង្ខំ) នៅក្នុងសាសនាអ៊ីស្លាមឡើយ)។

## ទេពកោសល្យនិងភាពរឹងមាំរបស់អាហ្គូហ្គាគើរលើសច្ចៈភាព

**អ៊ីស្លាម:** យើងវិលត្រលប់មកនិយាយអំពីការដណ្តើមយកជោគជ័យទាំងឡាយដែលប្រកបដោយភាពឆ្នើម ភាពឈ្លាសវៃនិងភាពរឹងមាំ និងការការពារសាសនាអ៊ីស្លាមរបស់អាហ្គូហ្គាគើរអាស្ស៊ីតហ្គីក ហើយនិងភាពអង់អាចក្លាហានរបស់លោកខលីដនិងបណ្តាសាហាហ្ប៉ីតដ៏ឧត្តុង្គឧត្តមដទៃទៀត ដែលពួកគេបានចូលរួមនៅក្នុងសង្គ្រាមតទល់នឹងពួកក្បត់សាសនាអ៊ីស្លាម ក៏មានអ្នកទទួលមរណភាពនៅក្នុងសមរភូមិផងដែរ ក្នុងនោះមានអ្នកដែលបាន

តស៊ូប្រយុទ្ធនៅក្នុងសមរភូមិផ្សេងៗ រហូតអស់ឡោះបានអោយសាសនាអ៊ីស្លាមរឹងមាំដោយសារពួកសាហាប៉្តត និងអាស្ស៊ីតហ្វ៊ីក ។

**អាប់ឌុរ៉រ៉ស់ម៉ាន** : ឥឡូវនេះខ្ញុំនិយាយរឿងដែលធ្វើអោយខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំង ហើយខ្ញុំបានកំណត់ក្នុងចិត្តថា:ខ្ញុំមិនតបតចំពោះជនដែលមានបំនងអាក្រក់មកលើរូបខ្ញុំជារៀងរហូត ក្រោយពីខ្ញុំបានអានប្រវត្តិនោះរួចមក ។ដំណើររឿងនោះមានដូចតទៅ: មានបុរសម្នាក់ជេរស្តីអាហ្គូហ្គាកើរ តែលោកមិនតបតំពោះជននោះវិញទេ ខណៈនោះរ៉ស៊ូលុលឡោះអង្គុយនៅមិនឆ្ងាយពីអាហ្គូហ្គាកើរឡើយ ។ ពេលនោះរ៉ស៊ូលុលឡោះមើលឃើញហើយលោកញញឹម ។ បុរសនោះនៅតែបន្តការជេរស្តីមកលើអាហ្គូហ្គាកើរថែមទៀត ពេលនោះអាហ្គូហ្គាកើរទ្រាំមិនបានក៏តបតវិញ។ ខណៈនោះស្រាប់តែរ៉ស៊ូលុលឡោះបានក្រោកឈរ រួចដើរចេញទៅ។ ក្រោយមកអាហ្គូហ្គាកើរដើរទៅជួបរ៉ស៊ូលុលឡោះ ហើយបានសួរលោកថា:ឱរ៉ស៊ូលុលឡោះ! ហេតុអ្វីបានជាលោកក្រោកឈរ រួចដើរចេញ? រ៉ស៊ូលុលឡោះបានមានប្រសាសន៏ថា: ( អម្បាញ់មិញមានម៉ាឡាអ៊ីកាហ៏មួយរូបនៅជាមួយអ្នក ជួយធ្វើការឆ្លើយតបជំនួសអ្នក តែដល់ពេលអ្នកឆ្លើយតបនឹងសំដីបុរសនោះវិញ ពេលនោះស្ហៃតន( បិសាច) ឆ្លៀតចូលមកហើយ ហើយរូបខ្ញុំនឹងមិនអង្គុយជាមួយស្ហៃតនឡើយ ។

**ម៉ាស់មូដ** : អាហ្គូហ្គាកើរពិតជាមនុស្សល្អឥតខ្ចោះមែន គ្រាន់តែលោកមិនមែនជារ៉ស៊ូលប៉ុណ្ណោះ ។



ឳពុកៈ អាហ្គូហ្គាកើរពិតជាអ្នកអំពាវនាវ ( មនុស្សលោកអោយទទួលយកនូវសាសនាអ៊ីស្លាមដ៏ល្អប្រពៃ) ទី២ ពោលគឺទី២បន្ទាប់ពីរ៉ស៊ូលុលឡោះនូវរាល់អ្វីទាំងអស់ ។

**ណាដា** : បានន័យថាយ៉ាងម៉េច?

**អាប់ឌុរ៉រ៉ស់ម៉ាន** : ចាប់ពីការទទួលនូវជំនឿអ៊ីស្លាមរហូតដល់ក្លាយជាមេដឹកនាំទទួលខុសត្រូវកិច្ចការរបស់មូស្លីមីន រហូតដល់ធ្វើការអំពាវនាវអោយទទួលយកសាសនាអ៊ីស្លាមជាថ្មីរបស់អ្នកបានក្បត់សាសនា។ អាហ្គូហ្គាកើរជាអ្នកទី២នៅក្នុងរូងភ្នំ លោកជាអ្នកមុនគេក្នុងការអនុវត្ត និងឆ្លើយតបតាមសាសនាអ៊ីស្លាម ។

**អ៊ីស្លាម** : មានពួកអាន់សរ៉ និងពួកមូហាជ្ជិរីនបាននាំគ្នារំលឹកចំពោះឧត្តមភាពអ្នកដែលមានឋានៈខ្ពង់ខ្ពស់ជាងគេនៅក្បែរទ្វារផ្ទះរបស់ណាហ្វី។ ខណៈនោះណាហ្វីបានចេញមក ហើយសួរពួកគេថា តើពួកអ្នកនាំគ្នាធ្វើអ្វី?ពួកគេឆ្លើយថា ពួកយើងកំពុងតែនិយាយដល់អ្នកដែលមានស្នាដៃឧត្តុង្គឧត្តម! រ៉ស៊ូលុលឡោះមានប្រសាសន៏ថា: ពួកអ្នកមិនត្រូវអោយតំលៃនរណាម្នាក់ប្រសើរជាងអាហ្គូហ្គាកើរឡើយ ព្រោះអាហ្គូហ្គាកើរប្រសើរជាងពួកអ្នកទាំងនៅលើលោកិយនិងនៅថ្ងៃបរលោក។

## អ៊ូម៉ើរក្ងូនខត្តបមេដឹកនាំអ៊ីស្លាមទី២

(១៣-២៣ម.ស/៦៣៤-៦៤៤គ.ស)

**អ៊ីស្លាមៈ** វាជាពន្លឺរបស់ថ្នាក់ដឹកនាំកំពូលអ៊ីស្លាមទី២ ដែលគេស្គាល់យ៉ាងជាក់ច្បាស់ហើយដែលពួកយើងបានទទួលនូវភាពយុត្តិធម៌ និងសេចក្តីថ្លៃថ្នូរពីលោក។ ពន្លឺបានជះទៅលើភាពងងឹតសូន្យឈឹងនៃអំពើស៊ីរិក វាបានជំរុញអោយឃើញប្រការល្អនៅក្នុងខ្លួនរបស់ពួកយើង ថែមទាំងពង្រឹងក្នុងចិត្តនូវគោលជំនឿនិងកិច្ចប្រតិបត្តន៏អំពើល្អទៀតផង។

**ហ្វើរ៉ោះ:** ពួកយើងត្រូវនិយាយពីប្រវត្តិរបស់ហ្វើរ៉ូក(អ៊ូម៉ើរ)នៅពេលនេះ ។

**ម៉ាស់ម៉ូដៈ**នោះគឺអ៊ូម៉ើរកូនខត្តប ជាថ្នាក់ដឹកនាំកំពូលទីពីរដែលឆ្លាតវៃ។

**ហ្សីយ៉ាដៈ** អ៊ូម៉ើរកូនខត្តបកើតចេញពីអំបូរអាត់ឌី។ អំបូរនេះគឺជាអ្នកដែលគ្រប់គ្រងផ្នែកការទូត និងតុលាការក្នុងសម័យជើហ៊ីលីយ៉ាស់ (សម័យចុងក្រោយរបស់អ៊ីសើនិងមុនមូហាំម៉ាត់កើតជារ៉ស៊ូល)។ ជីតារបស់លោកឈ្មោះនូហៃ្វ កូនអាប់ឌុលអាហ្សើ។ ជីតាអ៊ូម៉ើរនេះហើយដែលធ្លាប់កាត់ក្តីអោយលោកអហ្ពូតលិបឈ្នះក្តីលើលោកហ្គើរបកូនអ៊ូម៉ៃយ៉ះ ពេលដែលអ្នកទាំងពីរប្រលងប្រជែងគ្នាធ្វើជាអ្នកដឹកនាំរបស់អារ៉ាប់គូរ៉ៃស៏។

**ហ្សីយ៉ាដៈ** ទុកអោយខ្ញុំនិយាយប្រាប់ពួកអ្នកម្តង។ ដឹងទេ តើរ៉ស៊ូលុលឡោះនិយាយយ៉ាងដូចម្តេចពីរឿងអ៊ូម៉ើរ? រ៉ស៊ូលុលឡោះបានមានប្រសាសន៏ថាៈ ខ្ញុំមិនដែលឃើញមនុស្សអស្ចារ្យដូចម្នាក់នេះ(អ៊ូម៉ើរ) ដែលនាំមកនូវភាព



ប្លែកៗនោះទេ។

## អ៊ូម៉ើរក្នុងសម័យជើហ៊ីលីយ៉ះ

**ម៉ាស់មូដ :** ឥឡូវនេះពួកយើងត្រូវស្វែងយល់ពីបុគ្គលអ៊ូម៉ើរ ទាំងមុននិងក្រោយពេលចូលកាន់សាសនាអ៊ីស្លាមរបស់លោក។

## ត្រកូលនិងភាពថ្កុំថ្កើងរបស់អ៊ូម៉ើរ

**សើម៉ាស់:** អ៊ូម៉ើរកូនអាល់ខត្តប អាល់ខត្តបកូននូហៃ្វ នូហៃ្វកូនអាប់ឌុលអាហ្សើ។អាប់ឌុលអាហ្សើ គឺជាអ្នកជំនួញដ៏ល្បីល្បាញម្នាក់ក្នុងចំណោមអ្នកល្បីៗរបស់អារ៉ាប់គូរ៉ៃស៏។ លោកក៏ជារាជទូតរបស់អារ៉ាប់គូរ៉ៃស៏ទទួលបន្ទុកផ្នែកសិកសង្គ្រាម ផ្នែកចចារនិងជាតុលាការផងដែរ។

**អះម៉ាត់ :** នៅពេលដែលអល់ឡោះជ្រើសតាំងមូហាំម៉ាត់ជារ៉ស៊ូលសំរាប់ការចង្អុលបង្ហាញនិងនាំមកនូវសាសនាពិតនោះ អ៊ូម៉ើរធ្លាប់ជាបុគ្គលម្នាក់ធ្វើទុក្ខបុកម្នេញដល់អ្នកមានជំនឿ។ លោកធ្លាប់ធ្វើបាបដល់ខ្ញុំបំរើស្រីរបស់អំបូរមុមិល ដែលក្រោយមកអាហ្ពូហ្គើកើរបានទិញខ្ញុំបំរើនោះនិងបានដោះលែងអោយមានសេរីភាពវិញ។ អ៊ូម៉ើរមានមាឌធំរឹងមាំ ចិត្តឆេវឆាវ ឆាប់ខឹងចូលចិត្តការសប្បាយនិងចូលចិត្តគ្រឿងស្រវឹង។ លោកធ្លាប់យកផ្លែល្មើធ្វើជារូបសំណាកអ្នកខ្លាំងពូកែណាម្នាក់សំរាប់ជាទីសក្ការៈ តែពេលលោកឃ្លានលោកក៏បេះផ្លែល្មើនោះហូបអស់ទៅ។

**កូនចៅម៉ះម៉ូដះ**សើចក្អាកក្អាយរួចនិយាយថា:" ការស្អាតស្អំរបស់អល់ឡោះ ដែលគ្មានអ្វីមួយប្រដូចនឹងទ្រង់បានឡើយ ។

**ហ៊ូសាមៈ** ឥឡូវនេះ ខ្ញុំចង់ដឹងពីប្រវត្តិនៃការចូលកាន់សាសនាអ៊ីស្លាមរបស់អ៊ូម៉ើរ ?

## ប្រវត្តិការចូលកាន់សាសនាអយអ៊ីស្លាមរបស់អ៊ូម៉ើរ

**ម៉ាស់ម៉ូដះ** នៅពេលអ្នកមានជំនឿនឹងមូហាំម៉ាត់បានធ្វើដំណើរទៅកាន់ទឹកដីហាហ្គើសះ(ប្រទេសអេចូពីពេលបច្ចុប្បន្ន)ជាលើកដំបូងនោះធ្វើអោយការងារនោះកាន់តែបន្ថែមទំងន់មកលើអ៊ូម៉ើរខ្លាំងឡើងៗរហូតដល់អ៊ូម៉ើរប្តេជ្ញាថានឹងសំលាប់មូហាំម៉ាត់ព្រមទាំងពួកអ្នកមានជំនឿនឹងលោកទាំងអស់ចោល ។ ពេលមួយលោកណាអ៊ីមកូនអាប់ឌុលឡោះបានជួបអ៊ូម៉ើរក្នុងពេលកំពុងធ្វើដំណើរ ។ ណាអ៊ីមបានសួរថា តើអ៊ូម៉ើរទៅណា?អ៊ូម៉ើរឆ្លើយថា:"ខ្ញុំកំពុងដើររកមូហាំម៉ាត់និងពួកអ្នកមានជំនឿនឹងមូហាំម៉ាត់ដើម្បីសំលាប់"។ ពេលនោះណាអ៊ីមបានតបវិញថា:អ្នកកំពុងតែកុហកខ្លួនឯងហើយ ព្រោះប្អូនស្រីរបស់អ្នកនិងប្តីនាងបានចូលកាន់សាសនាដូចមូហាំម៉ាត់អស់ហើយ ។

**ហ្វាទីម៉ះ:** តើនរណាជាប្អូនស្រីបង្កើតរបស់អ៊ូម៉ើរនោះ?

**ណាជា :** គឺហ្វាទីម៉ះកូនស្រីរបស់លោកអាល់ខត្តប ដែលនាងបានចូលកាន់សាសនាអ៊ីស្លាមតាំងពីសាសនានេះចាប់បដិសន្ធិនាសម័យមូហាំម៉ាត់មកម្លេះ ហើយប្តីរបស់នាងគឺលោកសើអ៊ីដកូនហ៊ៀត ហ៊ៀតកូនអាំរូ អាំរូកូនន្នូហ្វៃល៍



ដែលលោកគឺជាបុគ្គលម្នាក់ក្នុងចំណោមជនទាំងដប់នាក់ដែលរ៉ស៊ូលុលឡោះបានផ្តល់ដំណឹងរីករាយដល់ពួកគេគឺជាអ្នកដែលត្រូវចូលឋានសួគ៌ ។

**ឪពុកៈ** មិនយូរទេ ពួកយើងនឹងបានឃើញពន្លឺអ៊ីស្លាម ដែលវានឹងឆ្លុះបញ្ចាំងទៅលើចិត្តនិងសតិបញ្ញារបស់អ៊ូម៉ើរ ពោលគឺបញ្ចេញលោកពីភាពងងឹតសូន្យឈឹងនៃសម័យជើហ៊ីលីយ៉ះទៅកាន់រស្មីនិងភាពរឹងមាំរបស់អ៊ីស្លាមវិញ ។

**ម៉ាស់ម៉ូដះ** អ៊ូម៉ើរបានធ្វើដំណើរឆ្ពោះទៅកាន់ផ្ទះប្អូនស្រីរបស់ខ្លួនប្រកបដោយការខឹងសម្បារយ៉ាងខ្លាំងស្ទើរតែគ្រប់គ្រងខ្លួនឯងលែងបាន ។ ពេលចូលដល់ផ្ទះរបស់នាងក៏បានឃើញមនុស្សមួយក្រុមដែលនៅទីនោះជាមួយនាង និងប្តីរបស់នាងដែលពួកគេកំពុងសូត្រអាល់គួរអាន ដោយសភាពភ័យខ្លាចពីអ៊ូម៉ើរនិងពពួកគូរ៉ៃស៊ី ។ ពេលអ៊ូម៉ើរចូលទៅ លោកក៏ទះកំផ្លៀងប្អូនស្រីខ្លួន និងវាយប្អូនថ្លៃរហូតដល់លត់ជង្គង់ចុះ តែពេលអ៊ូម៉ើរបានឃើញឈាមលើផ្ទៃមុខប្អូនលោកមានការអាណិតហើយដើរចូលទៅជិតនាងពេលនោះកំហឹងរបស់អ៊ូម៉ើរបានរលាយបាត់រួចលោកបាននិយាយទាំងអារម្មណ៍ធូរស្រាលថា: សូមបង្ហាញបងនូវក្រដាស(អាល់គួរអាន)ដែលនៅនឹងប្អូនមើល ។ តែនាងបានប្រកែកមិនព្រមផ្តល់អោយទេ លុះត្រាតែអ៊ូម៉ើរយកទឹកវូហ្ទុ និងជំរះសំអាតខ្លួនជាមុនសិន ពីព្រោះថាអាល់គួរអានមិនអាចប៉ះវាបានទេលុះត្រាតែអ្នកជ្រះស្អាតពីហាឌើស(ត្រូវមានវូហ្ទុ) អ៊ូម៉ើរយល់ព្រម ។ លោកក្រោកឈរឡើងរួចងូតទឹកជំរះសំអាតខ្លួន ពេលនោះនាងបានហុចអាល់គួរអាននោះអោយអ៊ូម៉ើរលោកក៏ចាប់ផ្តើមអានវា ។

**ហ៊ូសាមៈ**អ៊ូម៉ើរបានសូត្រអាល់គួរអាននៅក្នុងក្រដាសនោះត្រង់បន្ទូលរបស់អល់ឡោះដែលមានន័យថាៈ (តហ៊ើ) យើង(អល់ឡោះ) មិនបានបញ្ចុះអាល់គួរអានលើរូបអ្នក(មូហាំម៉ាត់) ដើម្បីអោយអ្នកលំបាកនោះទេ តែដើម្បីក្រើនរំលឹកដល់អ្នកដែលកោតខ្លាច។ អាល់គួរអានបញ្ចុះមកពីអ្នកដែលបានបង្កើតផែនដីនិងមេឃដ៏ខ្ពង់ខ្ពស់។ ម្ចាស់ដ៏មហាសប្បុរសនៅលើអារ៉ស្យ" ។ ពេលនោះអ៊ូម៉ើរ មានការចាប់អារម្មណ៏ក្នុងជំនឿចំពោះអល់ឡោះ ដោយលោកបានលាន់មាត់ថាពាក្យពេចន៏ (សំដីរបស់អល់ឡោះ) នេះល្អនិងថ្លៃថ្នូរណាស់! លោកបានលើកអាល់គួរអានមកថើបរួចនិយាយថាៈវាក្យខណ្ឌទាំងនេះគឺមិនប្រើបុគ្គលណាម្នាក់អោយយកម្ចាស់ណាផ្សេងដែលត្រូវគេគោរពធ្វើជាម្ចាស់ជាមួយអល់ឡោះឡើយ។ សូមប្រាប់ ខ្ញុំមកមូហាំម៉ាត់នៅឯណា?" ។

**អះម៉ាត់ៈ** អ៊ីស្លាមបានចូលក្នុងចិត្តគំនិតនិងបញ្ញាញាណរបស់អ៊ូម៉ើរតាមរយៈនេះ។ លោកបានធ្វើដំណើរទៅរករ៉ស៊ូលុលឡោះ ដើម្បីប្រកាសពីគោលជំនឿនឹងអល់ឡោះម្ចាស់ដែលខ្លាំងពូកែបំផុតរបស់លោកនិងការទទួលស្គាល់រ៉ស៊ូលដ៏ថ្កុំថ្កើងជាងគេគឺមូហាំម៉ាត់ដោយហ៊ានប្តេជ្ញាថាៈ ខ្ញុំសូមធ្វើសាក្សីថាគ្មានទេម្ចាស់ដែលត្រូវគេគោរពដ៏ពិតប្រាកដក្រៅពីអល់ឡោះ ហើយខ្ញុំសូមទទួលស្គាល់ថា មូហាំម៉ាត់ជារ៉ស៊ូលរបស់អល់ឡោះ " ។

**ណាដាៈ** លោកខហ្ពើបអាល់អារទីធ្លាប់បាននិយាយប្រាប់ខ្ញុំថា ប្រាកដណាស់រ៉ស៊ូលុលឡោះបានបួងសួងសុំពីអល់ឡោះអោយជួយពង្រឹងអ៊ីស្លាមតាមរយៈអាំរូកូនហ៊ូសាមឬអ៊ូម៉ើរកូនខត្តប។



## អ៊ូម៉ើរប្រកាសពីការចូលអ៊ីស្លាមរបស់លោក

**ហ៊ូសាម ៈ** អ៊ូម៉ើរដើរជុំវិញមេកទ្រាញគូរ៉ៃស៏ព្រមទាំងប្រកាសថាៈ"ខ្ញុំបានចូលកាន់សាសនាអ៊ីស្លាមហើយ ខ្ញុំសូមធ្វើសាក្សីថាៈ គ្មានទេម្ចាស់ដែលត្រូវគេគោរពដ៏ពិតប្រាកដក្រៅពីអល់ឡោះហើយខ្ញុំសូមទទួលស្គាល់ថាមូហាំម៉ាត់ពិតជាខ្ញុំបំរើនិងជារ៉ស៊ូលរបស់អល់ឡោះ។

**ហ៊ូដាៈ** អ្នកចូលអ៊ីស្លាមក៏កើនឡើងដោយសារការចូលអ៊ីស្លាមរបស់អ៊ូម៉ើរនិងហាំហ្ស៊ះកូនអាប់ឌុលមូតល់លិបដែលត្រូវជាមារបស់មូហាំម៉ាត់។ហាំហ្ស៊ះបានចូលអ៊ីស្លាមមុនអ៊ូម៉ើរប្រហែលជាបីថ្ងៃប៉ុណ្ណោះ។ ការចូលអ៊ីស្លាមរបស់អ្នកទាំងពីរបានធ្វើអោយអ៊ីស្លាមរឹងមាំ មានពរជ័យនិងប្រកបដោយការការពារយ៉ាងពេញទំហឹង។

**ហ៊ើជើរៈ** ខ្ញុំធ្លាប់បានដឹងថា អាប់ឌុលឡោះកូនម៉ាសអ៊ូដបាននិយាយថា ពួកយើងបានរឹងមាំចាប់ពីពេលដែលអ៊ូម៉ើរចូលកាន់សាសនាអ៊ីស្លាមមក ហើយការចូលអ៊ីស្លាមរបស់គាត់ជាការបើកច្រកមួយ ការបំលាស់ទីរបស់គាត់ជាជំនួយមួយ និងកាគ្រប់គ្រងរបស់គាត់ជាពរជ័យមួយ។ មុនការចូលអ៊ីស្លាមរបស់អ៊ូម៉ើរ ពួកយើងមិនអាចសឡាហ៏ក្នុងម៉ាស្ជិតហារ៉ម(ម៉ាស្ជិតដែលព័ទ្ធជុំវិញកាក់បា្ពះ) បានឡើយ។

**មូហាំម៉ាត់** ៈពួកយើងបានជជែកគ្នាតាំងពីដើមមេរៀនមកម្លេះថា អ៊ូម៉ើរបានត្រូវគេអោយនាមថា "ហ្វើរ៉ូក" តើវាមានន័យយ៉ាងដូចម្តេច? តើនរណាជា

អ្នកប្រសិទ្ធិនាមនេះអោយលោក?

**អាប់ឌុរ៉ស់ម៉ាន:** គឺណាហ្វីមូហាំម៉ាត់ជាអ្នកប្រសិទ្ធិនាមនេះឱ្យលោក។ នាមនេះមានន័យថា: អ្នកបែងចែករវាងខុសនិងត្រូវ ពីព្រោះថាការចូលសាសនាអ៊ីស្លាមរបស់គាត់អល់ឡោះបានបង្ហាញពីរការបែងចែករវាងខុស និងត្រូវដល់លោក។ ការបំលាស់ទីរបស់អ៊ូម៉ើរអារ៉ាប់គូរ៉ែស៏បានធ្វើទុក្ខបុកម្នេញដល់អ្នកកាន់សាសនាអ៊ីស្លាម និងបានធ្វើការហាមឃាត់ពួកគេមិនអោយធ្វើបំលាស់ទីឡើយ។ ដោយឡែកសំរាប់អ៊ូម៉ើរវិញលោកបានស្ពាយដាវ និងធ្នូចូលទៅកាន់កាក់បួះ និងជួបមេកន្រ្ទាញម៉ាក្កះដែលនៅជុំវិញកាក់បួះ។ លោកបានដើរជុំវិញកាក់បួះ៧ ជុំរួចលោកសឡាហ៏ ២រ៉កើអាហ៏ ខាងក្រោយម៉ាកមអ៊ីប៉រហ៊ីមបន្ទាប់មកលោកដើរទៅជួបមេកន្រ្ទាញម៉ាក្កះម្តងមួយ១ ដោយលោកបាននិយាយទៅកាន់ពួកគេថា: "បុគ្គលណាហើយចង់បែកម៉ែបែកឪចង់អោយកូនរបស់ពួកគេក្លាយជាក្មេងកំព្រា ឬចង់អោយប្រពន្ធរបស់ពួកគេក្លាយជាស្រ្តីមេម៉ាយ អញ្ជើមកជួបខ្ញុំខាងក្រោយអូរនេះ! តែគ្មានបុគ្គលណាម្នាក់ហ៊ានមកតាមលោកឡើយ។

**អះម៉ាត់:** អ៊ូម៉ើរបានចូលរួមតស៊ូក្នុងសង្គ្រាមជាច្រើន។

## អ៊ូម៉ើរជាអ្នកចាប់ផ្តើមមុនគេ

**ហ៊ូសាម:** អ៊ូម៉ើរកូនខត្តបជាមនុស្សដំបូងគេក្នុងការ :

- ប្រើអោយបញ្ជីរសឡាហ៏តារ៉ាវេសជាក្រុម។



- រំដោះប្រទេសអ៊ីរ៉ាក់ទាំងមូលតំបន់ជើហ្ស៊ីរ៉ោះ តំបន់អេហ្ស៊ីប និងតំបន់អាសកាន់ដារី។
- បង្កើតអោយមានការកត់ត្រាកាលបរិច្ឆេទជាមូហាំម៉ាត់សករាជ។
- ចងក្រងច្បាប់គ្រប់គ្រងផ្សេង១។
- តែងតាំងតុលាការនៅតាមតំបន់ផ្សេង១ និងបន្ថែមនៅម៉ាស្ជិតណាហ្វី។
- បានប្រគល់កូនសោរម៉ាស្ជិតអុកស( នៅប៉ាឡេស្ទីន) ។
- បានដឹកនាំមនុស្សទៅធ្វើហាជ្ជី ១០ឆ្នាំ ។

## ភាពយុត្តិធម៌របស់អ៊ូម៉ើរ

**ហ៊ើរជើរ :** ថ្ងៃមួយមានជនជាតិអេហ្ស៊ីបម្នាក់បានមកជួបថ្នាក់ដឹកនាំកំពូលអ៊ីស្លាមគឺអ៊ូម៉ើកូនខត្តបដើម្បីប្តឹងពីអាំរូកូនអាស និងកូនប្រុសរបស់គាត់ឈ្មោះមូហាំម៉ាត់ដោយលោកបានបញ្ជាក់ប្រាប់អ៊ូម៉ើរថា:ពេលមួយនោះ សេះរបស់ខ្ញុំបានរត់ ពេលសេះរត់មកដល់ជិតជនជាតិអេហ្ស៊ីបនោះ មូហាំម៉ាត់ កូនអាំរូបានចាប់សេះគាត់ទុក។ ជនជាតិអេហ្ស៊ីបនោះ បានប្រាប់មូហាំម៉ាត់ថា: "នេះជាសេះរបស់ខ្ញុំទេ ។ពេលនោះមូហាំម៉ាត់បានក្រោកឈរវាយជនជាតិអេហ្ស៊ីបនោះនឹងខ្សែតីព្រមទាំងបាននិយាយថា: យកវាទៅវិញទៅព្រោះខ្ញុំជាកូនអ្នកខ្ពង់ខ្ពស់ម្នាក់។ ពេលអ៊ូម៉ើរបានដឹងពីរឿងនេះលោកបានបញ្ជាអោយគេបញ្ជូនអាំរូកូនអាស និងកូនប្រុសរបស់លោកមកពីអេហ្ស៊ីប។ លុះពេលមកដល់

អ៊ូម៉ើរ បានហៅជនជាតិអេហ្ស៊ីបនោះមកព្រមទាំងអោយខ្សែតីទៅគាត់រួចប្រើអោយវាយទៅលើ មូហាំម៉ាត់ដោយអ៊ូម៉ើរ បាននិយាយថា: ចូរឯងវាយកូនអ្នកថ្កុំថ្កើងភ្លាមរួចលោកប្រើអោយវាយទៅលើ អាំរូ ផងដែរ តែជនជាតិអេហ្ស៊ីបនោះបានតបទៅអ៊ូម៉ើរថា:"ខ្ញុំសូមទោស ខ្ញុំវាយតែនរណាវាយខ្ញុំប៉ុណ្ណោះ"។ អ៊ូម៉ើរសំលឹងមើលទៅអាំរូ រួចនិយាយថា:តើពួកអ្នកបញ្ជាអោយគេគោរពចាប់ពីពេលណាមក! ។ មនុស្សលោកទាំងអស់កើតមកតាមរយៈម្ដាយរបស់គេជាបុគ្គលដែលមានសេរីភាព!"។

**ហ៊ូសាម :** នេះជាច្បាប់សំរាប់ការរស់នៅហើយវាជាមាគ៌ារបស់ប្រជាពលរដ្ឋអ៊ីស្លាមដែលគេត្រូវតែលើកតំកើងមនុស្សជាតិ ហើយនិងរក្សាគោលជំនឿរបស់ពួកគេ។ អ៊ីស្លាមដែលត្រូវតំកើងក្នុងនាមជាកូនចៅអាដាំ ហើយគោលជំនឿរបស់គេរៀងៗខ្លួនត្រូវបានគេថែរក្សា។

**ហ៊ូដា :** អ៊ូម៉ើរបានចាត់ចែងអោយមានគោលនយោបាយដល់អ្នកគ្រប់គ្រងតាមតំបន់របស់អ៊ីស្លាមសំរាប់ដោះស្រាយជីវភាពបានគ្រប់គ្រាន់។

**ម៉ាស់ម៉ូដ:** ខ្ញុំបានដឹងថា អ៊ូម៉ើរអនុគ្រោះ ដោយមិនយកប្រាក់ពន្ធចំពោះជនដែលគ្មានលទ្ធភាពបង់ក្នុងចំណោមពួកដែលសុំជ្រកកោន ក្នុងប្រទេសអ៊ីស្លាមមិនតែប៉ុណ្ណោះ លោកថែមទាំងផ្ដល់អោយពួកគេនូវអ្វី ដែលលោកមានទៀតផង។ ក្ដីមេត្តាបេស់ថ្នាក់ដឹកនាំកំពូលនិងការអាណិតស្រលាញ់មកលើថ្នាក់ដឹកនាំក្រោមបង្គាប់។



**អះម៉ាត់:** ថ្ងៃមួយអ៊ូម៉ើរបានធ្វើដំណើរទៅប្រទេសស្ហាមនៅពេលនោះលោកបានជួបមនុស្សជាច្រើន ដែលពួកគេមកប្ដឹងពីថ្នាក់ដឹកនាំតាមតំបន់របស់ពួកគេគឺលោកសើអ៊ីដ កូនអាមៀរអាល់ជុមហ៊ុ ដោយពួកគេបានប្ដឹងថា: លោកសាអ៊ីដមិនបានចេញមកជួបពួកគេទេទាល់តែថ្ងៃរះខ្ពស់ និងមិនបានបំពេញតាមសំណូមពររបស់ពួកយើងនៅពេលយប់ឡើយមិនតែប៉ុណ្ណោះគាត់តែងតែអវត្តមានពីពួកយើងពេញមួយថ្ងៃរៀងរាល់ខែ។អ៊ូម៉ើរបានកោះអញ្ជើញលោកសាអ៊ីដ អោយមានវត្តមាននៅចំពោះមុខមហាជនទាំងអស់។ សាអ៊ីដ បាននិយាយថា:"ខ្ញុំសូមស្បថនឹងអល់ឡោះថាខ្ញុំមិនបានគេចចេញពីពួកគេទេព្រោះតែខ្ញុំរវល់ត្រាំម្សៅនំប៉័ងហើយរង់ចាំរហូតដល់វាឡើងជូ បន្ទាប់មកខ្ញុំដុតនំប៉័ងរួចយកវូហ្ទុ( ការសំអាតខ្លួនមុនធ្វើការគោររពសក្ការៈចំពោះអល់ឡោះម្ចាស់) ក្រោយមកខ្ញុំចេញទៅរកពួកគេ។ ចំនែកឯការមិនដោះស្រាយអោយពួកគេនៅពេលយប់ព្រោះខ្ញុំមិនចូលចិត្តសញ្ជឹងគិត ពីមូលហេតុនៅពេលយប់នោះទេតែខ្ញុំនឹងរំលឹកវានៅពេលថ្ងៃវិញ និងដោយសារខ្ញុំយកពេលថ្ងៃសំរាប់ការដោះស្រាយអោយពួកគេ ដោយឡែកពេលយប់សំរាប់អល់ឡោះម្ចាស់ ពោលគឺខ្ញុំបន្ថែមការគោរពសក្ការៈចំពោះទ្រង់នៅពេលយប់។ ចំណែកឯការអវត្តមានរបស់ខ្ញុំមួយថ្ងៃក្នុងមួយខែគឺថ្ងៃនោះខ្ញុំបោកសំលៀកបំពាក់របស់ខ្ញុំ ហើយរង់ចាំវាស្ងួត។ អ៊ូម៉ើរពោលឡើងថា: រាល់ការសរសើរគឺសំរាប់អល់ឡោះម្ចាស់ដែលមិនធ្វើអោយអស់សង្ឃឹមចំពោះការយល់ដឹងជ្រៅជ្រះរបស់ខ្ញុំមកលើរូបអ្នក។

**ម៉ាស់ម៉ូដះ** ការយល់ដឹងជ្រៅជ្រះ វាជាជំនាញមួយដែលអាចប្រមើលដឹងកិច្ចការទាំងក្នុងនិងក្រៅ ។

**អះម៉ាត់ :** អ៊ូម៉ើរល្បីខាងពូកែយល់ដឹងការងារអនាគត និងពូកែនិយាយ ។

**ហ៊្សុយ៉ាដ :** តើអ្នកនិយាយថាម៉េចអម្បាញ់មិញ? ពូកែយល់ដឹងឆ្ងាយ? សូមជួយពន្យល់ប្រាប់ផង?

**អះម៉ាត់ះ** រឿងនេះទាក់ទងនឹងហាហ៊្ទីសនិយាយពីការពូកែដឹងឆ្ងាយដែលឈ្មោះនេះត្រូវបានសាសនវិទូផ្នែកហាហ៊្ទីសអោយនិយមន័យយ៉ាងនេះ ។

**អ៊ីស្លាម :**ឈប់សិន ! មុនពេលអ្នកបកស្រាយនិងផ្តល់ចំលើយនៃពាក្យពូកែដឹងឆ្ងាយនោះ សូមទុកឱកាសអោយខ្ញុំបន្ថែមបន្តិចសិន ។ នោះគឺទាក់ទងនឹងបុគ្គលអ៊ូម៉ើរតែម្តង នៅថ្ងៃមួយលោកបានថ្លែងសន្ទរកថា ថ្ងៃសុក្រក្នុងពេលមនុស្សម្នា កំពុងត្រងត្រាប់ស្តាប់ស្រាប់តែលោកស្រែកខ្លាំងៗថាៈ ក្បួនទ័ពទាំងអស់ភ្នំ!ភ្នំ! (មានន័យថា ចូរពួកអ្នកគេចខ្លួនទៅរកភ្នំភ្លាមដើម្បីគេចចេញពីមុខសត្រូវដែលតាមមកពីខាងក្រោយពួកអ្នក) ។ បន្ទាប់មកលោកវិលមកនិយាយបំពេញសុន្ទរកថារបស់លោកវិញ រួចក៏សឡាហ៏ធ្វើជាអ៊ីមុាំ (ជាអ្នកនាំមុខគេ) ។ ក្រោយពីសឡាហ៏ចប់លោកអាលីបានសួរអូម៉ើរថាៈ"ពួកយើងទាំងអស់គ្នាបានលឺលោកស្រែកខ្លាំងៗថាៈ"ក្បួនទ័ពទាំងអស់ភ្នំ!ភ្នំ! " ពេលនោះអ៊ូម៉ើរបានសួរអាលីថា អ្នកលឺខ្ញុំស្រែកអញ្ចឹងមែនឬ? អាលីឆ្លើយថាៈ "អ្នកនៅក្នុងវិហារទាំងអស់បានលឺលោកស្រែក!" ។ អ៊ូម៉ើរបានពន្យល់ថាៈ"ខ្ញុំបានមើលឃើញពពួកមូសរិគីន(ពួកពហុទេពនិយម) បានងាកមកឡោមព័ទ្ធ



ទ័ពមូស្លីមពួកនោះស្ទើរតែកំទេចទ័ពមូស្លីមទៅហើយ ។ ពេលនោះទ័ពមូស្លីមកំពុងដើរឆ្លងកាត់ភ្នំ ។ បើពេលនោះទ័ពមូស្លីមងាកមកប្រឈមនឹងពួកនោះច្បាស់ជាមានជ័យជំនះ ។ ផ្ទុយទៅវិញបើទ័ពមូស្លីមបោះបង់វិញ ច្បាស់ជាពួកមូសរិគីនកំទេចមិនខាន ។ ពេលនោះខ្ញុំក៏ស្រែកប្រាប់ថាៈ"ភ្នំ ! ភ្នំ! " ។

**ហ៊្សុយ៉ាដះ** តើក្បួនទ័ពបានលឺការស្រែកនោះដែរឬទេ? បើចំងាយវាឆ្ងាយពីគ្នាយ៉ាងនេះ?

**អ៊ីស្លាម :** បាទ! ពួកគេបានលឺ ពីព្រោះក្រោយព្រឹត្តិការណ៏មួយខែ លោកហ្មើសៀវបានមក ហើយលោកបាននិយាយថា : កងទ័ពបានលឺសំលេងស្រែកប្រាប់ថាៈក្បួនទ័ពភ្នំ!ភ្នំ! ពេលនោះពួកយើងបានងាកទៅរកភ្នំ ។ អល់ឡោះបានអោយពួកយើងមានជ័យជំនះតែម្តង ។

**ហ៊ូសាមៈ** បងប្អូនទាំងអស់! ខ្ញុំយល់ហើយន័យរបស់វាមិនចាំបាច់ពន្យល់បកស្រាយប្រាប់លំអិតនៃពាក្យពូកែដឹងឆ្ងាយទៀតឡើយ ។

**ម៉ាស់ម៉ូដះ** បងប្អូនទាំងអស់! អ្នកយល់តែអ្នកផ្សេងពីអ្នកគេមិនទាន់បានយល់ច្បាស់នៅឡើយទេ ។ ដូចនេះកុំប្រញាប់ពេក ។

**អះម៉ាត់ះ** មិនថ្វីទេ! ខ្ញុំនឹងពន្យល់ប្រាប់អ្នកអោយបានច្បាស់គឺពួកអ្នកសាសនវិទូផ្នែកសោតវិញ្ញាណមនុស្សពេលបច្ចុប្បន្ននេះ បាននិយាយថាពាក្យពូកែដឹងឆ្ងាយគឺមានន័យថាៈ "ការបង្ហាញប្រការអាថិកំបាំងវាមានន័យថាញាណដឹងពីចំងាយដូចមានបញ្ជាក់នៅក្នុងហាហ៊្ទីសខាងលើស្រាប់" ។

**ហ្ស៊ីយ៉ាដ :** សំលាញ់! ខ្ញុំពិតជាចំឡែកចិត្តនឹងញាណដឹងរបស់អ៊ូម៉ើរ មានភាពខ្លាំងក្លា។ ញាណដឹងទាំងនេះវាពិតជាចំឡែកមែនទែន។

**អ៊ីស្លាម :**អ្នកពណ៌នាពីញាណដឹងរបស់អ៊ូម៉ើរថាប្លែក រ៉ស៊ូលុលឡោះបានមានប្រសាសន៍ប្រាប់ហើយថា:" ចូរពួកអ្នកកោតខ្លាចញាណដឹងរបស់អ្នកកោតខ្លាចអល់ឡោះពិតណាស់គេអាចប្រមើលឃើញដោយពន្លឺបង្ហាញពីអល់ឡោះជាម្ចាស់។

**ហ្ស៊ីយ៉ាដ:** ត្រឹមត្រូវណាស់ប្រសាសន៍របស់រ៉ស៊ូលុលឡោះ។

## ក្ដីមេត្តារបស់អ៊ូម៉ើរ

**ហ្វាទីម៉ះ :** ឥឡូវនេះពួកយើងគួររំលឹកដល់ក្ដីមេត្តារបស់អ៊ូមើរ។

**ណាដា :** ត្រឹមត្រូវណាស់គ្មានអ្វីត្រូវសង្ស័យឡើយ។ នៅយប់មួយអ៊ូម៉ើរដើរល្បាតស្វែងយល់ពីសភាពនៃអ្នកនៅក្រោមឱវាទរបស់ខ្លួន។

**ហ្វាទីម៉ះ:**ពិតជាអញ្ចឹងមែន! ពេលមួយមានអ្នកចំណូលថ្មីមកទីក្រុងម៉ាឌីណះ ពួកគេបានបោះជំរុំនៅទីនោះ។ តាមទំលាប់របស់អ៊ូម៉ើរតែងតែដើរល្បាតនៅពេលយប់ដើម្បីស្វែងយល់ពីសភាពប្រជាជនរបស់លោក។ ពេលនោះលោកបានលឺសំលេងក្មេងយំ ។លោកក៏និយាយទៅកាន់ម្ដាយក្មេងនោះថា:"សូមអ្នកស្រីលួងវាផង?"ស្ត្រីនោះបានតបមកអ៊ូម៉ើរវិញថា: ខ្ញុំផ្ដាច់ដោះវាព្រោះថ្នាក់ដឹកនាំកំពូល(អ៊ូម៉ើរ) មិនផ្គត់ផ្គង់ពួកយើងនោះទេលើកលែងតែ ក្មេង១ណាដែលគេផ្ដាច់ដោះហើយប៉ុណ្ណោះ។ លោកអាប់ឌុររ៉ស់ម៉ាន កូនអោហ្វបាន



និយាយថា: ពេលអ៊ូម៉ើរសឡាហ៍ស៊ូហ្គះលោកយំយ៉ាងខ្លាំងបន្ទាប់មកលោកចេញដំណើរទៅដោយពោលពាក្យថា:អ៊ូម៉ើរ តើក្មេងប៉ុន្មាននាក់ហើយដែលអ្នកបានសំលាប់!។ ក្រោយមកលោកបានប្រកាសបញ្ជានៅក្នុងហ្វូងមនុស្សថាពួកអ្នកទាំងអស់គ្នាមិនត្រូវប្រញាប់ក្នុងការផ្ដាច់ដោះកូនរបស់ពួកអ្នកទេ"។ ថ្នាក់ដឹកនាំកំពូល(សំដៅលើរូបលោក)របស់ អ៊ីស្លាមសូមដាក់បទបញ្ជាថា: "ក្មេង១គ្រប់រូបត្រូវទទួលបានការផ្គត់ផ្គង់ទាំងលុយកាក់ សំលៀកបំពាក់ និងចំណីអាហារ"។

**អ៊ីស្លាម :** ចំណែកខ្ញុំវិញ នឹងពណ៌នាប្រវត្តិមួយទៀតអោយពួកអ្នកស្ដាប់។ មានថ្ងៃមួយអ៊ូម៉ើរបានចូលទៅជួបអាប់ឌុលឡោះកូនរបស់លោក។ពេលនោះលោកបានឃើញកូនកំពុងទទួលទានសាច់មួយដុំ។ អ៊ូម៉ើរខឹងយ៉ាងខ្លាំង រួចនិយាយថា:"កូនជាកូនរបស់ថ្នាក់ដឹកនាំអ៊ីស្លាមកំពូលម្នាក់កូនទទួលទានសាច់ឬ? លោកក៏ប្រើអោយអាប់ឌុលឡោះទទួលទាននំប៉័ងនិងប៊ឺវិញ។

**អាប់ឌុររ៉ស់ម៉ាន:** អ្នកបានពណ៌នារឿងចំណីអាហារ តែខ្ញុំនឹងនិយាយប្រវត្តិមួយផ្សេងទៀតប្លែកនិងអស្ចារ្យ។ គេបានពណ៌នាថា: មានថ្ងៃមួយអ៊ូម៉ើរបានចូលទៅក្នុងផ្សារក្នុងបំណងត្រួតពិនិត្យមើល។ លោកបានឃើញសត្វអូដ្ឋធាត់មួយក្បាល។ លោកសួរថា: វាជារបស់អ្នកណា ? ពួកគេបានឆ្លើយថាវាជារបស់អាប់ឌុលឡោះកូនអ៊ូម៉ើរ។ អ៊ូម៉ើរងាកមុខចេញប្រកបដោយការឈឺចាប់ជាខ្លាំង។ លោកបានប្រាប់អោយគេនាំអាប់ឌុលឡោះមកជួបលោក។ ពេលនោះអាប់ឌុលឡោះបានរាយរ៉ាប់ប្រាប់ឪពុកថា: " ខ្ញុំបានទិញវាដោយ

លុយកាក់របស់ខ្ញុំ រួចខ្ញុំបញ្ជូនវាអោយគេថែរក្សា ដើម្បីខ្ញុំដាក់វាលក់ដូចអ្នកមូស្លីមផ្សេងទៀតដែរ"។ ពេលនោះអ៊ូម៉ើរនិយាយទាំងខឹងថាៈ "កូនជាកូនរបស់ថ្នាក់ដឹកនាំអ៊ីស្លាមកំពូល។ កូនបានទុកវាអោយមនុស្សជួយមើលអោយឯងអញ្ចឹង (អាងខ្លួនឯងជាកូនអ្នកធំ) ! បន្ទាប់មកលោកបានប្រើអាប់ឌុលឡោះអោយយកត្រឹមអ្វីដែលគេបានចំណាយ និងសល់ប៉ុន្មានត្រូវបញ្ចូលទៅក្នុងឃ្លាំងសំភារៈរបស់អ៊ីស្លាមទាំងអស់។

◆ អាប់ឌុលឡោះកូនអ៊ូម៉ើរជាបុគ្គលម្នាក់ ដែលកោតខ្លាចអល់ឡោះបំផុតក្នុងចំណោមអ្នកកោតខ្លាចអល់ឡោះទាំងឡាយ។

**មូហាំម៉ាត់ៈ** មិនមែនតែប៉ុណ្ណឹងទេ! អ៊ូម៉ើរថែមទាំងបដិសេធក្នុងការតែងតាំងកូនរបស់លោកគឺអាប់ឌុលឡោះនូវតំណែងមួយក្នុងចំណោមតំណែងធំៗរបស់ប្រទេសទៀតផង និងបដិសេធក្នុងការដាក់ឈ្មោះកូនរបស់លោកជាជំរើសសំរាប់តំណែងកំពូលនៃអ្នកដឹកនាំអ៊ីស្លាមផងដែរ។

**ហ៊្សីយ៉ាដ :** អ្វីដែលអ្នកនិយាយគឺជាការពិត។ ថ្ងៃមួយអ៊ូម៉ើរអង្គុយជាមួយអ្នកដឹកនាំក្រោមបង្គាប់ ដើម្បីពិភាក្សាគ្នា ជុំវិញការជ្រើសរើសអ្នកគ្រប់គ្រងប្រចាំតំបន់គូហ្វះ(ឈ្មោះតំបន់មួយនៅក្នុងប្រទេសអ៊ីរ៉ាក់)។ លោកបានលើកយោបល់ថាៈខ្ញុំចង់បានអ្នកគ្រប់គ្រងរឹងមាំស្មោះត្រង់ ជាបុគ្គលម្នាក់ដែលមិនត្រូវថ្នាក់ដឹកនាំរបស់លោកសុំយោបល់ ក្នុងការជ្រើសរើសថ្នាក់ដឹកនាំប្រចាំតំបន់គូហ្វះ (ក្នុងប្រទេសអ៊ីរ៉ាក់) ខ្ញុំត្រូវការសមាសភាពមួយខ្លាំងពូកែនិង



ស្មោះត្រង់ដែលសមាសភាពមិនត្រូវបានគេប្តឹងតវ៉ាពីអ្វីមួយឡើយ។ ពេលនោះថ្នាក់ដឹកនាំទាំងអស់បានអោយយោបល់ថាៈបុគ្គលដែលលោកកំពុងស្វែងរកនោះគឺអាប់ឌុលឡោះកូនអ៊ូម៉ើរ។ ពេលនោះអ៊ូម៉ើរបានបដិសេធយ៉ាងដាច់អហំការហើយប្រើអោយជ្រើសរើសអ្នកផ្សេងវិញ។

## ជំហរយុត្តិធម៌របស់អ៊ូម៉ើរ ជាមួយអ្នកមិនមែនអ៊ីស្លាម

**ហ្វាទីម៉ះ** អ៊ូម៉ើរជាគំរូភស្តុតាងមួយក្នុងកិច្ចការយុត្តិធម៌ និងភាពឧត្តុង្គឧត្តមនោះ គឺគេអាចយកវាធ្វើជាអំណះអំណាងនៅក្នុងសាសនាអ៊ីស្លាម។ អ៊ីស្លាមជាសាសនាប្រកបដោយការយោគយល់ អាណិតស្រលាញ់ សន្តិភាព និងក្តីមេត្តា។ ប្រវត្តិរឿងមួយ គឺនៅពេលដែលគេតំរូវអោយប្រគេនអាសើគីហ្វះកូនស្រីអាល់មូកត់ទិសទៅអោយថ្នាក់ដឹកនាំដ៏កំពូល ក្រោយពីពួកគេមិនព្រមប្រគល់នាងទៅអោយអាំរូកូនអាសទេ។ ពេលនោះអាំរូបានផ្ញើសំបុត្រជូនអ៊ូម៉ើរដោយប្រាប់រឿងនេះដល់លោក។ អ៊ូម៉ើរបានមកជួបពួកគេ(បងប្អូនស្ត្រីនោះ)រួចលោកបានសរសេរកំណត់ត្រាធានាលើជីវិតពួកគេទាំងកូន ទាំងទ្រព្យសម្បត្តិ និងវិហារសាសនាគ្រឹស្ទរបស់ពួកគេគឺមិនត្រូវបំផ្លាញ ប៉ះពាល់ឬអនុញ្ញាតិអោយនរណាស្នាក់នៅឡើយ។

**សាម៉ាស់ៈ**ឱអល់ឡោះ! ជាម្ចាស់ ពិតណាស់ អ៊ីស្លាមជាសាសនាប្រកបដោយការអធ្យាស្រ័យនិងក្តីមេត្តា ទាំងនេះហើយគឺអល់ឡោះប្រើពួកយើងនៅក្នុងគម្ពីរអាល់គួរអានដ៏ថ្កុំថ្កើងនោះ។

## គ្មានការបង្ខិតបង្ខំនៅក្នុងសាសនាអ៊ីស្លាម

**អះម៉ាត់:** បងប្អូនជាទីស្រលាញ់! ចូរយើងក្រលេកមើលថ្នាក់ដឹកនាំកំពូល ដ៏យុត្តិធម៌ដែលភ្ជាប់អ៊ីស្លាម និងភាពស្មោះត្រង់ សំរាប់មនុស្សលោកទូទៅទាំងបរិស័ទអ៊ីស្លាម យ៉ាហ៊ូឌី និងណាសរ៉នី(ពួកជ្វីហ្វនិងពួកគ្រីស្ទ) ។ ថ្ងៃមួយពេលអ្នកអាហ្សាន (សូត្រធម៌អំពាវនាវមនុស្សអោយមកសឡាហ៍) បានចាប់ផ្តើមអាហ្សានសឡាហ៍។ ពេលនោះអ៊ូម៉ើរកំពុងអង្គុយក្នុងព្រះវិហារ គ្រីស្ទឈ្មោះគីយ៉ើម៉ាស់។ លោកប្រញាប់ចេញពីព្រះវិហារជាបន្ទាន់ ពេលលោកបានលឺ(សំលេងអាហ្សាន)ដើម្បីលោកសឡាហ៍ខាងក្រៅព្រះវិហារ នៅលើដីស្អាតជុំវិញព្រះវិហារនោះ។ លោកបាននិយាយទៅកាន់ហ្ពើរីកះថា: "ប្រសិនបើខ្ញុំសឡាហ៍ខាងក្នុងព្រះវិហារច្បាស់ជាពេលក្រោយមកអ្នកកាន់សាសនាអ៊ីស្លាមទាំងអស់នឹងអនុវត្តតាមបន្ទាប់ពីខ្ញុំ ហើយពួកគេច្បាស់ជាអះអាងថា អ៊ូម៉ើរធ្លាប់សឡាហ៍នៅទីនេះ(នៅក្នុងវិហារ) ។

## ថ្នាក់ដឹកនាំកំពូលដែលយុត្តិធម៌ និងលោកអាប់ហ្ពើស

**ហ្សីយ៉ាដ :** អ៊ូម៉ើរបាននិយាយទៅកាន់អាប់ហ្ពើសដែលត្រូវជាឪពុកមាររបស់ណាហ្ពីថា:វ៉ស៊ូលុលឡោះមុនពេលលោកទទួលមរណភាព លោកមានបំណងចង់ពង្រីកម៉ាស្ជិតរបស់លោក តែផ្ទះរបស់អាប់ហ្ពើសឯងវានៅជិតម៉ាស្ជិតណាស់។ ពួកយើងបានមូលមតិគ្នាថា សូមអោយលោកផ្តល់ទីតាំងនេះ ដើម្បីពួកយើងធ្វើការពង្រីកម៉ាស្ជិត។ លោកអាប់ហ្ពើសបានឆ្លើយថា: ខ្ញុំមិនយល់ព្រមទេ។ អ៊ូម៉ើរបានតបវិញថា:"អញ្ចឹងពួកយើងត្រូវយកវាទាំងបង្ខំឬ?" ។



អាប់ហ្ពើសឆ្លើយតបវិញថា: "វាមិនមែនជាសិទ្ធិរបស់អ្នកដែលត្រូវធ្វើដូចនេះទេ" ។ លោកជាថ្នាក់ដឹកនាំ! ពួកយើងត្រូវលើករឿងនេះទៅអោយលោកហ៊ូហៃហ្វះកូនអាល់យ៉ាម៉ាន់ដើម្បីកាត់ក្តី។ អ្នកទាំងពីរនាំគ្នាទៅរកលោកហ៊ូហៃហ្វះ។

**ម៉ាស់ម៉ូដ :** ឈប់សិន! ខ្ញុំមានចំនុចចាប់អារម្មណ៍គឺថា តើថ្នាក់ដឹកនាំកំពូលធ្វើដំណើរទៅជួបលោកហ៊ូហៃហ្វះ ដោយខ្លួនឯងផ្ទាល់ឬ?

**អះម៉ាត់:** ពិតហើយ! ថ្នាក់ដឹកនាំកំពូលនិងលោកអាប់ហ្ពើសបានអង្គុយទល់មុខហ៊ូហៃហ្វះ។ លោកអាប់ហ្ពើសបានលើកឡើងថា:"ខ្ញុំបានដឹងថា ណាហ្ពីដាវូដមានបំណងចង់យកដីនៅជាប់ម៉ាស្ជិតហ្ពៃទុលមឹកទិស (នៅប៉ាលីស្ទីន) ដើម្បីពង្រីកម៉ាស្ជិត ហើយដីនេះជាកម្មសិទ្ធិរបស់ក្មេងកំព្រា។ ពេលដែលគេទទូចចង់បានដីនោះ ក្មេងកំព្រាបានប្រកែកមិនព្រមប្រគល់អោយទេ។ ពេលនោះណាហ្ពីដាវូដចង់យកដីនោះទាំងបង្ខំតែអល់ឡោះបានវ៉ាហ៊ី (ប្រាប់បញ្ជា) ដល់ណាហ្ពីដាវូដនៅក្នុងបន្ទូលរបស់ទ្រង់ថា:ពិតណាស់ម៉ាស្ជិតទាំងឡាយណាដែលស្អាតស្អំពីការបំពាននោះហើយជាម៉ាស្ជិតរបស់យើង(អល់ឡោះ) ។ ពេលនោះណាហ្ពីដាវូដឈប់ទាមទាររួចទុកដីនោះអោយម្ចាស់គេវិញ។ បន្ទាប់មកលោកអាប់ហ្ពើសបានងាកមករកអ៊ូម៉ើររួចនិយាយថា: "តែសំរាប់ខ្ញុំស្រលាញ់អល់ឡោះនិងរ៉ស៊ូលរបស់ទ្រង់ ។ដូច្នេះដីនោះអ្នកយកវាសំរាប់ពង្រីកម៉ាស្ជិតចុះ

## ស្តេចតន(បិសាច)ខ្លាចអូម៉ើរ

**ហ្សីយ៉ាដ:**សំលាញ់! ខ្ញុំបានអានហាហ្ទីសមួយហើយខ្ញុំមានការភ្ញាក់ផ្អើលជាខ្លាំង!

**មូហាំម៉ាត់:** អ្នកភ្ញាក់ផ្អើលឬគេធ្វើអោយភ្ញាក់ផ្អើល?

**ហ្សុីយ៉ាដ :** សើចរួចនិយាយថា:" តាមពិត គឺទាំងពីរ ពោលគឺថាខ្ញុំបានអានហាហ្ទីសមួយដែលណាហ្គីបានមានប្រសាសន៍ទៅកាន់អ៊្លូម៉ើរថា :" ឱ! អ៊្លូម៉ើរខ្ញុំស្បថនឹងអល់ឡោះ គឺបីសាច វាគេចចេញពីផ្លូវដំណើររបស់អ្នក"។

**មូហាំម៉ាត់ :**បីសាចខ្លាចអ៊្លូម៉ើរ! គេចចេញពីផ្លូវអូម៉ើរ! ឱអល់ឡោះម្ចាស់ដ៏មហាស្អាតស្អំ!

**អះម៉ាត់ :** វាគ្មានអ្វីដែលអ្នកត្រូវភ្ញាក់ផ្អើលនោះឡើយ ពីព្រោះថា ខ្ញុំរបស់អល់ឡោះដែលស្មោះត្រង់ គឺបីសាចពុំមានអំណាចអ្វីមកលើពួកគេឡើយ។ ដូចអល់ឡោះមានបន្ទូលបញ្ជាក់ពីសំដីរបស់បីសាចថា:(ខ្ញុំនឹងលំអលោកីយ៍នេះសំរាប់មនុស្សលោក ហើយខ្ញុំនឹងធ្វើអោយពួកគេវង្វេងទាំងអស់ លើកលែងតែខ្ញុំរបស់ទ្រង់ណាម្នាក់ដែលស្មោះចំពោះទ្រង់ ក្នុងចំណោមពួកគេប៉ុណ្ណោះ។ អល់ឡោះបានមានបន្ទូលតបវិញថា:(នេះគឺមាគ៌ារបស់យើងដែលត្រឹមត្រូវ។ ពិតណាស់ឯងគ្មានអំណាចអ្វីលើខ្ញុំរបស់យើងឡើយលើកលែងតែជនណាដែលដើរតាមគន្លងរបស់ឯងគឺគេស្ថិតក្នុងចំណោមពួកវង្វេងហើយ"។

## កូនក្រមុំទន្លេនីលនិងអ៊្លូម៉ើរកូនខត្តប

**ហ៊ូសាម:** គឺអ៊្លូម៉ើរបានបញ្ជូនសំបុត្រទៅគ្រប់ទិសទី នៃទឹកដីអេហ្សុីបដ៏ស្រស់បំព្រង ដែលមានទឹកហូរហៀរសំរាប់ស្រោចស្រប់ដំណាំ សំរាប់ការភ្ជួររាស់ដីសំរាប់បន្លែបង្កា និងសំរាប់មនុស្សម្នាដ៏ច្រើនកុះករ ។



**ហ្សុីយ៉ាដ:** តើអ្នកកំពុងនិយាយពីអ្វី?កូនក្រមុំទន្លេនីល សំបុត្រ ទឹកហូរហៀរសំរាប់មនុស្ស? ឬគ្រោះរាំងស្ងួតស្ទើរតែបំផ្លាញមនុស្សលោក?

**ហ៊ូសាម:**ហេតុអ្វីបានជាអ្នកប្រញាប់ប្រញាល់ម្ល៉េះ? ចាំបន្តិច ខ្ញុំនឹងនិយាយរឿងកូនក្រមុំទន្លេនីលប្រាប់។ វាជាទង្វើរបស់ជនជាតិអេហ្សុីបដែលតែងតែបោះកូនក្រមុំចូលទៅក្នុងទន្លេនីល ក្រោយពីពួកគេតុបតែងអោយកូនក្រមុំនោះនូវគ្រឿងអលង្ការដ៏ស្រស់ស្អាតរួចរាល់ហើយ ដោយគេយល់ថាបើមិនធ្វើអញ្ចឹងទេនោះនឹងគ្មានទឹកប្រើប្រាស់ឡើយ។ លុះពេល អាំរូ កូនអាស្សរំដោះប្រទេសអេហ្សុីបបាន លោកត្រូវប្រឈមមុខនឹងប្រពៃណី ដ៏ចំឡែកនេះ។ ទន្លេដ៏ធំល្វឹងល្វើយនេះបានរីងហួតដោយទង្វើទាំងអស់នេះ។ អាំរូបានផ្ញើលិខិតទៅអោយអ៊្លូម៉ើរ ដើម្បីពិភាក្សាជុំវិញទស្សនៈ របស់អ្នកស្រុកនេះតើគួរធ្វើបែបណា ដើម្បីអោយមនុស្សសុខចិត្តបោះបង់នូវទំលាប់ទាំងនោះចោល និងដើម្បីអោយមនុស្សម្នាដឹងថា វាជាប្រការដែលត្រូវច្បាប់អ៊ីស្លាមបានហាមឃាត់ដាច់ខាត ចំពោះការសំលាប់មនុស្សដោយការបោះទាំងរស់ចូលក្នុងទន្លេនីល។ លិខិតអ៊្លូម៉ើរទៅកាន់តំបន់ផ្សេងៗនៃប្រទេសអេហ្សុីបអ៊្លូម៉ើរបានបញ្ជូនលិខិតមួយច្បាប់ ដែលមានខ្លឹមសារក្នុងលិខិតនេះថា: " ពីអាប់ឌុលឡោះអ៊្លូម៉ើរកូនខត្តបជូនចំពោះប្រជាជនអេហ្សុីបទាំងអស់។ ប្រសិនបើអ្នកធ្លាប់រត់ដោយខ្លួនឯង ចូរអ្នកឈប់រត់ភ្លាមតែបើអ្នកធ្លាប់រត់តាមការបញ្ជារបស់អល់ឡោះ ពួកយើងជួយសុំពីទ្រង់ដ៏មហាធំធេងអោយពន្លឿនដល់អ្នកថែម

ទៀត ។គេបានបញ្ជូនលិខិតរបស់អ៊ូម៉ើរទៅកាន់ទន្លេយូរអង្វែង។ សូមអល់ឡោះផ្តល់ផលបុណ្យដល់មនុស្សតាមរយៈទន្លេនីលផង ។

**មូហាំម៉ាត់ :** អត្ថន័យល្អណាស់ និងប្រកបដោយភាពទន់ភ្លន់បំផុត ! ប៉ុន្តែខ្ញុំចង់បញ្ជាក់អោយបានច្បាស់ថែមទៀតថា ឥឡូវនេះពួកយើងកំពុងតែចាប់អារម្មណ៏ក្នុងប្រទេសអេហ្ស៊ីបតាមរយៈទន្លេនីល ដែលគ្មានទឹកជំនន់ឬគ្រោះរាំងស្ងួតទៀតឡើយ បន្ទាប់ពីជនជាតិអេហ្ស៊ីបបានសាងសង់ទំនប់យ៉ាងខ្ពស់ក្នុងតំបន់អាសវ៉ានមក ។

## ក្តីមេត្តានិងភាពយុត្តិធម៌របស់អ៊ូម៉ើរ

**ហ្ស៊ីយ៉ាដ :** ពួកយើងគួរងាកទៅមើលប្រវត្តិរបស់អ៊ូម៉ើរដែលពួកយើងអាចទាញយកបន្ថែមពីក្តីមេត្តារបស់លោកចំពោះជនមូស្លីម និងមិនមែនមូស្លីម។ មានពេលមួយនោះអ៊ូម៉ើរ បានឃើញបុរសយ៉ើហ៊ូឌីចំណាស់ម្នាក់ពិការភ្នែក។ លោកបានបញ្ជាអោយគេផ្តល់ការផ្គត់ផ្គង់ដល់ជនពិការចំណាស់នេះ និងអ្នកផ្សេងៗទៀតដែលមានតំរូវការចាំបាច់ពីថវិការួមរបស់ជនមូស្លីម។

**អះម៉ាត់:** ទាក់ទងនឹងប្រវត្តិទាំងនេះបានធ្វើអោយរូបខ្ញុំហូរទឹកភ្នែកនិងបានធ្វើអោយខ្ញុំមានចំណាប់អារម្មណ៏កាន់តែខ្លាំងផង។ ខ្ញុំសូមលើកយកដំណើររឿងរបស់ថ្នាក់ដឹកនាំកំពូលយុត្តិធម៌ ដែលពួកយើងយល់ថាវាមានសារៈសំខាន់មួយដើម្បីយកមកពិពណ៌នាប្រាប់។ ដំណើររឿងនេះបាននាំមកដោយលោកសាឡាម។ សាឡាមបាននិយាយថាៈ ថ្ងៃមួយ ពួកយើងបានចេញទៅកន្លែងមួយជិតទីក្រុងម៉ាឌីណះ ជាមួយអ៊ូម៉ើរ។ ពេលនោះពួកយើងបានឃើញពន្លឺ



ភ្លើងដែលកំពុងដាំស្ល។ អ៊ូម៉ើរនិយាយថាៈ ពួកយើងត្រូវទៅកាន់កន្លែងនោះដើម្បីបានដឹងពីសភាពរបស់ពួកនៅទីនោះ។ លុះពេលពួកយើងចូលទៅជិតពួកយើងបានឃើញស្ត្រីម្នាក់ ក្មេងតូចៗនិងឆ្នាំងមួយលើចង្ក្រាន ហើយក្មេងៗទាំងនោះកំពុងទ្រហោយំ ដោយសារការស្រេកឃ្លាន។ អ៊ូម៉ើរបានអោយសាឡាម[១] រួចនិយាយថា ឱម្ចាស់ភ្លើង! ( សំដៅទៅអ្នកកំពុងដុតភ្លើង) ស្ត្រីរូបនោះបានឆ្លើយតបវិញដែលមានន័យថាៈ សូមសេចក្តីសុខកើតមានចំពោះពួកអ្នកផងដែរ។ អ៊ូម៉ើរបានសួរបន្តថាៈ ហេតុអ្វីបានជាក្មេងទាំងនេះស្រែកយំ? ស្ត្រីនោះឆ្លើយថាៈ ដោយសារការស្រេកឃ្លាន និងអាកាសធាតុត្រជាក់ដែលវាបង្កផលលំបាកដល់ពួកយើងនិងក្មេងៗ។ អ៊ូម៉ើរសួរបន្តថាៈតើអ្នកស្រីកំពុងធ្វើអ្វីនៅក្នុងឆ្នាំងនេះ? ស្ត្រីនោះបានឆ្លើយថាៈ វាមានតែទឹកទទេដែលខ្ញុំកំពុងដណ្តាំវាបន្លំភ្នែកក្មេងៗទាំងនេះដើម្បីអោយពួកគេឆាប់ដេកលក់។ ពេលនោះអ៊ូម៉ើរបានវិលត្រឡប់វិញយ៉ាងលឿន ទឹកភ្នែករបស់លោកបានហូរស្រក់មកពេញថ្ពាល់។ លោកបានចាប់យកម្សៅមួយការុងនិងអំបិល។ លោកលើកលីដោយខ្លួនឯង។ ពេលនោះលោកសាឡាមបាននិយាយទៅកាន់អ៊ូម៉ើរថាៈ"សូមទុកអោយខ្ញុំលីវិញ?។ អ៊ូម៉ើរបានឆ្លើយថាៈតើអ្នកអាចទទួលទោសកំហុសជំនួសរូបខ្ញុំនៅថ្ងៃបរលោកបានដែរឬទេ ? "។ អ៊ូម៉ើរបន្តលីម្សៅរហូតដល់ផ្ទះស្ត្រីនោះ។ ពេលទៅដល់លោកចាប់ផ្តើមធ្វើនំ ដើម្បីអោយ

---

១ - ពាក្យស្វាគមរបស់ជនមូស្លីមដែលមានន័យថាសូមសេចក្តីសុខកើតមានចំពោះរូបអ្នក)

ក្មេងៗនោះទទួលទាន ។លោកបានឱនផ្តុំភ្លើងរហូតដល់នំឆ្អិន ។ លោកបានដាក់ឆ្នាំងចុះរួចប្រាប់ស្ត្រីនោះថា:ចូរអ្នកស្រីបញ្ចុកពួកគេ ហើយខ្ញុំជាអ្នកផ្តុំអោយឆាប់ត្រជាក់ ។ក្មេងៗបានទទួលទានរហូតបានឆ្អែតគ្រប់ៗគ្នាហើយស្ត្រី រូបនោះបានសំដែងការដឹងគុណចំពោះអ៊ូម៉ើរតែស្ត្រីនោះមិនបានស្គាល់ថាអ្នកជួយនោះជាថ្នាក់ដឹកនាំកំពូលរបស់អ៊ីស្លាមនោះទេ ។

**ម៉ាស់ម៉ូដៈ** សំលាញ់! ខ្ញុំសូមបំពេញបន្ថែម គឺខ្ញុំធ្លាប់បានអានថា: មានបុរសម្នាក់បានមកជួបអ៊ូម៉ើរដើម្បីប្តឹងពីក្មេងៗដែលបានលួចសត្វអូដ្ឋរបស់គាត់ ។ ពេលអ៊ូម៉ើរហៅក្មេងៗទាំងនោះមក លោកបានសំលឹងមើលពួកគេដោយក្តីអាណិតអាសូរបំផុតដល់ពួកគេ ដោយសារតែ........ ។

**ហ៊ូសាម :** អ្នកចង់និយាយថាម៉េច? វាដូចជាមិនទាន់យល់ ?

**ហ្សុីយ៉ាដ :** សំលាញ់! មានន័យថា:អ៊ូម៉ើរមានការអាណិតអាសូរដល់ក្មេងៗទាំងនោះពេលលោកបានឃើញខ្លួនប្រាណរបស់ពួកគេស្គមស្គាំងស្បែកដណ្តប់ឆ្អឹងនិងបានស្តែងចេញការក្រៀមក្រំបំផុត ។មុខមាត់របស់ពួកគេស្លេកស្លាំង ។ អ៊ូម៉ើរបានបញ្ជាអោយគេនាំខ្លួនមេកន្ទ្រាញក្មេងៗទាំងនេះ មកជួបរួចនិយាយប្រាប់ថា: " ពួកយើងនឹងដាក់ទណ្ឌកម្មឯង តាមទោសកំហុសក្មេងៗទាំងនេះ ព្រោះឯងបានបណ្តោយពួកក្មេងៗទាំងនេះឱ្យធ្លាក់ខ្លួនទៅជាចោរ ហើយពួកយើងនឹងសងតំលៃសត្វអូដ្ឋអោយម្ចាស់គេវិញ" ។ អ៊ូម៉ើរក៏បាននិយាយទៅកាន់ក្មេងៗទាំងនោះថា: ទៅវិញចុះហើយឈប់ប្រព្រឹត្តអំពើទាំងនេះទៀត ។

**អះម៉ាត់:** ក្តីមេត្តារបស់អ៊ូម៉ើរបានប្រើទៅលើអ្នកនៅក្រោមឱវាទ ទាំងមូស្លីម



និងមិនមែនមូស្លីម ។ លោកធ្លាប់បានដាក់ទណ្ឌកម្មលើកូនរបស់លោកដោយការវាយនឹងរំពាត់ ពេលដែលគេបានផឹកស្រា ។

**ម៉ាស់ម៉ូដៈ** អ៊ូម៉ើរសុខចិត្តលះបង់អ្វីៗដើម្បីអនុវត្តច្បាប់ ។លោកពាក់អាវវែងមួយឈុតដែលពោរពេញទៅដោយស្នាមផ្ទេរប៉ះដេរដាស ។ លោកព្យាបាលសត្វអូដ្ឋ ។មានស្តេចនិងថ្នាក់ដឹកនាំផ្សេងៗមកជួបលោក ពួកគេបានជួបពេលលោកកំពុងដេកលើដីក្នុងសភាពជាលក្ខណ:ជនក្រីក្របំផុត ។

## ការធ្វើឃាតអ៊ូម៉ើរ

**ហ៊ូសាម:** អ៊ូម៉ើរបានគ្រប់គ្រងប្រកបដោយយុត្តិធមិ និងកោតខ្លាចអល់ឡោះបំផុត ។ ថ្ងៃមួយពេលអ៊ូម៉ើរកំពុងធ្វើអ៊ីម៉ាំសឡាហ៍ ក៏ស្រាប់តែមានយុវជនម្នាក់ឈ្មោះលុលុដែលមិនមែនជាមូស្លីម បានលបចូលទៅលាក់ខ្លួននៅក្បែរកន្លែងអ៊ូម៉ើរឈរសឡាហ៍ រួចក៏ស្ទុះចេញមកចាក់អ៊ូម៉ើរនឹងកាំបិតស្នៀតមុខពីរដែលមានពិស ។ បន្ទាប់មកក៏បានចាក់ទៅលើបុរសចំនួន១៣នាក់ផ្សេងៗទៀត ។ លុះពេលព័ទ្ធចាប់ខ្លួនយុវជននោះបាន យុវជននោះក៏ចាក់សំលាប់ខ្លួនឯង ។

**ឪពុក :** ឱកូនៗជាទីស្រលាញ់! ពួកយើងត្រូវវិលត្រឡប់ទៅរកប្រវត្តិរបស់អ៊ូម៉ើរវិញ ដើម្បីពួកយើងជជែកពីគុណសម្បត្តិ និងទស្សនៈផ្សេងៗរបស់លោកដែលវានឹងបន្សល់ទុករហូតដល់អវសាន្តជីវិត ។

**ម៉ាស់ម៉ូដ :** អ៊ូម៉ើរជាបុគ្គលម្នាក់ដែលមានលក្ខណ:ជាអ្នកប្រតិបត្តិប្រការល្អ

អ្នកកោតខ្លាចអល់ឡោះជាម្ចាស់ អ្នកយកចិត្តទុកដាក់លើការគោរពសក្ការៈចំពោះអល់ឡោះ អ្នកដោះស្រាយតំរូវការរបស់មនុស្សម្នាអ្នកលះបង់លោកីយ៍ អ្នកចំណាយពេលវេលាដើម្បីកិច្ចប្រតិបត្តិ អ្នកទំនាក់ទំនងល្អដាក់ខ្លួនគោរពកោតខ្លាចអល់ឡោះ ។ អ៊ូម៉ើរបាននិយាយណែនាំថាៈ"ចូរពួកអ្នកគិតអំពីខ្លួនឯងមុនពេលគេគិតគូរអោយអ្នក ចូរពួកអ្នកថ្លឹងថ្លែងទង្វើរបស់ពួកអ្នកមុនពេលទង្វើរបស់ពួកអ្នកត្រូវគេថ្លឹង ហើយចូរពួកអ្នកត្រៀមខ្លួនសំរាប់ថ្ងៃបរលោក "។សូមអល់ឡោះអភ័យទោសដល់អ៊ូម៉ើរដែលជាថ្នាក់ដឹកនាំកំពូលម្នាក់ និងបណ្តាមិត្តសំលាញ់របស់មូហាំម៉ាត់ទាំងអស់ផង ។

**កូន៧ទាំងអស់ៈ**ឱអល់ឡោះ! ម្ចាស់ដែលជាអ្នកគ្រប់គ្រងលើលោកទាំងឡាយសូមទ្រង់ទទួលយកនូវការបួងសួងនេះផងចុះ ?



# ឧស្មានកូនអាហ្វាន

## មេដឹកនាំអ៊ីស្លាមទី៣(២៣-៣៥ ម.ស/៦៤៤-៦៥៦ គ.ស)

**អះម៉ាត់ៈ** តាមការព្រៀងទុករបស់យើង គឺត្រូវជជែកគ្នាពេលឥឡូវនេះពីមេដឹកនាំអ៊ីស្លាមកំពូលទីពីររបស់សាសនិកអ៊ីស្លាមបន្ទាប់អំពីណាហ្គីនិងអាហ្គូហ្គាកើរ គឺលោកឧស្មានកូនអាហ្វាន ។ គេបានដាក់ងារអោយលោកថា : "ហ៊្សីននូរៃន៏ ( មានរស្មី២) "។

**ហ៊ូសាម** :ថ្ងៃនេះយើងមានភ័ព្វវាសនាដ៏ត្រចះត្រចង់នឹងពោរពេញទៅដោយភាពសុខសាន្តចំពោះការស្វែងយល់នូវប្រវត្តិរបស់មេដឹកនាំ ដ៏កំពូលទីពីររបស់សាសនិកអ៊ីស្លាម គឺលោកឧស្មានកូនអាហ្វាន។

**ម៉ាស់មូដៈ**លោកគឺមានឈ្មោះថាៈឧស្មានកូនអាហ្វានអាហ្វានកូនអាហ្គីអាស្សអាហ្គីអាស្សកូនអ៊ូម៉ៃយ៉ះ អ៊ូម៉ៃយ៉ះកូនអាប់ឌុស្សាំ។ ម្តាយរបស់លោកឈ្មោះអ៊ូរវ៉ាកូនគូរ៉ៃស៏ កូនរ៉ហ្គីអះ។ ជីដូនរបស់លោកឈ្មោះ អ៊ុម្មី ហាគីមអាល់ហៃហ្គកកូនស្រីអាប់ឌុលមូតល់លិប ដែលត្រូវជាបងប្អូនភ្លោះជាមួយនឹងលោកអាប់ឌុលឡោះកូនអាប់ឌុលមូតល់លិបឪពុករបស់ណាហ្គីមូហាំម៉ាត់។

**សើម៉ាហ៏ៈ** ដូច្នេះជីដូនរបស់លោក គឺអ៊ុម្មីហាគីម ត្រូវជាម្តាយមីងរបស់រ៉ស៊ូលុលឡោះ។

**ហ៊្សីយ៉ាដ :** លោកឧស្មានកូនអាហ្វាន ចាប់កំណើតក្រោយឆ្នាំដំរី រយះពេល៦ឆ្នាំ។ ឪពុករបស់លោកជាអ្នកជំនួញធំម្នាក់។

**ហ៊ូសាម :** ហេតុអ្វីបានជាលោកចូលអ៊ីស្លាម? តើលោកចូលសាសនាអ៊ីស្លាមតាំងពីពេលណា?

## ការចូលអ៊ីស្លាមរបស់លោក

**ម៉ាស់មូដ :** មូលហេតុលោកទទួលយកសាសនាអ៊ីស្លាម ដោយសារអាហ្គូហ្គាកេីរជាអ្នកអំពាវនាវ និងដឹកនាំលោករហូតដល់មានជំនឿក្នុងសាសនារបស់អល់ឡោះដ៏ត្រឹមត្រូវ ។ពេលមួយអាហ្គូហ្គាកេីរនិយាយទៅកាន់លោកឧស្មានថា:ខ្ញុំបានដឹងយ៉ាងច្បាស់ថាលោកជាបុរសម៉ឺងម៉ាត់ម៉ត់ចត់ និងមានការពិចារណាផ្លូវខុសនិងផ្លូវត្រូវមិនអាចរំលងលោកបានឡើយ ។រូបបដិមាដែលអ្នកនិងក្រុមមនុស្សរបស់អ្នកកំពុងគោរពសក្ការៈនេះវាមានន័យយ៉ាងម៉េច? ពួកគេមិនអាចស្តាប់ឮមិនអាចមើលឃើញ មិនអាចមានលទ្ធភាពបង្គ្រោះថ្នាក់និងមិនអាចផ្តល់ផលប្រយោជន៏ដល់អ្នកនិងក្រុមមនុស្សរបស់អ្នកបានទេ” ។

**លូហ្គាណា:**លោកឧស្មានបានរៀបរាប់អោយដឹងថា:“ខ្ញុំបានធ្វើដំណេីរជាមួយអាហ្គូហ្គាកេីរទៅចូលជួបរ៉ស៊ូលុលឡោះ ។ នៅពេលទៅដល់រ៉ស៊ូលុលឡោះលោកមានប្រសាសន៏មកកាន់ខ្ញុំថា: ឱ ឧស្មាន! ចូរអ្នកទទួលស្គាល់អល់ឡោះជាម្ចាស់ នោះចាត់ទុកថាអ្នកកំពុងបានធ្វើដំណេីរទៅកាន់ឋានសួគ៌របស់ទ្រង់ហេីយ ។ នៅពេលខ្ញុំបានឮប្រសាសន៏របស់ណាហ្គីភ្លាម ខ្ញុំក៏ទទួលយកការចង្អុលបង្ហាញរបស់ណាហ្គីនិងពោលពាក្យថា (أشهد أن لا إله إلا الله) មានន័យថា: ខ្ញុំធ្វើសាក្សីថាគ្មានទេម្ចាស់ដែលត្រូវគោរពពិតប្រាកដក្រៅពីអល់ឡោះ” ។

**ហ្សីយ៉ាដ :**ក៏ប៉ុន្តែ........ក៏ប៉ុន្តែ....ខ្ញុំបានអានឯកសារមួយមិនដឹងថាត្រឹមត្រូវឬយ៉ាងណានោះទេ ។ ឯកសារនោះសរសេរថា: “ ឧស្មានមានមីងម្នាក់ជាហោរាសាស្រ្ត ។ ម្តាយមីងរូបនោះបានប្រាប់ឧស្មានពីរឿងរបស់មូហាំម៉ាត់ថា: “មូហាំម៉ាត់ គឺជាណាហ្គីដែលលោកមានភស្តុតាងមកជាមួយ ។ អល់ឡោះបានតែងតាំងលោកដោយនាំមកនូវសាសនាពិតប្រាកដចូរដេីរតាមមូហាំម៉ាត់ហេីយបោះបង់ការគោរពផ្សេងពីអល់ឡោះជាបន្ទាន់ ។លោកស្រីបានបញ្ជាក់ថាមូហាំម៉ាត់កូនអាប់ឌុលឡោះ ជាអ្នកអំពាវនាវមនុស្សលោកទៅរកមាគ៌ាមួយប្រកបដោយការចង្អុលបង្ហាញ និងទៅរកសាសនាមួយដ៏ពិតប្រាកដ ។

**អះម៉ាត់ :**បងប្រុស! តើបានពាក្យសំដីនេះមកពីណា? ត្រូវដឹងថាហោរាសាស្រ្តគឺត្រូវច្បាប់សាសនាអ៊ីស្លាមហាមឃាត់ដាច់ខាត( ហារ៉ាំ) ។

**ណាដា:**ពិតមែនហេីយ!ការទាយត្រូវបានច្បាប់ដាក់បំរាមដាច់ខាតបន្ទាប់អំពីទួលយកសាសនាអ៊ីស្លាមហេីយ ។ ដូចអល់ឡោះមានបន្ទូលនៅក្នុងជំពូកអាល់ជិនក្នុងវាក្យខ័ណ្ឌទី៨និងទី៩ដែលមានន័យថា: ពិតណាស់យេីង (ពួកបិសាច) បានទាមទារដល់មេឃា( ដេីម្បីស្តាប់ពាក្យសំដីក្រុមរបស់គេ) តែពួកយេីងបានជួបពួកម៉ាឡាអ៊ីកាហ៏យ៉ាងច្រេីននៅការពារទីនោះយ៉ាងរឹងមាំនិងដុតភ្លេីង( សំរាប់គប់ដល់នរណាទៅជិតទីនោះ) ។

## អាពាហ៍ពិពាហ៍របស់ឧស្មាន

លោកឧស្មាន កូនអាហ្វានបានរៀបអាពាហ៏ពិពាហ៏ ជាមួយអ្នកស្រីរូក័យយ៉ះ ជាកូនស្រីរបស់រ៉ស៊ូលុលឡោះ ។ក្រោយពីអ្នកស្រីទទួលមរណៈភាពលោកបាន រៀបអាពាហ៏ពិពាហ៏ជាមួយប្អូនបង្កើតរបស់រូក័យយ៉ះគឺឈ្មោះអ៊ុម្មីកាល់ស៊ូម ។ ក្រោយពីអ៊ុម្មីកាល់ស៊ូមទទួលមរណៈភាព រ៉ស៊ូលុលឡោះ មានប្រសាសន៏ទៅ កាន់លោកឧស្មានថាៈបើយើងមានកូនស្រីទី៣ យើងនឹងរៀបការអោយអ្នក ទៀត ។

**សើម៉ាហ៏ :** លោកឧស្មានកូនអាហ្វាន និងអ្នកស្រីរូក័យយ៉ះកូនស្រីរបស់រ៉ស៊ូ លុលឡោះ បានធ្វើដំណើរទៅកាន់ទឹកដីហាប់ស្ហះ (បច្ចុប្បន្នជាប្រទេសអេចូពី) អ្នកទាំងពីរជាអ្នកធ្វើបំលាស់ទីមុនគេបង្អស់ទៅកាន់ទីនោះ ។ ក្រោយមកអ្នក ទាំងពីរក៏បានវិលត្រលប់មកកាន់ទឹកដីម៉ាឌីណះវិញ ។ តែជាអកុសលអ្នកស្រី ក៏ចាប់ផ្តើមមានជំងឺលោកឧស្មានក៏បានយកចិត្តទុកដាក់ ថែរក្សាអ្នកស្រីជាប់ ជានិច្ច ។ ក្រោយពេលអ្នកស្រីរូក័យយ៉ះទទួលមរណៈភាពលោកឧស្មានបាន រៀបអាពាហ៏ពិពាហ៏ជាមួយប្អូនស្រីរបស់អ្នកស្រីគឺអ៊ុម្មីកាល់ស៊ូម ។ ក្នុងឆ្នាំ ទី៩នៃមូហាំម៉ាត់សករាជអ្នកស្រីក៏ទទួលមរណៈភាពទៀត គឺបន្ទាប់ពីបាន រៀបអាពាហ៏ពិពាហ៏បានរយៈពេល៦ឆ្នាំ ។

## គោរម្យងារនិងអត្ថន័យរបស់វា

**មូហាំម៉ាត់ :** ក៏ប៉ុន្តែ..! ហេតុអ្វីបានជាគេហៅលោកជាអ្នកទទួលបានរស្មីពីរ?



**អះម៉ាត់ :** ត្រឹមត្រូវណាស់បងប្រុស! ក្រោយពេលខ្ញុំឮថា លោកឧស្មានបាន រៀបការជាមួយកូនស្រីទាំងពីររបស់រ៉ស៊ូលុលឡោះ អ្នកចង់សួរសំណួរនេះ មែនឬ? ក៏ប៉ុន្តែខ្ញុំនឹងនិយាយរៀបរាប់ប្រាប់អ្នក ដើម្បីយើងទទួលបានផលប្រ យោជន៏ទាំងអស់គ្នា ។ហេតុដែលជាគេហៅលោកឧស្មានថាៈ"អ្នកមានរស្មីពីរ" នោះដោយសាលោកបានរៀបការជាមួយកូនស្រីទាំងពីរបស់ រ៉ស៊ូលុលឡោះ ជាមួយនេះដែរ ខ្ញុំបានអានអត្ថបទមួយ ដែលរាយការណ៏ដោយលោកអាលី បានឱ្យដឹងថាៈ" បុគ្គលម្នាក់នោះត្រូវបានគេហៅក្នុងក្រុមម៉ាឡាអ៊ីកាហ៏ថាៈជា អ្នកមានរស្មីពីរ" ។ ពាក្យផ្សេងទៀតបានបង្ហាញថានៅក្នុងហេតុផលដែលគេ បានដាក់ងារលោកជាមនុស្សមានរស្មីពីរនោះ គឺដោយសារលោកបានសូត្រ គួរអានបានចប់១ដងជារៀងរាល់យប់នៅក្នុងសឡាហ៏របស់លោក ។ គម្ពីរគួរ អានដ៏ឧដុង្គឧត្តមជារស្មីមួយ ហើយការសឡាហ៏(ការថ្វាយបង្គំ)ពេលយប់ក៏ ជាពន្លឺមួយផ្សេងទៀត ។ តែទស្សនៈខាងលើគឺទស្សនៈទី១ត្រឹមត្រូវជាង ។

## ការអៀនខ្មាស់របស់ឧស្មាន

**ម៉ាស់មូដៈ** គេស្គាល់យ៉ាងច្បាស់ថាលោកឧស្មានជាមនុស្សមានការអៀនខ្មាស់ និងមានគុណៈជាច្រើនទៀតដូចជាលោកជាមនុស្សរាក់ទាក់ចិត្តទូលាយទន់ភ្លន់ សុភាពរាបសារ និងជាមនុស្សប្រកាន់សីលធមិរស់នៅល្អ ។

**លូហ្កាណាៈ**លោកឧស្មានមានឈ្មោះល្បីល្បាញថាជាមនុស្សខ្លាំងក្លាចិត្តទូលាយ ពពួកមូស្លីមីនគ្មានទឹកសំរាប់ប្រើប្រាស់ក្រៅអំពីទឹកអណ្តូងឈ្មោះហ៊ុលរ៉ះដែល

ជាកម្មសិទ្ធរបស់យ៉ាហ៊ូឌីម្នាក់ ។ ពេលនោះលោកឧស្មានក៏សុំទិញទឹកអណ្តូងនោះចំនួនពាក់កណ្តាល ដើម្បីទុកអោយពួកមូស្លីមីនប្រើប្រាស់ដោយមិនគិតថ្លៃ ។ បុរសយ៉ាហូឌីនោះយល់ឃើញថា ដោយសារតែខ្លួនមិនអាចមានសិទ្ធិផ្តាច់មុខនូវចំណែកណាមួយនៃអណ្តូងនោះ គាត់ក៏សំរេចលក់ទឹកអណ្តូងនោះពាក់កណ្តាលទៅអោយលោកឧស្មាន ។ ឧស្មានបានទិញរួចក៏ប្រគល់ចំណែកនោះទុកអោយសាសនិកអ៊ីស្លាមទាំងអស់គ្នាបានប្រើប្រាស់ ។

**អ៊ីស្លាមៈ** នៅពេលរ៉ស៊ូលុលឡោះគ្រោងធ្វើសិកសង្គ្រាមនៅសមរភូមិតាហ្ពូក តែពួកមូស្លីមីនគ្មានសំភារៈសិកគ្រប់គ្រាន់ឡើយ ។ ខណៈនោះលោកឧស្មានក៏បានបរិច្ចាគទ្រព្យរបស់លោកចំនួនមួយភាគបីទៅឱ្យណាហ្ពីសំរាប់សំភារៈសិក ហើយលោកបានផ្គត់ផ្គង់ចំណីអាហារផងដែរ ។ លោកបានយកថវិកាចំនួន ១000ឌីណារ( លុយមាសរបស់អារ៉ាប់ជំនាន់មុន) ប្រគល់ជូនណាហ្ពី ។ក្រោយមកទៀតលោកបានទិញដី( ដាក់ជាសម្បត្តិរួម) ចំណាយអស់ទឹកប្រាក់ចំនួន ២0ពាន់ដារ៉ហាំ( លុយប្រាក់របស់អារ៉ាប់ជំនាន់មុន ) ទៀត ។

## ការធ្វើជំនួញរបស់លោកឧស្មានជាមួយអល់ឡោះជាម្ចាស់

**ហ៊ូសាម :** តើពួកអ្នកទាំងអស់គ្នា អនុញ្ញាតិអោយខ្ញុំនិយាយពីការធ្វើជំនួញរបស់លោកនិងការបរិច្ចាគក្នុងបុព្វហេតុមាគ៌ាអល់ឡោះនៅក្នុងសម័យមេដឹកនាំអ៊ីស្លាមទី១( អាហ្ពូហ្ពាកើរ) ដែរឬទេ? ឬមួយពួកអ្នកចង់បន្តនិយាយរឿយៗពីភាពអស្ចារ្យរបស់ឧស្មាន? បើដូច្នេះយើងនឹងនិទានគ្រប់យ៉ាងទាំងអស់ដែលពាក់ពន្ធ័នៅក្នុងរឿងនោះតាមលទ្ធភាពដែលយើងអាចធ្វើទៅបាន!



**ឪពុក :** នែ៎! ជំនួញរបស់លោកឧស្មានទទួលបានជោគជ័យ និងចំណេញច្រើនណាស់ ។ និយាយរឿងនេះធ្វើអោយពួកយើងកាន់តែមានអារម្មណ៏ភ្លឺថ្លា និងរីករាយពន់ពេកណាស់ ។

**ហ៊ូសាមៈ**នៅក្នុងសម័យអាហ្ពូហ្ពាកើរ គ្រោះរាំងស្ងួតខ្លាំងមួយបានកើតមានខណៈនោះអាហ្ពូហ្ពាកើរបាននិយាយថាៈអល់ឡោះទ្រង់នឹងបើកច្រកដល់យើងប្រសិនបើទ្រង់មានបំណង ។ ស្អែកឡើងទំនិញរបស់ឧស្មានយ៉ាងសន្ធឹកសន្ធាប់បានមកដល់ ។ នៅពេលនោះបណ្តាអ្នកជំនួញនៅម៉ាឌីណះក៏បាននាំគ្នាមកជួបលោកឧស្មានបំណងទិញទំនិញទាំងនោះ ។ខណៈនោះលោកឧស្មានបានសួរពួកគេថាៈ តើពួកអ្នកហ៊ានអោយខ្ញុំចំណេញប៉ុន្មានសំរាប់ទំនិញមកពីស្រុកស្ហាមនេះ? ពួកគេឆ្លើយថាៈ ពួកយើងហ៊ានអោយចំណេញ៥ដងលើ តំលៃដើម ។ លោកឧស្មាននិយាយថាៈអោយចំណេញ១0ដងមក? ។ពួកគេនិយាយតបវិញថាៈ"នៅពេលពួកយើងតំឡើងថ្លៃបន្ថែមអោយលោក លោកតែងតែទាមទារអោយពួកយើងតំឡើងជាបន្តបន្ទាប់ ។តើមានអ្នកហ៊ានឡើងថ្លៃលឿនដូចពួកយើងដែរទេ?ខណៈនោះលោកឧស្មានមានប្រសាសន៏ថាៈ" សូមដឹងលឺផងចុះថាៈ ទំនិញទាំងនេះខ្ញុំទុកបរិច្ចាគទានជូនអ្នកក្រីក្រនៅឯម៉ាឌីណះប៉ុណ្ណោះ" ។

**អះម៉ាត់ៈ**អល់ឡោះ!ប្រាកដណាស់លោកឧស្មានគ្មានបំណងប្រាថ្នាផលបុណ្យអ្វីក្រៅពីផលបុណ្យពីអល់ឡោះជាម្ចាស់ ។ អល់ឡោះមានបន្ទូលនៅក្នុងជំពូកអាល់អាន់អាម វាក្យខ័ណ្ឌ១៦0 ដែលមានន័យថាៈ ( ជនណាបានសាងអំពើកុសលមួយ កុសលនោះនឹងកើនទៅជា១0ដងសំរាប់រូបគេ ) ។

**មូហាំម៉ាត់:** តើពួកអ្នកដឹងដែរឬទេ លោកឧស្មានកូនលោកអាហ្វានគឺជាអ្នករៀបចំប្រមូលផ្តុំគម្ពីរអាល់គួរអានដ៏ពិសិដ្ឋ?!

**ហ្ស៊ីយ៉ាដ:**បាទ! ពិតមែនហើយ ការងារដ៏សំខាន់បំផុតរបស់លោកឧស្មានកូនអាហ្វាននោះគឺការរៀបចំប្រមូលផ្តុំគម្ពីរអាល់គួរអាន។

**ហ៊ូសាម:** មានន័យថាលោកមែនទេដែលជាអ្នករៀបចំប្រមូលផ្តុំគម្ពីរអាល់គួរអានសព្វថ្ងៃនេះ? យើងបានដឹងរួចមកហើយថា លោកអ៊ូម៉ើរបានជូនយោបល់ដល់អាប៊ូបាកើរអោយមានការរៀបចំប្រមូលគម្ពីរគួរអាន ដោយមូលហេតុថា:អ្នកចងចាំគួរអានបានស្លាប់ជាបន្តបន្ទាប់។ ខណ:នោះគេក៏បាននាំគ្នាប្រមូលផ្តុំវាក្យខ័ណ្ឌអាល់គួរអានរួចគេយកវាទៅពិនិត្យគ្រប់ វាក្យខ័ណ្ឌទាំងអស់ជាមួយនឹងអ្នកចងចាំអាល់គួរអាន។ ដូចគ្នាដែរនៅសម័យអ៊ូម៉ើរហើយក្រោយមក **ឧស្មាន** ក៏ចាប់ផ្តើមចំលងក្នុងលក្ខណ:ជាគម្ពីរដែលមានឈ្មោះថាគួរអានអូស្មានីដែលគេទទួលស្គាល់ទាំងអស់គ្នា។

**សើម៉ាហ៊:** នៅពេលលោកហ៊ូហៃហ្វ៊ះវិលត្រលប់មកពីសមរភូមិវិញ លោកបានផ្តល់ពតិមានដល់លោកឧស្មានថា:មនុស្សម្នាស្ទើរតែខ្វែងយោបល់គ្នាក្នុងបញ្ហាគម្ពីរអាល់គួរអាន។ ខណ:នោះលោកឧស្មានបានបញ្ជូននារសាទៅជួបអ្នកស្រីហាប់សោះ( ប្រពន្ធណាប៊ី) ដើម្បីស្នើសុំឯកសារ (គម្ពីរអាល់គួរអាន) ដែលលោកអ៊ូម៉ើរបានរក្សាទុកដែលមាននៅជាមួយអ្នកស្រី ។បន្ទាប់មកលោកបានបញ្ជាអោយលោកហ៊ៀតកូនសាប៊ិត អាប់ឌុលឡោះកូនស៊ូហៃប៊ែរ៍សាអាត់ កូនអាល់អាស្សនិងអាប់ឌុររ៉ស់ម៉ានកូនហារីស ដើម្បីរៀបចំគម្ពីរអាល់គួរអាន



អោយបានត្រឹមត្រូវ និងត្រូវធ្វើការពិនិត្យម្តងទៀតជាមួយនឹងមិត្តសំលាញ់របស់រ៉ស៊ូលុលឡោះទាំងអស់គ្នាបន្ទាប់មកចងក្រង វាអោយទៅជាគម្ពីរអាល់គួរអានពេញលេញតែម្តង( គឺដូចគួរអាននៅពេលបច្ចុប្បន្ននេះ) ។

**ម៉ាស់ម៉ូដ:** អល់ឡោះពិតជាបានតបស្នងដល់លោកឧស្មានលើការងារដ៏ធំធេងនិងឧត្តុង្គឧត្តម!នោះគឺជាការងាររៀបចំគម្ពីរអាល់គួរអានដ៏ពិសិដ្ឋ។ ឥឡូវនេះខ្ញុំយល់ច្បាស់ហើយ ហេតុអ្វីបានជាគេហៅគម្ពីរគួរអានថាជាគម្ពីរអូស្មានី!!

**អ៊ីស្លាម:** លោកឧស្មានកូនអាហ្វាន គឺជាអគ្គរាជទូតរបស់រ៉ស៊ូលុលឡោះក្នុងកិច្ចចរចាសន្តិភាពនៅតំបន់ហ៊ូហៃប៊ីយ៉ះ។ គេបានបំផុសព័តិមានប្រឌិតថា:លោកឧស្មានត្រូវបានពួកគូរៃរ៉ៃស៍សំលាប់ ក្រោយពីពួកគេបានចាប់ខ្លួនលោកបាន៣ថ្ងៃ។

**ហ៊ូសាម :** ខ្ញុំនឹងនិយាយប្រាប់ពួកអ្នកពីរឿងមួយដ៏អស្ចារ្យរបស់លោកឧស្មាន។ រ៉ស៊ូលុលឡោះបានអំពាវនាវអោយធ្វើសច្ចាជាមួយគ្នា ណាប៊ីបានដាក់ដៃខាងស្តាំរបស់លោកលើដៃខាងឆ្វេង រួចមានប្រសាសន៏ថា: នេះគឺជាការសច្ចារបស់ឧស្មាន ពោលគឺណាប៊ីធ្វើសច្ចាជំនួសឧស្មានក្នុងពេលលោកអវត្តមាន។

## ការដឹកនាំនិងការរំដោះរបស់ឧស្មាន

**សាមីយ៉ះ:** លោកឧស្មានកូនអាហ្វានស្នងដំណែងជាមេដឹកនាំក្រោយពេលគេលួចធ្វើឃាតលោកអ៊ូម៉ើរកូនខត្តប ។

**ម៉ូហាំម៉ាត់:** មានកុលសម្ព័ន្ធជាច្រើនអំពីពួកហ្វារីស៊ី ទួរគី និងរ៉ូមបានវាយលុកទៅលើពួកមូស្លីមីន។

**អះម៉ាត់ :** លោកឧស្មានមានមោទនៈភាពដ៏ឧត្តុង្គឧត្តមក្នុងការបង្កើតប្រទេសថ្មី។

**ហ្វាទីម៉ះ** :ចាំ គឺពិតជាអញ្ចឹងមែន! លោកឧស្មានអាចមានយុទ្ធវិធីគ្រប់គ្រាន់ក្នុងការបង្ក្រាបភាពចលាចលបាន ពោលគឺជនណាហើយចង់បានសន្តិភាពលោកធ្វើអោយមានសន្តិភាពជាមួយ ហើយបើជនណាចង់ធ្វើសង្គ្រាមលោកក៏ឆ្លើយតបវិញដែរ ។លោកចេញបញ្ជាដល់មេទ័ពទាំងអស់នៅក្នុងប្រទេស ដែលកំពុងមានភាពចលាចលគឺមិនអោយពួកគេចាកចេញពីប្រទេសនោះជាដាច់ខាត គឺក្នុងបំណងកុំអោយពួកអ្នកបង្ករភាពចលាចល ដែលរត់គេចខ្លួនទាំងនោះវិលត្រលប់ទៅបង្ករភាពអមិត្តឡើងវិញ។ កងទ័ពរបស់ឧស្មានបានធ្វើការរំដោះទិសខាងកើតរហូតដល់ប្រទេសចិននិងឥណ្ឌា ទិសខាងជើងរហូតសមុទ្រអាត់តាឡង់តិចនិងខាងលិចរហូតដល់ប្រទេសអេស្ប៉ាញ។

**ម៉ាស់មូដ :** នៅពេលលេចលឺដំណឹងពីការលួចធ្វើឃាតមកលើលោកអ៊ូម៉ើរពេលនោះមានភាពភ្ញាក់ផ្អើល និងចលាចលបានកើតមានឡើងនៅឯអាហ្វ្រាហ្គីយ៉ាននិងអារម៉ានីយ៉ាស់។ ពួកគេក៏បានក្បត់កិច្ចសន្យា ហើយបានបង្កនូវការបំបាក់ស្មារតី និងធ្វើការផ្តួលរំលំមកលើបណ្តាមូស្លីមីនទៀតផង។

**អាប់ឌុររ៉ស់ម៉ាន:** ប្រទេសរ៉ូមបានធ្វើសង្គ្រាមមកលើអាស់កាន់ដារី ទាំងផ្លូវ



គោក និងផ្លូវទឹក។ គេបានបញ្ជូនកងនាវាទៅឡោមព័ទ្ធប៉ាឡេស្ទីនរួចពួកគេបានបញ្ជូនភ្នាក់ងារសំងាត់ ដើម្បីបំផុសមនុស្សអោយមានការក្បត់ និងបះបោរឡើង។

**មូសតាហ្វា:** សំលាញ់! ខ្ញុំបានដឹងថា: កប៉ាល់ដែលបានចូលរួមធ្វើសង្គ្រាមមកលើអាស់កាន់ដារីមានចំនួនច្រើនជាង៥០០កប៉ាល់ និងកងទ័ព១០០០០០នាក់។

**អះម៉ាត់ :** ខ្ញុំសូមរំលឹកថា ប្រទេសអេហ្ស៊ីបក៏បានចូលរួមជាមួយកងកប៉ាល់អ៊ីស្លាមមុនគេផងដែរ។ នៅក្នុងរបបឧស្មានមានអ្នកដឹកនាំនៅអេហ្ស៊ីបឈ្មោះលោកអាប់ឌុលឡោះកូនសាអាត់ សាអាត់កូនអាហ្គីសារ៉ស់។ លោកមេបញ្ជាការដែនសមុទ្រ លុះពេលនាវាចំបាំងរបស់ប្រទេសរ៉ូមបោះជំហានចូលមកដើម្បីធ្វើសង្គ្រាមអាស់កាន់ដារីនៅឆ្នាំ៣៤ម.ស។ ខណៈនោះនាវាចំបាំងរបស់ប្រទេសអេហ្ស៊ីបបានធ្វើដំណើរចេញស្ទាក់ពីការវាយលុករបស់ប្រទេសរ៉ូម។ ដោយឡែកលោកមូអាវីយ៉ះដែលពេលនោះលោកជាមេទ័ពប្រចាំស្រុក ស្ហាមបានបញ្ជូនកងនាវាចំបាំងក្រោមការទទួលខុសត្រូវ របស់លោកអាមីរ៉ោះបាសារី កូនអាហ្គីអើរតាអាស់អោយសហការកំលាំងជាមួយនាវាចំបាំង របស់ប្រទេសអេហ្ស៊ីបដើម្បីទប់ទល់ការវាយលុករបស់ប្រទេសរ៉ូម ។

**សើម៉ាហ៏:** ពិតណាស់ទីលានប្រយុទ្ធហ្សាទីសវ៉ារីដែលបានកើតនៅឆ្នាំ៣៤ម.សត្រូវនឹងឆ្នាំ៦៥៥គ.សបានទទួលជោគជ័យ នៃសង្គ្រាមដែនសមុទ្រដ៏ធំធេងសំរាប់ប្រជាពលរដ្ឋអារ៉ាប់ទាំងមូល។

**ម៉ាស់មូ៉ដ:** ខ្ញុំក៏បានដឹងថា: ទីលានប្រយុទ្ធនោះត្រូវបានគេស្គាល់ថាហ្វីនគីស។

## ផលិតកម្មនាវានៅប្រទេសអេហ្ស៊ីប

**ហ្វាទីម៉ះ :** មិនត្រឹមតែប៉ុណ្ណោះទេ តាមពិតប្រទេសអេហ្ស៊ីបបានផលិតនាវាជាច្រើននៅឯកោះរ៉ៅហ្ទោះដែលគេហៅថាកោះឧស្សាហកម្ម ។

**អ៊ីស្លាមៈ** អ្នកបានធ្វើការបកស្រាយលំអិតរវាងពតិមានដែលខ្ញុំបានលើកឡើងនោះតែអ្វីដែលអ្នកបានលើកឡើងវាពិសេសនិងមានប្រយោជន៏ណាស់ ។ សូមអល់ឡោះផ្តល់ភាពសុខដុមរមនាដល់រូបអ្នក ។

**អះម៉ាត់ៈ** សុំទោស! ទាំងនេះជាព័តិមានពាក់ពន្ធ័ប្រវត្តិសាស្រ្តដែលខ្ញុំបានដឹងហើយវាបានធ្វើអោយខ្ញុំពេញចិត្តបំផុត ។ ខ្ញុំចង់ចូលរួមមតិជាមួយពួកអ្នកហើយសូមពួកអ្នករួមពិភាក្សាជាមួយខ្ញុំក្នុងរឿងនោះផង ។

**ណាដា :** យើងត្រូវក្រលេកមើលទៅរឿងកងនាវាដែលបានធ្វើសង្រ្គាមមកលើមូស្លីមីន ។

**ហ្វារ៉ហ៏ះ** បេសកកម្មនេះ ប្រៀបដូចជាបេសកកម្មប្រឆាំងនឹងអ្នកបោះបង់សាសនាចោលដែរ ក៏ប៉ុន្តែឧស្មានជាមេដឹកនាំមាំមួន វាងវៃ និងរហ័សរហួនក្នុងការចាត់ចែងការងារទាំងឡាយ និងការរៀបចំតំបន់ថ្មីៗប្រកបដោយការប្រុងប្រយ័ត្ន អត់ធ្មត់និងទន់ភ្លន់ក្នុងនយោបាយទាំងជាមួយសត្រូវនិងសម្ព័ន្ធមិត្ត ។ ការឆ្លាតវៃរបស់ឧស្មាននេះ បានធ្វើអោយភាពចលាចលទាំងឡាយស្ងប់ស្ងាត់ទៅវិញ ។

**អះម៉ាត់ៈ**បងប្រុស! សូមអ្នកកុំភ្លេចថាៈកងទ័ពរបស់ឧស្មានគឺជាមិត្តសំលាញ់



(សាហាការី) ដ៏ថ្កុំថ្កើងរបស់ណាហ្ពីមូហាំម៉ាត់ ហើយពួកគេសុទ្ធតែជាអ្នកដែលមានជំនឿលើអល់ឡោះរឹងមាំបំផុត ។ការការពារសាសនា និងជំនឿពិតប្រាកដគឺរុញអោយពួកគេ បានទទួលជ័យជំនះម្តងហើយម្តងទៀតជាប់ជានិច្ច ។ ជ័យជំនះរបស់ពួកគេចាប់ពីសមរភូមិបាឌើរដល់កឌីស៊ីយ៉ាស់ ដល់តាហ្ពូក និងដល់ប៉ាប៉ាលីយូន ។យើងអាចនិយាយបានថាៈការធ្វើសង្រ្គាមរបស់ពួកមិត្តសំលាញ់របស់រ៉ស៊ូលុលឡោះប្រឆាំងនឹងហ្វូរស៊ី និងរ៉ូម គឺសាហាវជាងការធ្វើសង្រ្គាមរបស់ពួកគេ ក្នុងតំបន់អារ៉ាប់ប្រឆាំងនឹងពពួកបោះបង់សាសនាទៅទៀត ។

**ហ៊ូសាម :** ខ្ញុំនឹងនិទានរឿងប្រាប់ដល់ពួកអ្នកពាក់ពន្ធ័នៅក្នុងប្រវត្តិសាស្រ្តដែលវាបានធ្វើអោយខ្ញុំពេញចិត្តបំផុត ហើយដែលវាធ្វើអោយខ្ញុំពិចារណាយ៉ាងម៉ត់ចត់ចំពោះជំនឿដែលកើតមាននៅក្នុងដួងចិត្តរបស់ក្រុមមិត្តសំលាញ់របស់មូហាំម៉ាត់ ។ រឿងរ៉ាវនោះគឺលោកហាហ្ពីបហ្ពិនមូសាល់ឡាម៉ាស់ដែលបានធ្វើសង្រ្គាមនៅស៊ើរីនិងប៉ាឡេស្ទីន ។ពេលនោះលោកហាហ្ពីបហ្ពិនមូសាល់ឡាម៉ាស់មានកំលាំងជំនួយពីម៉ាឌីណះ និងក៏រង់ចាំជំនួយមកពីអាល់គូហ្វះដែរតែកំលាំងនោះមានការយឺតយ៉ាវក្នុងការមកដល់ លុះពេលពួករ៉ូមបានសំរុកមកកងកំលាំងរបស់លោកហាហ្ពីបហ្ពិនមូសាល់ឡាម៉ាស់បានសំលាប់ពួកនោះ អស់ជាច្រើននៅទីបញ្ចប់ពួកគេបានយកជ័យជំនះលើពួករ៉ូម ។

**សើម៉ាហ៏ៈ**ប្រសើរជាងនេះទៀត គឺភរិយាលោកហាហ្ពីបហ្ពិនមូសាល់ឡាម៉ាស់បានសួរប្តីខ្លួនថាៈ តើទិសដៅណាត់នៅទីណា? លោកឆ្លើយថាៈគឺនៅឯជំរុំធំឈ្មោះមូរីយ៉ានតែបើស្លាប់គឺឋានសួគ៌ ។

ជាចុងក្រោយលោកហាហ្គីបហ្គិនមូសាល់ឡាម៉ាស់ បានឃើញប្រពន្ធរបស់ខ្លួនបានទៅដល់ជំរុំមុន លោកទៅទៀត ។

**ម៉ាស់ម៉ូដ :** ក្រោយមកលោកឧស្មានបានបើកការវាយលុកតំបន់គុបរុស រូឌុសដើហ្សៀរ សមុទ្ររ៉ូម និងបានធ្វើការឡោមព័ទ្ធតំបន់អេហ្ស៊ីប ស្វាមនិងតំបន់កៃរូវ៉ាន ។

## ប្រវត្តិនៃការដឹកនាំរបស់ឧស្មាន

**ឪពុក:**ឧស្មានបានផ្ញើលិខិតជូនពួកចៅហ្វាយខេត្ត ពួកមេទ័ព មេដឹកនាំគ្រប់ជាន់ថ្នាក់និងអ្នកគ្រប់គ្រងសម្បត្តិរួមរបស់អ៊ីស្លាមអោយយកចិត្តទុកដាក់ខ្ពស់បំផុតក្នុងរឿងសឡាហ៍( ការថ្វាយបង្គំ៥ពេលក្នុងមួយថ្ងៃ) ព្រមទាំងបានណែនាំពួកគេអោយបំពេញតួនាទីជាអ្នកប្រើមនុស្សអោយធ្វើល្អ និងហាមឃាត់ពួកគេកុំអោយធ្វើអំពើអាក្រក់និងជំរុញអោយអ្នកដែលនៅក្រោមឱវាទទាំងអស់គោរពប្រតិបត្តិអល់ឡោះ និងរ៉ស៊ូលរបស់ទ្រង់ហើយត្រូវបោះបង់អោយខាងតែបានចំពោះអំពើបង្កើតថ្មីនៅក្នុងសាសនាអ៊ីស្លាមទាំងអស់ ។

**ហ្ស៊ីយ៉ាដ:**បងប្អូនទាំងអស់គ្នា! ខ្ញុំបានអានឯកសារមួយបានបង្ហាញថា: លោកឧស្មានបានប្រើអោយគេធ្វើម្ហូបឆ្ងាញ់ៗសំរាប់ចែកអ្នកអៀកទីកាហ្វអ្នកគោរពសក្ការ: និងអ្នកធ្វើដំណើរដែលដាច់ស្បៀង ។

**កូនៗ :** អល់ឡោះជាម្ចាស់ អស្ចារ្យណាស់!

**ណាដា :** ក្នុងចំណោមការងាររបស់លោក ដែលត្រូវបានគេកត់ត្រាក្នុងប្រវត្តិ



សាស្ត្រដែលមានពន្លឺនិងមានប្រយោជន៍បំផុតនោះគឺគម្ពីរអាល់គួរអានឧស្មានីដូចដែលយើងបានរៀបរាប់កន្លងមក ។

**ហ្វាទីម៉ះ:** ហើយក្នុងនោះផងដែរ គឺលោកបានដោះស្រាយព្រឹត្តិការណ៍ផ្សេងៗដែលបានកើតឡើងបន្ទាប់ពីការដោះស្រាយចំពោះភាពចលាចលនៃពពួកក្បត់សាសនាអ៊ីស្លាម ។

## ការរំដោះនៅគុបរីស

**ហ៊ីសាម** :ក្នុងការរំដោះកុបរីស ដែលវាជាតំបន់កោះ ដូចដែលយើងបានដឹង ។ ខ្ញុំសូមធ្វើការរំលឹកអោយពួកអ្នកបានស្តាប់ពីហាហ្ទីសរបស់ណាហ្គីជាមួយនឹងមិត្តសំលាញ់ដ៏ឧត្តុង្គឧត្តមរបស់លោក គឺអ្នកស្រី អ៊ុម្មីហារ៉ម កូនស្រីមូលហាន ។ ដែលណាហ្គីធ្លាប់សំរាកនៅផ្ទះរបស់គាត់លុះពេលណាហ្គីក្រោកពីដំណេកលោកសើចពេលនោះអ្នកស្រីបានសួរណាហ្គីពីរឿងសើចរបស់លោកណាហ្គីប្រាប់ថា: រូបខ្ញុំត្រូវបានគេបង្ហាញអោយឃើញប្រជានុរាស្ត្ររបស់ខ្លួនមួយក្រុមដែលបានធ្វើសឹកសង្គ្រាមដើម្បីបុព្វហេតុមាគ៌ាអល់ឡោះ ។ ពួកគេបានជិះលើសំពៅជាស្តេចនៅគ្រែស្នែងក្នុងសមុទ្រនេះ( ទឹករលកធំៗ) ឬប្រៀបបាននឹងស្តេចនៅលើគ្រែស្នែង ។ពេលនោះអ្នកស្រីបានសុំរ៉ស៊ូលុលឡោះ ថា:ឱរ៉ស៊ូលុលឡោះ!ជួយសុំពីអល់ឡោះអោយរូបខ្ញុំបានស្ថិតនៅជាមួយពួកគេផងណាហ្គីមានប្រសាសន៍ថា:អ្នកស្រីជាមនុស្សក្នុងចំណោមពួកគេដែរ ។ សេចក្តីរាយការណ៍ផ្សេងទៀតបានបញ្ជាក់ថា:អ្នកស្រីក្នុងចំណោមអ្នកឈានមុខគេ ។ អ្នកស្រីអ៊ុម្មីហារ៉មដែលជាភរិយាមិត្តសំលាញ់របស់ណាហ្គីម្នាក់ឈ្មោះអ៊ុហ្គើហ្ទះ

កូនសម៉ាត់ដែលបានទទួលមរណៈភាពនៅទីនោះ(គុបរីស)ហើយបានកប់នៅទីនោះតែម្តង ដែលគេដាក់ឈ្មោះថា "ផ្នូរស្ត្រីដ៏ស្អាតស្អំ" ។

**អ៊ីស្លាមៈ** ពពួកម៉ាឡើអ៊ីកាហ៍មានការខ្មាស់អៀនចំពោះលោកឧស្មាន នេះគឺអ្វីដែលណាហ្គីបានប្រាប់ពួកយើង ។

**អាប់ឌុររ៉ស់ម៉ាន :** លោកឧស្មានជាមេបញ្ជាការម្នាក់ដែលបានរៀបចំកងទ័ពបានឧបត្ថម្ភក្នុងបុព្វហេតុមាគ៌ារបស់អល់ឡោះ និងជាអ្នកជំនួញម្នាក់ដែលទទួលបានជោគជ័យយ៉ាងធំធេង ។

**ឪពុកៈ** ជីវប្រវត្តិរបស់មេដឹកនាំដ៏កំពូលអ៊ីស្លាម គឺលោកឧស្មានកូនអាហ្វានដែលពួកយើងបានឆ្លងកាត់មកនេះ គឺយើងបានទទួលស្គាល់ថាៈ លោកបានប្រឈមមុខនឹងភាពវឹកវរធំៗរហូតត្រូវគេធ្វើឃាតក្នុងនាមជាមេដឹកនាំកំពូលរបស់អ៊ីស្លាម ។

**ណាដាៈ** ទីបញ្ចប់នៃប្រវត្តិរបស់លោកឧស្មានដែលជាមេដឹកនាំជំនាន់ទីពានៃសាសនាអ៊ីស្លាមនេះ ពួកយើងទាំងអស់នាំគ្នាបួងសួងថាៈ " ឱអល់ឡោះ! ជាម្ចាស់សូមទ្រង់ផ្តល់ផលប្រយោជន៍ដល់ពួកយើងពីគម្ពីរ អាល់គួរអានផងចុះ ហើយសូមឱ្យគម្ពីរ អាល់គួរអានជាជំនួយការពារពួកយើងនាថ្ងៃកាត់ក្តីផងចុះ សូមអល់ឡោះទទួលយកនូវសំណូមពរនេះផង!



## អាលីកូនអាហ្គូតលិបមេដឹកនាំអ៊ីស្លាមទី៤

(៣៥-៤០ ម.ស/៦៥៦-៦៦០គ.ស)

**អះម៉ាត់ :** ថ្ងៃនេះគឺជាថ្ងៃដែលមានរស្មីត្រចះត្រចង់ល្អណាស់ដោយការលើកយកមេដឹកនាំទី៤មកបង្ហាញគឺលោកអាលីកូនអាហ្គូតលិប ។

**ម៉ាស់ម៉ូដៈ** លោកគឺអាលីកូនអាហ្គូតលិប អាហ្គូតលិប កូនអាប់ឌុលមូតល់លិប អាប់ឌុលមូតល់លិបកូនហ៊ូសាម ។ ម្តាយរបស់លោកឈ្មោះហ្វាទីម៉ះកូនស្រីអាសាត់ អាសាត់កូនហ៊ូសាម ។ លោកស្រីបានចូលសាសនាអ៊ីស្លាម និងបានធ្វើការភៀសខ្លួនទៅកាន់ម៉ាឌីណះផងដែរ ។

**ហ្វាទីម៉ះ :** ខ្ញុំចង់និយាយប្រាប់ពួកអ្នកមុនខ្ញុំភ្លេចទៅវិញថាៈនៅពេលដែលលោកស្រីហ្វាទីម៉ះកូនស្រីអាសាត់ដែលត្រូវជាម្តាយរបស់លោកអាលីកូនអាហ្គូតលិបទទួលមរណៈភាពរ៉ស៊ូលុលឡោះបានយកអាវរបស់លោកពាក់អោយលោកស្រីហើយរ៉ស៊ូលុលឡោះបានចុះក្នុងផ្នូររបស់លោកស្រី ដើម្បីរៀបចំសពជូនលោកស្រីទៀតផង ។ ក្រោយមកមានគេសួរណាហ្គីថាៈ ហេតុដូចម្តេចបានជាលោកធ្វើដូចនេះ?លោកមានប្រសាសន៏ថាៈ ប្រាកដណាស់ ខ្ញុំបានពាក់អាវរបស់ខ្ញុំជូនសពលោកស្រី ដើម្បីអោយលោកស្រីបានពាក់សំលៀកបំពាក់របស់ឋានសួគ៌ហើយខ្ញុំចូលនៅក្នុងផ្នូរនោះដើម្បីផ្តល់ភាពងាយស្រួលដល់លោកស្រី

**មូសតហ្វាៈ** ខ្ញុំបានអានឯកសារប្រវត្តិ បញ្ជាក់ថាៈ ម្តាយរបស់អាលីបានដាក់ឈ្មោះអោយលោកថាៈ"ហ៊ីដរ៉ោះ" តែក្រោយមក ឪពុករបស់លោក បានប្តូរឈ្មោះនេះទៅជា "អាលី " វិញ ។

**ហ៊ូសាម** : លោកអាលីត្រូវជាជីដូនមួយនឹងរ៉ស៊ូលុលឡោះ ហើយបានរៀបអាពាហ៍ពិពាហ៍ជាមួយកូនស្រីរបស់រ៉ស៊ូលុលឡោះឈ្មោះហ្វាទីម៉ះ។ អ្នកទាំងពីរទទួលបានកូនប្រុសចំនួនពីរនាក់ គឺអាល់ហាសាន់ និង អាល់ហ៊ូសេនដែលអ្នកទាំងពីរនាក់នេះ គឺជាសមាសភាពត្រូវចូលឋានសួគ៌។ អាលីកាលពីក្មេងបានចូលសាសនាអ៊ីស្លាមមុនគេក្នុងចំណោមក្មេងៗទាំងឡាយហើយទទួលបានការបណ្តុះបណ្តាលនៅផ្ទះរ៉ស៊ូលុលឡោះ។

**អ៊ីស្លាម** : (ក្រោកឈរហើយនិយាយថា )បងបប្អូនទាំងអស់គ្នាខ្ញុំមានបំនងនិយាយប្រាប់អ្នកទាំងអស់គ្នានូវរឿងមួយដែលខ្ញុំបានដឹង ហើយខ្ញុំចង់រៀនសូត្រតាមគំរូដែលខ្ញុំទទួលបានពីការអានរបស់ខ្ញុំយ៉ាងច្រើននេះ។

**កូន១** : (ពួកគេក៏សួរថា) តើអ្នកបានអានអ្វី? ហើយបានដឹងពីអ្វីខ្លះ ?

**អ៊ីស្លាម** :គឺប្រវត្តិអណ្តូងទឹកហ្សុំហ្សុំ( អណ្តូងដែលនៅជាប់នឹងកាក់ហ្ពះ) ។

**កូន១**: ពួកយើងបានដឹងខ្លះៗហើយ តើអ្នកមានអ្វីថ្មីទៀតដែលយើងមិនទាន់ដឹងឬ? ឬក៏អ្នកចង់និទានអោយពួកយើងស្តាប់ពីការផុសទឹកចេញខាងក្រោមជើងរបស់ណាហ្ពីអ៊ីស្មាអែល ខណៈពេលដែលយើងកំពុងនិយាយ អំពីប្រវត្តិរបស់លោកអាលីនោះ?

**អ៊ីស្លាម** :ទេ ! តាមពិតខ្ញុំចង់និទានអំពីអ្នកជីកវា។ ពិតណាស់ គឺលោកអាប់ឌុលមូតល់លិប កូនហ៊ូសាម ត្រូវជាជីតារបស់ណាហ្ពីហើយក៏ជាជីតារបស់អាលី ដែរ។ នៅរាត្រីមួយអាប់ឌុលមូតល់លិបបានសុបិន្តឃើញថា: មានគេ



ប្រាប់គាត់ថា:ចូរអ្នកជីកទីកន្លែងដ៏ប្រពៃ។ នៅរាត្រីទីពីរបានមកប្រាប់ទៀតថា: ចូរអ្នកជីកដីចុះ។ នៅរាត្រីទីបីសំលេងនោះក៏មកប្រាប់ទៀតថា: ចូរអ្នកជីកអណ្តូងហ្សុំហ្សុំ ។ អាប់ឌុលមូតល់លិបក៏សួរថា:តើហ្សុំហ្សុំជាអ្វី ? សំលេងនោះក៏ឆ្លើយថា:វាជាអណ្តូងទឹកដែលហូរមិនចេះអស់ និងមិនមានការខកខាន ក្នុងការផ្តល់ទឹកដល់បណ្តាអ្នកធ្វើហាជ្ជីដ៏ឧត្តម។

**ឪពុក** : សូមអល់ឡោះបង្ហាញផ្លូវដល់រូបអ្នក! វាគឺជាចំណេះដឹងដ៏ល្អប្រពៃបំផុត។ ពេលនេះយើងត្រឡប់មកប្រវត្តិរបស់មេដឹកនាំទី៤ វិញពីប្រវត្តិចូលអ៊ីស្លាមនិងការដង្ហែរតាមណាហ្ពីមូហាំម៉ាត់របស់លោកអាលីយ៉ាងណានោះ?

**អាប់ឌុររ៉ស់ម៉ាន** : អាលីបានរស់នៅក្នុងលំនៅដ្ឋានរបស់ណាហ្ពី ដោយកាលនោះពួកគូរ៉ៃស៍ធ្វើទុក្ខបុកម្នេញយ៉ាងខ្លាំង។ អាហ្ពូតលិបមានកូនជាច្រើន។ អាប់ហ្គាសដែលជាមារបស់ណាហ្ពីបានយកជាក់ហ្វើតមកនៅជាមួយ ចំណែកណាហ្ពីយកអាលីមកនៅជាមួយដែរ។

**អាប់ឌុលឡោះ** : ក្រោយមករស្មីអ៊ីស្លាមបានលេចឡើងនៅក្រុងម៉ាក្កះ។ ប្រជាជននៅទីនោះមានអ្នកដែលមានជំនឿ ហើយអាលីជាអ្នកមានជំនឿដំបូងគេបង្អស់ក្នុងចំណោមក្មេងៗ។

## ការកៀសខ្លួនរបស់ណាហ្ពី

**អ៊ីស្លាម** : ខ្ញុំនឹងចែករំលែកចំណេះដឹងថ្មីៗ ដែលខ្ញុំទើបតែបានអានប៉ុន្មានថ្ងៃមុននេះ។

**កូន១ :** អញ្ចឹង! សូមផ្តល់អ្វីដែលអ្នកដឹងមកចុះ។

**អ៊ីស្លាម :** ពួកគូរ៉ៃស៊ីបានប្រមូលផ្តុំគ្នានៅទីជំនុំនាថ្ងៃមួយដែលគេហៅថាថ្ងៃហ៊្សេះម៉ះ។ បីសាចបានសំដែងខ្លួនជាមនុស្សចំណាស់ម្នាក់មកជួបពួកគេ។ វាបានឈរនៅមាត់ទ្វារជំនុំ ហើយពួកគេបានសួរថាៈ អ្នកជានរណា? បិសាចបានឆ្លើយតបវិញថា : ខ្ញុំជាមុនស្សចាស់ម្នាក់មកពីអ្នកស្រុកណាច់ឌិន ខ្ញុំបានទទួលដំណឹងពីក្តីបំណងរបស់ពួកអ្នកក្នុងការរៀបចំគំរោងសំលាប់មូហាំម៉ាត់ រួចវាបានចូលមកអង្គុយជាមួយក្រុមទាំងនោះទៅ។

**ណាដា :** នេះជារឿងថ្មីសំរាប់ខ្ញុំមែន ស្តីពីរឿងបិសាចដែលបង្ហាញខ្លួនជារូបភាពមនុស្សចាស់មកពីណាច់ឌិន ដោយរៀបគំរោងបំផ្លាញការអំពាវនាវត្រឹមត្រូវ និងការសំលាប់រ៉ស៊ូលុលឡោះ។

**ម៉ាស់ម៉ូដ :** អ៊ីស្លាម! ក្រោយមកតើមានព្រឹត្តិការណ៍អ្វីកើតឡើងទៀត? អ្នកត្រូវតែបញ្ចប់រឿងនោះអោយពួកយើងបានដឹងផង។

**អ៊ីស្លាមៈ** ពួកគូរ៉ៃស៊ីបានឯកភាពគ្នាថាៈ ត្រូវជ្រើសរើសយកយុវជនម្នាក់ពីគ្រប់កុលសម្ព័ន្ធក្រោយមកបញ្ជាអោយពួកយុវជនទាំងនោះ សំលាប់រ៉ស៊ូលុលឡោះ។ ពួកគេពន្យល់ប្រាប់ថាៈ យើងធ្វើដូចនេះ ដើម្បីអោយការទទួលខុសត្រូវធ្លាក់ទៅលើកុលសម្ព័ន្ធទាំងអស់ ហើយបក្ខពួកណាហ្ពីមិនអាចធ្វើសង្គ្រាមមកលើគ្រប់កុលសម្ព័ន្ធឡើយ ។ពេលនោះបិសាចដែលកំពុងអង្គុយ ក្នុងជំនុំដែរនោះបានគាំទ្រទស្សនៈនេះ ដែលវាជាទស្សនៈរបស់អាហ្ពូហាកិម គឺអាំរូកូនហ៊ូសាម។ ក្រោយមកពួកគេក៏បែកខ្ញែកគ្នាអស់ទៅ។ អល់ឡោះក៏បញ្ជូន



ម៉ាឡាអ៊ីកះមកប្រាប់ណាហ្ពី ដែលទទួលបានការចង្អុលបង្ហាញពីអល់ឡោះ ដោយបញ្ជាក់ប្រាប់ណាហ្ពីថាៈយប់នេះកុំដេកលើគ្រែរបស់អ្នកអោយសោះនិងបានប្រាប់ណាហ្ពី ពីការតាំងចិត្តសំលាប់ណាហ្ពីពីសំណាក់ពួកគូរ៉ៃស៊ី ហើយអល់ឡោះបានអនុញ្ញាតអោយណាហ្ពីធ្វើការភៀសខ្លួន។

**អាប់ឌុររ៉ស់ម៉ានៈ**( បាននិយាយកាត់) ឱបងប្អូន ! ឥឡូវនេះខ្ញុំបានយល់ហើយនូវអ្វីដែលអ្នកបាននិទានប្រាប់ពួកយើងនោះពីព្រោះតែអ្នកបានប្រាប់ពួកយើងអំពីសេចក្តីក្លាហាន និងចិត្តសប្បុរសរបស់ អាលី កូនអាហ្ពូតលិប ខណៈពេលដែលគាត់បានប្រតិបត្តិតាមបញ្ជារ៉ស៊ូលុលឡោះ ហើយបានដេកលើគ្រែរបស់រ៉ស៊ូលុលឡោះនោះ។

**ហ្វាទីម៉ះ :** ត្រឹមត្រូវហើយ! រ៉ស៊ូលុលឡោះបានប្រើអាលីថាៈ" ចូរអ្នកដេកលើគ្រែរបស់ខ្ញុំ។ ពួកគេមិនអាចធ្វើអ្វីមកលើរូបអ្នកឡើយ ព្រោះអល់ឡោះជាអ្នកការពាររូបអ្នកពីសត្រូវ "។

**អ៊ីស្លាមនិយាយបន្ត :** នៅពេលយប់ពួកគេបានឡោមពទ្ធ័ជុំវិញលំនៅដ្ឋានរបស់ណាហ្ពី។ ពេលនោះអាហ្ពូជើហ៊ុលបាននិយាយប្រាប់យុវជនទាំងនោះថាមូហាំម៉ាត់បានអះអាងថា អ្នកទាំងអស់គ្នា បើមិននាំគ្នាគោរពតាមគាត់ទេពួកអ្នកនឹងត្រូវគេបញ្ចូលទៅក្នុងឋាននរក និងត្រូវគេដុតនៅក្នុងភ្លើងនោះ។ ណាហ្ពីបានយកដីមួយក្តាប់ទៅរោយលើក្បាលពួកយុវជនទាំងនោះ។ អល់ឡោះបានបំបិតភ្នែកនិងត្រចៀករបស់ពួកគេ ដែលធ្វើអោយយុវជនទាំងនោះមើលលោកមិនឃើញនិងមិនលឺស្នូរសើរបជើងលោកសោះឡើយ ។លោក

បានធ្វើដំណើរទៅកាន់លំនៅដ្ឋានអាហ្គូហ្គាកើរដែលអ្នកទាំងពីរត្រូវធ្វើបំលាស់ទីជាមួយគ្នា ។លុះពេលណាហ្គីនិងអាហ្គូហ្គាកើរទៅដល់រូងភ្នំហ៊ីរ៉ក ហើយអ្នកទាំងពីរក៏ចូលទៅក្នុងរូងនោះ ។

**ម៉ាស់ម៉ូដះ** ពួកមូសរីគីនបានស្វែងរកណាហ្គីនិងអាហ្គូហ្គាកើររហូតទៅដល់មាត់រូងភ្នំហ៊ីរ៉ក់ តែពួកគេមិនបានឃើញណាហ្គីនិងអាហ្គូហ្គាកើរឡើយ ។

**អាប់ឌុររ៉ស់ម៉ាន :** សូត្រអាយ៉ាត់គួរអានជំពូកតាវហ្ប៉ត វាក្យខ័ណ្ឌ៤0ដែលមានន័យថា:"បើពួកអ្នកមិនបានជួយមូហាំម៉ាត់ទេ គឺអល់ឡោះជួយលោក (មូហាំម៉ាត់) នៅពេលដែលពួកប្រឆាំងបានបណ្តេញពួកគេទាំងពីរនាក់ (ណាហ្គីនិងអាហ្គូហ្គាកើរ) ចេញ ។ លុះពេលអ្នកទាំងពីរនៅក្នុងរូងភ្នំ ពេលនោះណាហ្គីបាននិយាយទៅកាន់អាហ្គូហ្គាកើរថា: អ្នកកុំព្រួយបារម្ភ ព្រោះអល់ឡោះមើលឃើញនិងជួយយើង ពេលនោះអល់ឡោះបានបញ្ចុះភាពលំនឹងក្នុងចិត្តដល់ណាហ្គី ។

**ម៉ាស់ម៉ូដះ** ឥឡូវនេះយើងត្រូវវិលទៅរកប្រវត្តិរបស់លោកអាលីកូនអាហ្គីតលិបវិញបន្ទាប់ពីពួកយើងបានរំលឹកពីការបំលាស់ទីរបស់ណាហ្គីហើយនោះ ។

**ហ្វាទីម៉ះ :** ពួកយើងចង់ដឹងណាស់ថា: តើវាមានហេតុអ្វីនៅពេលដែលពពួកគូរ៉ៃស៍បើកទ្វារផ្ទះណាហ្គីនៅពេលព្រឹក ពួកគេបានឃើញអ្នកដែលកំពុងដេកលើគ្រែណាហ្គី គឺជាអាលីកូនអាហ្គូតលិបទៅវិញ!

**ហ្វាទីម៉ះ :** នៅក្នុងកាលៈទេសៈនោះ គឺអាលីកូនអាហ្គូតលិបជាអ្នកដេកនៅលើគ្រែរបស់ណាហ្គី ។



**ហ៊្សុយ៉ាដះ**(និយាយទៅកាន់ហ្វាទីម៉ះ )បងស្រី ! តើពាក្យសំដីក្នុងប្រសាសន៍របស់ណាហ្គី ពោលទៅកាន់អាលីមានន័យដូចម្តេចនៅត្រង់ឃ្លាថា: (ចូរអ្នកពាក់អាវរងាររបស់ខ្ញុំហើយសូមអ្នកដេកចុះអ្នកនឹងមិនត្រូវខ្លាចអ្វីទាំងអស់ ។ រូបអ្នកត្រូវបានការពារដោយការការពារពីអល់ឡោះ) ។ ណាហ្គីបានសំណូមពរអោយអាលីស្នាក់នៅម៉ាក្កះរហូតទាល់តែគេអាចយកកម្មសិទ្ធ(ឥវ៉ាន់ឬទ្រព្យសម្បត្តិដែលផ្ញើទុកជាមួយណាហ្គី) ផ្សេងៗរបស់បុគ្គលទៅអោយម្ចាស់គេវិញដែលប្រការទាំងនេះនៅចំពោះរ៉ស៊ូលុលឡោះដ៏សច្ចៈ និងទៀងត្រង់បំផុត ។

**មូហាំម៉ាត់ :** អាលីមានជំហរលះបង់ខ្ពស់ណាស់ ។ លុះពេលដែលពួកគូរ៉ៃសបានដឹងថា ពួកគេត្រូវបានក្បត់ហើយនោះ ពួកគេនាំគ្នាធ្វើបាបលោកអាលីតែអាលីមិនបារម្ភពីពួកនោះឡើយ រហូតលោកបានផ្តល់កម្មសិទ្ធបុគ្គលដល់ម្ចាស់ដើមគេវិញក្នុងបីថ្ងៃក្រោយមក បន្ទាប់មកលោកបានធ្វើបំលាស់ទីទៅម៉ាឌីណាស់តែម្នាក់ឯង ។

**អះម៉ាត់ :** ណាហ្គីបានចងសម្ព័ន្ធមិត្តរវាងពួកដែលភៀសខ្លួនមកពីក្រុងម៉ាក្កះជាមួយនឹងអ្នកស្រុកនៅម៉ាឌីណះ ។

**ហ៊្សុយ៉ាដ :** ខ្ញុំដូចជាមិនទាន់យល់ច្បាស់សាច់រឿងនៅឡើយ?!

**អះម៉ាត់ :**គេចង់និយាយថា: រាល់ពួកអ្នកធ្វើបំលាស់ទីគ្រប់ៗរូបត្រូវបានណាហ្គីប្រើអោយចងសម្ព័ន្ធមិត្តជាបងប្អូនចិត្តមួយថ្លើមមួយ ជាមួយពួកអាន់សរ៍ដើម្បីអោយមានការគាំទ្រដល់ការផ្សព្វផ្សាយរបស់ណាហ្គី ។ អ្នកស្រុកម៉ាឌី

ណេះបានស្វាគមពួកធ្វើការបំលាស់ទីដោយក្តីរីករាយបំផុត និងបានលើកតំកើងដល់ពួកគេ រហូតដល់មានអ្នកស្រុកម៉ាឌីណាស់ខ្លះ បានចែករំលែកសម្បត្តិផ្ទាស់ខ្លួនអោយដល់បងប្អូនរបស់ខ្លួនដែលបានផ្លាស់ទីមក។

**ហ៊្សីយ៉ាដ:** អ្នកបានភ្លេចមិនទាន់បានរំលឹកប្រាប់ពួកយើងត្រង់ចំនុចថា ណាហ្គីបានមានប្រសាសន៏ថា:( នេះជាបងប្អូនរបស់ខ្ញុំ) គឺសំដៅទៅលើលោកអាលី ។

## អាពាហ៍ពិពាហ៍អាលីជាមួយហ្វាទីម៉ះអាហ្សះរ៉ក៏

**ហ៊ូសាម :** ខ្ញុំបានអានជួបប្រសាសន៏របស់ណាហ្គីដែលមានខ្លឹមសារថា :( អល់ឡោះពិតជាបានបង្គាប់ប្រើខ្ញុំអោយរៀបការកូនស្រីរបស់ខ្ញុំហ្វាទីម៉ះ ជាមួយអាលី ហើយខ្ញុំសូមធ្វើជាសាក្សីថាពិតណាស់ខ្ញុំបានរៀបការហ្វាទីម៉ះ ជាមួយអាលី )។ ណាហ្គីបានមានប្រសាសន៏ទៅកាន់ហ្វាទីម៉ះជាកូនស្រីរបស់លោកដែលមានន័យថា:( ឪពុកស្បថនឹងអល់ឡោះជាម្ចាស់ថា ពិតណាស់ឪពុកបានរៀបការកូនជាមួយបុរសម្នាក់ដែលមានវិជ្ជាខ្ពង់ខ្ពស់ អាកប្បកិរិយាសុភាព រាបសារ ទន់ភ្លន់ ហើយជាអ្នកដែលបានចូលសាសនាអ៊ីស្លាមមុនគេ )។

## បុត្រាបុត្រីរបស់អាលី និងលោកស្រីហ្វាទីម៉ះ

**ហ្វាទីម៉ះ :** លោកស្រីហ្វាទីម៉ះមានបុត្រជាមួយអាលី គឺហាសាន់ ហ៊ូសេន មូស៊្សីន ហៃ្សនាប់ និងអ៊ុម្មីកាល់ស៊ូម ។

**ណាដា :** ហាសាន់មានឈ្មោះដើមរបស់គេ គឺ"ហារ៉ប់"។ ណាហ្គីបានប្តូទៅជាហាសាន់វិញ។ ឯមូហ្ស៊ីនគេបានទទួលមរណភាពតាំងពីគេនៅតូច។ រ៉ស៊ូលុលឡោះស្រលាញ់កូនរបស់អ្នកស្រីហ្វាទីម៉ះ និងលោកអាលីបំផុត។ ណាហ្គីត្រូវឱនស៊ូជូត( ឱនក្រាបគោរពអល់ឡោះនៅក្នុងសឡាហ៏) អោយយូរដោយសារតែកូនរបស់អាលី និងហ្វាទីម៉ះម្នាក់បានជិះលើស្មារបស់លោកដូចនេះលោកត្រូវតែស៊ូជូតអោយយូរ ។ពេលមួយណាហ្គីត្រូវបង្ខំចិត្តចុះពីលើមិមហ្ពើរ ( ទីខ្ពស់នៅក្នុងម៉ាស្ជិតសំរាប់អានសុន្ទរកថាថ្ងៃសុក្រ) នៅពេលដែលលោកគ្រលេកឃើញចៅរបស់លោកគឺហាសាន់ និងហ៊ូសេនដើរជិតធ្លាក់ លោកក៏ចុះមកពរក្មេងទាំងពីរ ព្រមទាំងវាចារតាមសំដីរបស់អល់ឡោះថា: ពិតណាស់ទ្រព្យសម្បត្តិនិងកូនចៅរបស់ពួកអ្នកគឺជាភាពចលាចល។ ពេលណាណាហ្គីបានលឺចៅរបស់គាត់ណាម្នាក់ក្នុងចំណោមចៅទាំងពីរស្រែកយំ លោកតែងតែហៅហ្វាទីម៉ះ ហើយមានប្រសាសន៏ទៅកាន់ហ្វាទីម៉ះថា:" កូនដឹងទេថា:ការយំរបស់គេនាំអោយយើងមានការឈឺចាប់ក្នុងចិត្ត។

**ហ្វារ៉ស់:** នៅក្នុងសមរភូមិអ៊ូហ៊ុត ពួកអារ៉ាប់គូរ៉ៃស៏ បានឡោមព័ទ្ធហ្វាទីម៉ះ ហើយពួកគេចេញទៅសងសឹកដោយសារការសំលាប់ពួកគេកាលសង្គ្រាមនៅបាឌើរ ដែលពេលនោះអ្នកកាន់ទុងជ័យគឺម៉ាស់អាប់ កូន អ៊ូម៉ៃរ។

**អះម៉ាត់ :** បងប្អូនទាំងអស់គ្នា ទង់គឺជាសញ្ញាមួយដែលគេសរសេរពាក្យ لاإله إلا الله محمد رسول الله មានន័យថា: គ្មានទេម្ចាស់ផ្សេង ដែលត្រូវគេគោរពដ៏ពិតប្រាកដគឺមានតែអល់ឡោះ ហើយលោកមូហាំម៉ាត់ ជាសាវ៉កឹរបស់អល់ឡោះ )។

**ម៉ាស់ម៉ូដ :** ទង់ មានន័យថា:"សញ្ញាមួយ"។

**អ៊ីស្លាម :** ”រ៉ស៊ូលុលឡោះបានស្រែកហៅអាលីនៅពេលដៃម្ខាងកាន់ទង់ជ័យ និងដៃម្ខាងទៀតកាន់ដាវ ។

**មូសតាហ្វា :** ឱ បងប្អូន! ទុកអោយខ្ញុំបញ្ចប់រឿងនេះ ។ អ្នកបានឃើញហេតុការណ៍នៅខាងមុខខ្ញុំវាដូចជារូបខ្ញុំស្ថិតនៅលើទឹកដីសមរភូមិដែរ ។ ពេលនោះអ្នកកាន់ទង់របស់ពួកមូសរិគីនស្រែកសួរឡើងថា: ” តើពួកអ្នកឬដែលបានអះអាងថា: បើពួកអ្នកឯងស្លាប់នឹងត្រូវចូលឋានសួគ៌ តែបើពួកយើងស្លាប់នឹងត្រូវចូលឋាននរក”? ។ បើគ្រាន់បើចេញម្នាក់មកតតាំងជាមួយអាញ់ ! ពេលនោះអាលីដែលជាអ្នកក្លាហានបានស្រែកឡើងថា: ខ្ញុំជាអ្នកចូលទៅរកឯងមុនគេ ឱអាហ្ពីសាអាត់កូនអាហ្ពើតល់ហះ! ។ អ្នកទាំងពីរក៏ចាប់ផ្តើមប្រយុទ្ធគ្នា ខណៈនោះអាលីកាប់តែមួយដាវ សាអាត់បានធ្លាក់មកដល់ដីអាលីមានបំណង់កាប់មួយដាវទៀត តែភ្នែករបស់លោកបាំងមើលសាអាត់មិនឃើញ ហើយសាអាត់រត់គេចបាត់ទៅ ។

## សង្គ្រាមនៅខៃហ្ពើរ

**អ៊ីស្លាម:** សំលាញ់ឥឡូវនេះយើងងាកទៅមើលសង្គ្រាមនៅខៃហ្ពើរម្តង គឺលោកអាលីជាវីរៈបុរស ជាអ្នកជំនាញខាងជិះសេះ និងជាអ្នកប្រយុទ្ធដ៏អង់អាចក្លាហានបំផុត ។ នៅពេលដែលអាំរូហ្ពិនអាប់ឌូវ៉ាត់ឌិន បានប្រកាសហៅអ្នកមូស្លីមីនថា:នរណាមួយចង់ប្រយុទ្ធជាមួយអាញ់? លោកអាលីបានឆ្លើយថា: ឱ”រ៉ស៊ូលុលឡោះ! ទុកអោយខ្ញុំចេញទៅរកវា? ”រ៉ស៊ូលុលឡោះបានអោយអាលីអង្គុយចុះ ។អាំរូហ្ពិនអាប់ឌូវ៉ាត់ឌិនបានប្រកាសហៅលើកទីពីរទាំងកំហឹងថា: មានមនុស្សប្រុសចង់ប្រយុទ្ធជាមួយអាញ់ទេ? ក្រែងពួកអ្នកអួតថាបើពួកអ្នកត្រូវគេសំលាប់ពួកអ្នកនឹងត្រូវចូលឋានសួគ៌មែនទេ? ពេលនោះអាលីបានសុំណាហ្ពីថា:ឱ”រ៉ស៊ូលុលឡោះ!ទុកវាអោយខ្ញុំ?ណាហ្ពីមានប្រសាសន៏ ទៅកាន់អាលីថា:ចូរអង្គុយអោយស្ងៀមអាលីព្រោះវាគឺជាអាំរូហ្ពិនអាប់ឌូវ៉ាត់ឌិនអាលីបាននិយាយទាំងភាពសច្ចះដោយការជួយរបស់អល់ឡោះនិងភាពក្លាហានរបស់លោកថា: ខ្ញុំអាចសំលាប់វាបានអ៊ីនសើអល់ឡោះ (បើអល់ឡោះបើកអោយខ្ញុំ) ។ពេលនោះ”រ៉ស៊ូលុលឡោះបានអនុញ្ញាតអោយអាលីប្រយុទ្ធជាមួយអាំរូហ្ពិនអាប់ឌូវ៉ាត់ឌិន ។ពេលអាំរូហ្ពិនអាប់ឌូវ៉ាត់ឌិនឃើញអាលីមើលងាយថាតូចណាស់ រួចនិយាយមកកាន់អាលីថា: ខ្ញុំមិនចង់សំលាប់ឯងទេ អាលីឆ្លើយថា:តែខ្ញុំចង់សំលាប់អ្នកឯង! អ្នកទាំងពីរចាប់ផ្តើមប្រយុទ្ធគ្នា ។អាលីបានកាប់អាំរូហ្ពិនអាប់ឌូវ៉ាត់ឌិន រហូតណាហ្ពីបានលឺសំណួរកាប់របស់អាលីទៅសត្រូវហើយអ្នកមូស្លីមទាំងអស់បានសូត្រធមិតឹកហ្បៀរ (ពាក្យថា:អល់ឡោះហ៊ូអឹកហ្ពារ) ។

## លោកអាលីនិងការរំដោះខៃហ្ពើរ

**មូសតាហ្វា :** ខ្ញុំនឹងអធិប្បាយអំពីព្រឹត្តិការណ៍នៅខៃហ្ពើរ ។

**ហ្វាទីម៉ះ :** ខៃហ្ពើរ ?(ជាឈ្មោះភូមិ)

**មូសតហ្វា :**មែនហើយ ។ អាល់ខៃហ្ពើរមានការការពារយ៉ាងរឹងមាំរហូតកងពលតូចមួយដែលដឹកនាំដោយអាហ្ពូហ្ពាកើរ និងមានកងពលមួយផ្សេង

ទៀត ដែលដឹកនាំដោយអ៊ូម៉ើរ ដែលកងពលទាំងពីរនេះមិនអាចវាយចូលតំបន់ខៃហ្ពើរបាន។ ចុងក្រោយកងទ័ពទាំងអស់វិលវិញដោយមិនអាចរំដោះតំបន់ខៃហ្ពើរបានឡើយ។ ណាហ្គីមានប្រសាសន៍ថា: (ខ្ញុំនឹងប្រគល់ទង់ជ័យអោយទៅបុរសម្នាក់នៅថ្ងៃស្អែក ដែលបុរសរូបនេះស្រលាញ់អល់ឡោះ និងស្រលាញ់រ៉ស៊ូលរបស់ទ្រង់ផងដែរ )។

**ស៊ីម៉ាហ៏ :** នៅព្រឹកថ្ងៃបន្ទាប់រ៉ស៊ូលុលឡោះបានហៅអាលី អាលីមកជួបរ៉ស៊ូលុលឡោះក្នុងសភាពភ្នែករបស់គាត់ឡើងក្រហម( ឈឺភ្នែក)។ ពេលណាហ្គីឃើញដូចនេះ លោកក៏ផ្ញើមចុងម្រាមដៃរបស់លោក រួចស្ទាបទៅភ្នែកអាលីស្រាប់តែភ្នែកនោះជាធម្មតាវិញភ្លាម។ ក្រោយមករ៉ស៊ូលុលឡោះបានកាន់ទង់ជ័យរួចលើកឡើងលើហើយប្រគល់អោយអាលីព្រមទាំងមានប្រសាសន៍ថា:"ចូរអ្នកយកទង់នេះរួចធ្វើដំណើរចុះ រហូតអល់ឡោះផ្តល់ភាពជោគជ័យដល់ពួកអ្នក "។

**ម៉ាស់ម៉ូដ :** អាលីបានកាន់ទង់ជ័យ ហើយបានទៅឈរនៅច្រកកំផែងខៃហ្ពើររួចនិយាយថា : "ខ្ញុំគឺអាលីកូនអាហ្ពូតលិប"។

**ណាដា :** ប៉ុន្តែអាលីជួបនូវការប្រយុទ្ធយ៉ាងខ្លាំង រហូតប៉ើង ខែលរបស់គាត់ចេញពីដៃ ពេលនោះអាលីស្រែកខ្លាំងៗថា:"ខ្ញុំសូមស្បថចំពោះម្ចាស់ដែលរូបខ្ញុំក្នុងកណ្តាប់ដៃរបស់ទ្រង់ថា ខ្ញុំនឹងភ្លក្សរសជាតិដូចអ្វីដែលលោកហាំហ្ស៊ះធ្លាប់បានភ្លក្ស( ស្លាប់) បើមិនដូចនេះទេអល់ឡោះច្បាស់ជាជួយខ្ញុំអោយមានជ័យជំនះអាចរំដោះតំបន់ខៃហ្ពើរបានពុំខាន"។ អាលីក៏រុលបុកចូលទៅមុខ



មនុស្សម្នាទាំងអស់គ្នាបានឃើញច្រកទ្វារកំផែងស្ថិតក្នុងដៃរបស់អាលីមិនយូរប៉ុន្មានស្រាប់តែអាលីបានស្រែកជ័យជំនះថា:"អល់ឡោះមហាធំធេង"។

**កូន១ :** ស្រែកបន្ទរឡើងថា: "អល់ឡោះមហាធំធេង" ។

## រំលឹកពីការរំដោះក្រុងម៉ាក្កះ

**ហ្វាទីម៉ះ :** ក្នុងការរំដោះទីក្រុងម៉ាក្កះ មេដឹកនាំរបស់ក្រុមអាន់សរ័គឺលោកសាអាត់កូនអ៊ូហ្ពើឌះ គឺជាអ្នកកាន់ទង់ជ័យដឹកនាំទ័ពមូស្លីមីនបានស្រែកខ្លាំងឡើងថា :"ថ្ងៃនេះគឺជាថ្ងៃបង្ហូរឈាម"។

**ហ្វារ៉ហ៏ :** សូមរំលឹកថា: ពេលនោះអូម៉ើរកូនខត្តបបានរត់យ៉ាងលឿនទៅផ្តល់ដំណឹងដល់រ៉ស៊ូលុលឡោះចំពោះសំដីរបស់សាអាត់កូនអ៊ុហ្ពើឌះ។ ពេលនោះរ៉ស៊ូលុលឡោះបានហៅអាលីរួចបញ្ជាទៅអាលីថា:"ចូរប្រញាប់ទៅអោយទាន់សាអាត់រួចយកទង់ជ័យពីគាត់ហើយឯងជាអ្នកកាន់ទង់ជ័យវាយលុកចូល "។

## ការសច្ចាប្រណិធានទទួលអាលីជាមេដឹកនាំ

**ឪពុក :** បន្ទាប់ពីឧស្មានត្រូវបានគេសំលាប់ អាលីបានបដិសេធក្នុងការធ្វើជាមេដឹកនាំតាំងពីការចាប់ផ្តើមមកម្លេះ ដោយសារការឈ្នានីសមកលើថ្នាក់ដឹកនាំរបស់អ្នកកាន់សាសនាអ៊ីស្លាម។ ទោះជាយ៉ាងនេះក៏ពួកអ្នកបំលាស់ទីនិងអ្នកស្រុកម៉ាឌីណះនៅតែធ្វើសច្ចាប្រណិធានយកអាលីធ្វើជាមេដឹកនាំរបស់ពួកគេដែរ។

## ឃ្លាំងទ្រព្យសម្បត្តិរួមរបស់មូស្លីមីន

**ម៉ាស់មូដ :** គោលនយោបាយរបស់អាហ្ពូហ្ពាកើរ គឺការផ្គត់ផ្គង់ស្មើគ្នារវាង

អ្នកចូលអ៊ីស្លាមជាយូរមកហើយ និងអ្នកដែលទើបបានចូលអ៊ីស្លាមថ្មីថ្មោង ។

**អ៊ីស្លាម :** ដោយឡែកអាលីយល់ឃើញថាៈ ការផ្គត់ផ្គង់ពីឃ្លាំងសំភារៈគឺចាំបាច់ផ្ដល់អោយបរិស័ទរបស់ខ្លួន ដើម្បីអោយពួកគេបានរស់នៅសមរម្យគឺមិនត្រូវមើលទៅលើពេលវេលានៃការចូលកាន់សាសនាអ៊ីស្លាមមុន ឬក្រោយឬដោយការតស៊ូក្នុងមាគ៌ារបស់អល់ឡោះនោះទេ ។ តាមពិតការងារមុនឬក្រោយវាជាឋានៈ តួនាទី និងផលបុណ្យ គឺជាប្រការដែលអល់ឡោះម្ចាស់តែមួយគត់ដែលដឹង ។

**អាប់ឌុររ៉ស់ម៉ានៈ** ខ្ញុំចង់សួរនិងពិភាក្សាៈ តើអ្នកយល់យ៉ាងណាដែរ ចំពោះទស្សនៈរបស់អាលីដែលយល់ឃើញថាៈ បើការផ្គត់ផ្គង់ទៅតាមឋានន្តរសក្តិវាជាមូលហេតុនាំដល់ភាពចលាចលមិនខាន ។ ខ្ញុំចង់និយាយថានឹងអាចកើតមានបញ្ហាជាច្រើននៅក្នុងសាសនា និងនាំមកនូវវិនាសអន្តរាយចំពោះការងារលោកីយ៏ផងដែរ ។

**អ៊ីស្លាមៈ** តើអ្នកចង់ដឹងពីបញ្ហាទ្រព្យសម្បត្តិរួមរបស់អ៊ីស្លាមមែនទេ? នៅអាល់គូហ្វះ( ប្រទេសអ៊ីរ៉ាក់) អាលីបានចាប់ផ្ដើមរៀបចំអោយមានឃ្លាំងសំភារៈរបស់អ៊ីស្លាម ។រាល់បុគ្គលដែលជ្រកក្រោមការចាត់ចែងរបស់ឃ្លាំងនេះត្រូវតែផ្ដល់ចំណែកដល់ឃ្លាំងរួមនេះ ហើយគេយកសំភារៈទាំងនោះទៅផ្ដល់ជូនអ្នកដែលមានសិទ្ធិទទួល ។

**សើម៉ាហ៊ៈ** ខ្ញុំបានអានឯកសារមួយបញ្ជាក់ថាៈមិត្តភក្តិរបស់អាលីមួយចំនួនបានជូនយោបល់លោកថាៈអោយរក្សាប្រាក់ទុកមួយចំនួនសំរាប់លើកទឹកចិត្ត



មេៗកុលសម្ព័ន្ធ តែអាលីបានបដិសេធ ។

**អ៊ីស្លាម :** វាជាហេតុផលល្អណាស់! នៅពេលដែលឃ្លាំងសំភារៈរួមទំនេរអាលីបានដើរស្រោចដីនិងលាងសំអាតវា បន្ទាប់មកលោកបានសឡាហ៏នៅលើដីនោះចំនួនពីររ៉ក្អាត់ ដើម្បីអល់ឡោះជាម្ចាស់ ។

## ការលះបង់និងភាពទន់ភ្លន់របស់អាលី

**អ៊ីស្លាម :** លោកអាលីពិតជាបុរសម្នាក់ដែលមានលក្ខណៈទន់ភ្លន់និងលះបង់ខ្ពស់ ។ គ្មានអ្វីដែលថាមិនអាចនោះទេ ព្រោះលោកជាជីដូនមួយជាមួយណាហ្ពី និងត្រូវជាកូនប្រសាររបស់ណាហ្ពីទៀតផង ។

**ហ្វាទីម៉ះ :** អាលីមិនចង់ប្រកាន់ខ្លួនក្នុងនាមជាមេដឹកនាំទេ!

**ណាដា :** ប្រសើរអ្វីម្លេះទេ( មិនប្រកាន់វណ្ណៈ) ! គឺនៅថ្ងៃមួយលោកបានដើរនៅក្នុងទីផ្សារ លោកបានជួយយកអាសារចាស់ជរាម្នាក់ ។ ខណៈនោះគូរកនរបស់លោកបានខិតជិតលោកដោយម្នាក់ក្នុងចំណោមពួកគេ បាននិយាយមកកាន់អាលីថាៈ"សូមលោកទុកអោយខ្ញុំជួយគាត់វិញបានទេ" ។ ពេលនោះអាលីបានឆ្លើយតបវិញដោយសូត្រនូវបន្ទូលរបស់អល់ឡោះត្រង់ជំពូកអាល់គីសសោះវាក្យខ័ណ្ឌ៨៣មានន័យថាៈ ថ្ងៃបរលោកនោះ យើងបានបង្កើតវាសំរាប់អ្នកណាដែលមិនចង់ខ្ពង់ខ្ពស់ ( មហិច្ឆតា) និងអ្នកដែលមិនបង្កមហន្តរាយនៅលើផែនដីនេះ ផលបុណ្យនោះគឺសំរាប់ជនទាំងឡាយណាដែលគោរពកោតខ្លាចអល់ឡោះ" ។ ថ្ងៃមួយអាលីបានទៅទិញរបស់របរមួយចំនួន

ដែលជាតំរូវការក្រុមគ្រួសាររបស់លោក ។លោកបានមានប្រសាសន៏ថាៈ " មេគ្រួសារត្រូវតែទទួលខុសត្រូវរែកពន់របស់ទាំងនេះ" ។ លោកក៏បានជិះលើខ្នងសត្វលាមួយក្បាលប្រៀបដូចជាជនក្រីក្រមកពីទីជនបទម្នាក់ ។

**អ៊ីណាសៈ** អាលីជាមេដឹកនាំមិនរើសអើងខ្លួនលោកពាក់អាវដែលតំលៃត្រឹមតែបីដារ៉ហាំ( ឈ្មោះលុយអារ៉ាប់) ប៉ុណ្ណោះ ។

**ហ្វារ៉ស** ៖ លោកអ៊ូម៉ើរ កូន អាប់ឌុលអាហ្ស៊ីសបាននិយាយថាៈ"មនុស្សដែលលះបង់បំផុតនៅលោកីយ៏នេះគឺអាលីកូនអាហ្គូតលិប " ។

## ភក្តីមេត្តារបស់លោកអាលី

**អ៊ីស្លាម** ៖ ភាពទន់ភ្លន់ សុភាពរាបសារនិងការលះបង់ខ្ពស់ នាំមកនូវកុសលផលបុណ្យ ។ យើងទាំងអស់គ្នាបានឃើញយ៉ាងច្បាស់ហើយពីសណ្ដានចិត្តសណ្ដោសប្រណីរបស់អាលីដែលជាមេដឹកនាំរបស់អ្នកមានជំនឿ សូម្បីតែជាមួយអ្នកដែលមិនមែនជាមូស្លីមីនក៏ដោយចុះ ។

**អៃម៉ាន់** ៖ ពាក្យថាអាល់អ៊ីមុាំ គឺជាបុគ្គលដែលត្រូវបានគេអនុវត្តតាមចំណែកវ៉ស៊ូលុលឡោះគឺជាអ្នកដឹកនាំរបស់អ្នកគោរពកោតខ្លាចអល់ឡោះ ។ យ៉ាងណាមិញដូចជាអាហ្គូហ្គាកើរ អ៊ូម៉ើរ ឧស្មាន គឺជាអ៊ីមុាំ ។

**ហ៊ូសាមៈ** អល់ឡោះជាម្ចាស់របស់ពួកយើងបានប្រទានឋានៈជាមេដឹកនាំជូនណាហ្គីអ៊ីប្រហ៊ីម ។ ទ្រង់បានមានបន្ទូលក្នុងគម្ពីរអាល់គួរអានជំពូកអាល់ហ្គាការ៉ោះវាក្យខ័ណ្ឌ១២៥មានន័យថាៈយើងសូមចាត់តាំងឯង ( អ៊ីប្រហ៊ីម)



អោយធ្វើជាមេដឹកនាំរបស់មនុស្សលោក" ។ អ៊ីប្រហ៊ីមបានសំណូមពរអល់ឡោះថាៈ "សូមទ្រង់ចាត់តាំងពូជពង្សរបស់ខ្ញុំផង?"អល់ឡោះបានតបថាៈ "ពាក្យសន្យា របស់ខ្ញុំមិនមានការពាក់ព័ន្ធជាមួយពពួកធ្វើបំពានគេឡើយ" ។

**ហ្ស៊ីយ៉ាដ** ៖ ពាក្យថាអ៊ីមុាំក៏សំដៅទៅលើអ្នកដែលឈរនៅខាងមុខគេក្នុងពេលសឡាហ៏ផងដែរ ។ជាបន្តទៅទៀតនេះយើងនៅមានការសន្ទនាជាច្រើនទៀតរបស់បណ្ដាអ្នកដែលត្រូវបានអល់ឡោះសន្យាដល់ពួកគេអោយចូលឋានសួគ៌ ។

**អាប់ឌុរ៉ស់ម៉ានៈ** ថ្ងៃមួយលោកអាលីបានឃើញអាវក្រោះ របស់លោកនៅជាមួយបុរសយ៉ាហ៊ូឌីម្នាក់ ។ អាលីបាននាំបុរសនោះទៅកាន់អ្នកកាត់ក្ដីឈ្មោះសូរៃហ៏ ។ អាលីបាននិយាយទៅកាន់សូរៃហ៏ថាៈវាជាអាវក្រោះបស់ខ្ញុំ ខ្ញុំមិនបានលក់វា ឬក៏អោយទៅអ្នកណាដែរ ប៉ុន្តែបុរសយ៉ាហ៊ូឌីនេះបានអះអាងថាវាជាកម្មសិទ្ធរបស់គាត់ ។ ខណៈនោះលោកសូរៃហ៏ ដែលជាអ្នកកាត់ក្ដីបាននិយាយទៅកាន់អាលីថាៈ ឱ លោកមេដឹកនាំ! តើលោកមានភស្តុតាងអ្វីមកបញ្ជាក់សំរាប់ពាក្យសំដីរបស់លោកដែរឬទេ?" ។ ពេលនោះលោកអាលីបានញញឹម រួចនិយាយថាៈ"សំរាប់ខ្ញុំមិនមានអ្វីមកបញ្ជាក់ទេ!" ។ ពេលនោះលោកសូរៃហ៏ជាអ្នកកាត់ក្ដីផ្ដល់អាវក្រោះអោយទៅបុរសយ៉ាហ៊ូឌីនោះ ។ បុរសយ៉ាហ៊ូឌីនោះបានយកអាវក្រោះ រួចចេញដំណើរទៅ ។បន្តិចក្រោយមកបុរសយ៉ាហ៊ូឌីនោះក៏វិលមកវិញហើយនិយាយថាៈខ្ញុំសូមធ្វើសាក្សីថានេះពិតជាច្បាប់របស់បណ្ដាណាហ្គីមែន ហើយសំដីរបស់លោកអាលី គឺជាការពិត

ព្រោះអាវក្រោះនេះពិតជាកម្មសិទ្ធិរបស់មេដឹកនាំមែន(របស់អាលី) ។ ខ្ញុំសូមធ្វើការប្តេជ្ញា និងធ្វើសាក្សីថាៈ គ្មានទេម្ចាស់ដែលត្រូវគេគោរពដ៏ពិតប្រាដកមានតែអល់ឡោះហើយណាហ្គីមូហាំម៉ាត់ជារ៉ស៊ូលរបស់អល់ឡោះ ។នៅពេលដែលបុរសយ៉ាហូឌីបានទទួលស្គាល់និងពោលពាក្យសច្ចាទាំងពីររួចលោកអាលីក៏ប្រគល់អាវក្រោះទៅអោយបុរសនោះវិញ ក្រោយមកអ៊ីស្លាមរបស់គាត់កាន់តែប្រសើរឡើងៗ ។

## លក្ខណៈពិសេសរបស់លោកអាលី

**ឪពុកៈ** លោកអាលី គឺជាមេដឹកនាំម្នាក់ត្រូវបានគេកោតសរសើរថា គាត់ជាបុរសរស់នៅប្រកបដោយសុជីវធម៌ វោហារស័ព្ទ ឆ្លាតវៀងវៃ និងពូកែផ្នែកច្បាប់មិនតែប៉ុណ្ណោះ លោកជាតុលាការឆ្នើមនាសម័យនោះ លោកជាអ្នកចេះផ្នែកច្បាប់ អនុវត្តជាងគេនិងជាអ្នកដកស្រង់ក្រិត្យច្បាប់ចេញពីអាល់ គួរអាននិងហាហ្ទីសរបស់ណាហ្គី ។ ភាពជាមេដឹកនាំនិងជំនាញផ្នែកភាសាអារ៉ាប់ ។

**អ៊ីស្លាម ៈ** ឪពុកជាទីស្រលាញ់! ខ្ញុំបានអានឯកសារមួយបង្ហាញថាៈ លោកអាលីមានការចងចាំច្បាស់លាល់ណាស់ផ្នែកភាសាអារ៉ាប់ ក៏ប៉ុន្តែ ខ្ញុំនៅមិនទាន់យល់ពីរឿងនេះនៅឡើយទេ ។

**ឪពុកៈ**មិនស្អីទេ! ចំពោះលោកអាលី មានការចងចាំខ្ពស់ផ្នែកភាសាអារ៉ាប់ លោកមិនខ្ជីខ្ជារចំពោះវាឡើយ ។ លោកបានរៀបចំយ៉ាងល្អនូវរូបមន្តភាសា លោកបានអញ្ជើញអាហ្គូអែសវ៉ាត់អាត់ដាវលី ហើយស្នើលោកអោយកត់ត្រា



វាទុកជាឯកសារដើម្បីកុំអោយអាននិងសរសេរខុសអក្ខរាវិរុទ្ធរបស់វា ។លោកអាលីបាននិយាយទៅកាន់អាហ្គូអែសវ៉ាត់អាត់ដាវលីថាៈ ” សូមអ្នកកត់ត្រាទុកនូវអ្វីដែលខ្ញុំអាន ” ។ អាលី បានអានរូបមន្តគ្រឹះរបស់ភាសាអារ៉ាប់ ថាៈ សំដីនៅក្នុងភាសាអារ៉ាប់ គឺផ្សំឡើងដោយនាម កិរិយាសព្ទ័ និងបរិវាស័ព្ទ ។ នាមគឺអ្វីដែលគេចង់បង្ហាញពីអត្ថន័យរបស់ឈ្មោះអ្វីម្យ៉ាង ចំណែកកិរិយាសព្ទគឺអ្វីដែលគេចង់បង្ហាញពីចលនាអំពើរបស់នាមដោយឡែកបរិវារសព្ទគឺអ្វីដែលបង្ហាញពីអត្ថន័យដែលវាពុំមែនជានាមឬកិរិយាសព្ទ័នោះឡើយ ។ លោកអាលីបាននិយាយទៅកាន់អាហ្គូអែសវ៉ាត់អាត់ដាវលីថាៈ ”ឱអាហ្គូអែសវ៉ាត់! ចូរចងក្រងវេយ្យាករណ៏ភ្លាម ។ ចាប់ពីពេលនោះមកគេស្គាល់ចំណេះដឹងនេះថាជាវេយ្យាករណ៏ ។

## ឧត្តមភាពរបស់អាលី

**អ៊ីស្លាម ៈ**ឱបងប្អូនទាំងអស់ ! សូមស្តាប់ខ្ញុំនឹងបង្ហាញដល់ពួកអ្នកខ្លះៗពីឧត្តមភាពរបស់អាលី ។ លោកមូហាំម៉ាត់កូនកាអាប់អាល់គូរ៉ហ្ស៊ីបាននិយាយថាៈ លោកតល់ហះ កូនស្នៃហ្គះកូនអាប់ឌុតដារី លោកអាប់ហ្គាសកូន អាប់ឌុលមូតល់លិបនិងលោកអាលីដែលពួកគេបានបង្ហាញពីលក្ខណៈពិសេសរបស់ពួកគេរៀងៗខ្លួន ។ ពេលនោះតល់ហះនិយាយថាៈ ខ្ញុំជាម្ចាស់ផ្ទះនេះហើយខ្ញុំមានកូនសោនៅនឹងដៃបើខ្ញុំចង់ ខ្ញុំសំរាកនៅក្នុងផ្ទះនោះមិនខាន” ។ លោកអាប់ហ្គាសនិយាយថាៈ”ខ្ញុំជាអ្នកផ្គត់ផ្គង់ទឹកបើខ្ញុំចង់ខ្ញុំនឹងដេកក្នុងម៉ាស្ជិត” ។ លោកអាលី

និយាយថា: ខ្ញុំមិនយល់ពីអ្វីដែលអ្នកទាំងពីរកំពុងនិយាយនោះទេ តែខ្ញុំបានសឡាហ៏តំរង់ទៅរកកាក់ហ្ពះមុនអ្នកទាំងពីររយះពេល៦ខែ ហើយរូបខ្ញុំក៏ជាអ្នកប្រយុទ្ធផងដែរ"។ ខណះនោះអល់ឡោះបានបញ្ចុះវាក្យខ័ណ្ឌទី៩ក្នុងជំពូកតាវប៉្ហតដែលមានន័យថា:"តើពួកអ្នកគិតថា:អ្នកផ្តល់ទឹកអោយអ្នកធ្វើបុណ្យហាជ្ជី និងអ្នកសាងសង់ម៉ាស្ជិតហារ៉ម ប្រៀបដូចជាអ្នកមានជំនឿចំពោះអល់ឡោះ និងថ្ងៃបរលោកនិងតស៊ូបុព្វហេតុមាគ៌អល់ឡោះឬ? សំរាប់ទ្រង់ពួកគេទាំងអស់មិនមានឋានះស្មើគ្នានោះទេ។

**ហ្វាទីម៉ះ:** លោកអាលី គឺជាអ្នកពូកែជំនាញថ្លែងសន្ទរកថា និងមានវិជ្ជាជ្រៅជ្រះ ដែលជះពន្លឺរស្មីដល់ចិត្តគំនិត ខ្លួនប្រាណ វិចារណញ្ញាណនិងពាក្យសំដី។

**មូហាំម៉ាត់ :** អាលីកូនអាហ្ពូតលិបជាសាសនិកម្នាក់នៅវ័យក្មេង តែនៅក្នុងសមរភូមិគឺជាអ្នកជំនាញខាងជិះសេះប្រយុទ្ធទៀតផង។

## ការព្យាយាមបួងសួង និងគ្រួសារស៊ូលុលឡោះ

**អះម៉ាត់ :** នៅក្នុងរឿងនេះអាយ៉ាត់បានបញ្ចុះគឺពាក់ពន្ធ័នៅក្នុងក្រុមគ្រួសាររបស់រ៉ស៊ូលុលឡោះ។

**ណាដា:** បានន័យថា វាមិនត្រូវសង្ស័យចំពោះវាក្យខណ្ឌនោះឡើយ ។

**ហ្វារ៉ហ៏:** ការបួងសួងដាក់បណ្តាសារ ! តើវាសំដៅលើអ្វីទៅ?

**ឪពុក:** វាគឺជាការបួងសួងសុំអោយដាក់បណ្តាសារព្រោះថាពាក្យនេះន័យរបស់វាគឺបណ្តាសារ។ ប្រវត្តិដំណើររឿងនេះមានដូចតទៅ: មានប្រតិភូមួយក្រុម



មកពីតំបន់ណាច់រ៉ានមកជួបណាហ្ពី តែពួកគេបានបដិសេធចំពោះពាក្យសំដីរបស់ណាហ្ពីដែលថា:"អ៊ីសាគឺជាខ្ញុំរបស់អល់ឡោះ ហើយបន្ទូលរបស់ទ្រង់ (ពាក្យបញ្ជារបស់អល់ឡោះ ដែលថា: ចូរកើតភ្លាម ) ទៅកាន់ស្រីម៉ារីយ៉ុំដែលជាចៅហ្វាយនៃស្ត្រីទូទាំងពិភពលោក)"។ ក្រោយមកណាហ្ពីបានអំពាវនាវពួកគេអោយទទួលយកសាសនាអ៊ីស្លាមប៉ុន្តែពួកគេទាំងនោះបានបដិសេធ និងប្រឆាំងជំទាស់នឹងភាពជារ៉ស៊ូលរបស់មូហាំម៉ាត់ទៀតផង។ពួកគេបានសួរណាហ្ពីថា: ចូរអ្នកបង្ហាញពួកយើងមើល តើនរណាមួយកើតមកគ្មានឪពុកនោះ? ណាហ្ពីបានប្រាប់ពួកគេថា: គឺណាហ្ពីអាដាម តើនរណាជាឪពុករបស់មនុស្សលោក?។ ពេលនោះអល់ឡោះក៏បានបញ្ចុះវាក្យខ័ណ្ឌ៦១នៅក្នុងជំពូកអាល់អ៊ីមរ៉ាន ដែលមានន័យថា:"ចំពោះអ្នកដែលមកឈ្លោះ ជជែកជាមួយអ្នក( មូហាំម៉ាត់) ក្នុងរឿងអ៊ីសាកូនម៉ារីយ៉ុំ បន្ទាប់ពីអ្នកបានដឹងការពិតច្បាស់លាស់ហើយនោះចូរអ្នកនិយាយទៅកាន់ពួកនោះថា: ចូរពួកអ្នកមកចុះហើយយើងនឹងកែនកូនចៅរបស់ពួកយើង និងកូនចៅរបស់ពួកអ្នកប្រពន្ធរបស់ពួកយើងនិងប្រពន្ធរបស់ពួកអ្នក និងរូបពួកយើងផ្ទាល់ និងពួកអ្នកផងដែរបន្ទាប់មកយើងនឹងសូត្របន់ស្រន់សុំពីអល់ឡោះបញ្ចុះទណ្ឌកម្ម និងដាក់បណ្តាសារដល់អ្នកដែលនិយាយកុហក"។ពេលនោះណាហ្ពីបានបួងសួងពីអល់ឡោះអោយដាក់បណ្តាសារចំពោះពួកនោះហើយណាហ្ពីហៅអាលីហ្វាទីម៉ះ ហាសាន់ និងហ៊ូសេន រួចលោកនិយាយ "អល់ឡោះជាម្ចាស់ពួកគេទាំងអស់នេះជាក្រុមគ្រួសាររបស់ខ្ញុំ "។

**ហ៊ូសាម**ៈរឿងរ៉ាវនេះខ្ញុំទើបតែបានលឺជាលើកដំបូងប៉ុណ្ណោះចុះវាបានបញ្ចប់នៅត្រឹមណា ?

**ហ្វាទីម៉ះ :** រឿងនេះចប់ត្រឹមថា ពួកនោះកោតខ្លាចណាហ្វីជាខ្លាំង ព្រោះណាហ្វីស្នើសុំពួកនោះ អោយធ្វើការបួងសួងសុំពីអល់ឡោះអោយដាក់បណ្តាសារ តែពួកគេបានប្រកែកមិនហ៊ានហើយបែរមកយល់ព្រមបង់ពន្ធលើខ្លួន ។ដោយមូលហេតុមេកន្រ្ទាញពួកគេឈ្មោះអាគីបបាននិយាយប្រាប់កូនចៅរបស់ខ្លួនថា "ពួកអ្នកកុំនិយាយបួងសួងសុំការដាក់បណ្តាសារលើមូហាំម៉ាត់អោយសោះបើពុំនោះទេ ពួកឯងទទួលរងនូវក្តីវិនាសពុំខាន បើពួកអ្នកនៅតែចចេសបួងសួងសុំការដាក់បណ្តាសារមកលើណាហ្វីទៀត ភ្លើងនឹងឆេះពួកអ្នកមិនខាន ព្រោះមូហាំម៉ាត់ជាណាហ្វីដែលអល់ឡោះតែងតាំងពិតប្រាកដមែន ។

## អាលីនិងចំណេះវិជ្ជា

**ហ៊ូសាម :** ក្នុងទ្រឹស្តីរបស់អាលីមួយបានលើកឡើងថាៈ ( វិជ្ជាប្រសើរជាងទ្រព្យសម្បត្តិ វិជ្ជាការពាររូបអ្នក តែរូបអ្នកការពារទ្រព្យសម្បត្តិ វិជ្ជាកើនឡើងដោយការចំនាយ ទ្រព្យសម្បត្តិថយចុះដោយការចំណាយ វិជ្ជាហុចផលដល់ម្ចាស់នូវការគោរពប្រតិបត្តិ ទ្រព្យសម្បត្តិត្រូវចប់ដោយសង្ខាម្ចាស់លើកលែងតែម្ចាស់បានចំនាយក្នុងផ្លូវល្អប៉ុណ្ណោះ) ។

## មរណៈភាពរបស់អាលីជាមហាវីរៈបុរសអ៊ីស្លាម

**ឪពុក** :មរណៈភាពរបស់វីរៈបុរសដែលមានឋានៈជាខលីហ្វះនិងជាមេដឹកនាំ



ដ៏ឆ្នើម ។នៅពេលដែលលោកដើរហៅមនុស្សអោយក្រោកមកសឡាហ៍ស៊ូហ្ពហ ខណៈនោះអាប់ឌុររ៉ស់ម៉ានកូនមុលយាំ ពីពួកខវ៉ារិច ដែលគេបានរៀបគំរោងជាមួយនឹងបក្ខពួករបស់គេពីរនាក់ផ្សេងទៀត ក្នុងការសំលាប់ អាលី និងមូអាវីយ៉ាស់នៅប្រទេសស្ហាមនិងសំលាប់អាំរូ ហ្ពិនអាស នៅប្រទេសអេហ្ស៊ីប កាលនោះអាប់ឌុររ៉ស់ម៉ានកូនមុលយាំ បានប្រើដាវដាក់ជាតិពុលកាប់ទៅលើអាលី ។ គេបានសែងលោកអាលីទៅកាន់គេហដ្ឋានរបស់លោក ។ ខណៈនោះអាលីបានសំណូមពរអោយអ្នកសែងគាត់យកគាត់ត្រលប់ទៅម៉ាស្ជិតវិញ ដើម្បីអោយពួកគេបំពេញសឡាហ៍ស៊ូហ្ពហសិន បន្ទាប់មកចាំយកខ្ញុំវិលមកគេហដ្ឋានវិញ ។នៅពេលលោកបានឃើញឃាតករ សំលាប់រូបលោកខណៈ ដែលមនុស្សម្នាក់កំពុងចាប់ជននោះ ។លោកអាលី បានសំណូមពរពួកគេថាៈ "សូមពួកអ្នកកុំសំលាប់គាត់ដោយសាររូបខ្ញុំអោយសោះព្រោះអល់ឡោះទ្រង់មិនស្រលាញ់ទេចំពោះជនបំពានគេឡើយ ផ្ទុយទៅវិញសូមពួកអ្នកមើលថែរក្សាគាត់ឱ្យបានល្អប្រសើរផងបើជីវិតខ្ញុំនៅមានគឺខ្ញុំអាចអភ័យទោសអោយគាត់ ឬខ្ញុំនឹងកាត់ក្តីគាត់តែបើជីវិតខ្ញុំត្រូវអស់ចូរពួកអ្នកសំលាប់គេទៅហើយ ខ្ញុំនឹងវ៉ៃពៀកជាមួយគាត់នៅចំពោះមុខអល់ឡោះជាម្ចាស់នៃពិភពទាំងឡាយ ។ពេលនោះមនុស្សម្នាបានលើកសំណូមពរអោយលោកអាលី តែងតាំងកូនប្រុសរបស់លោកគឺហាសាន់ស្នងតំណែងជំនួសលោក តែអាលីបាននិយាយថាៈខ្ញុំសូមទុកភារកិច្ចនេះអោយពួកអ្នកទាំងអស់គ្នាដូចដែលរ៉ស៊ូលុលឡោះទុកភារកិច្ចនេះដល់មូស្លីមទាំងអស់ដោយណាហ្វីមិនបានតែងតាំងនរណាម្នាក់ អោយស្នងបន្តក្រោយពី

លោកឡើយ ។

## ចំណេះដឹងមហាសាលរបស់អាលីពីច្បាប់អ៊ីស្លាម

**អ៊ីស្លាម ៖** បងប្អូនជាទីស្រលាញ់! មុនពេលពួកយើងបញ្ចប់ការនិទានពីប្រវត្តិរបស់ថ្នាក់ដឹកនាំកំពូល គឺលោកអាលីនោះ ខ្ញុំសូមអានអោយពួកអ្នកបានស្តាប់ពីអត្ថបទមួយដែលលោកម៉ះមូដអាប់ហ្គាសអាល់អាកតបានសរសេរកំណត់ត្រាពីទេពកោសល្យរបស់លោកអាលីដោយលោកបញ្ជាក់ថា៖ លោកអាលីគឺជាមនុស្សម្នាក់ក្នុងចំណោមកូនចៅរបស់អាដាម( ឪពុកមនុស្សលោក) ដែលមានចំណេះដឹងពីបណ្តានាមផ្សេងៗ ដែលបានទទួលនូវការឆ្លាតវៃ និងចេះបែងចែកខុសនិងត្រូវបានល្អបំផុត ។លោកអាលីបានបន្សល់ទុកស្នាដៃឆ្នើមគឺការធ្វើអោយអ៊ីស្លាមចេះរួបរួមគ្នា ការកាត់ក្តីតាមច្បាប់អ៊ីស្លាមមានចំណេះដឹងផ្នែកច្បាប់អ៊ីស្លាមមានចំណេះដឹងពីក្បួនច្បាប់វេយ្យាករណ៍ អារ៉ាប់និងមានចំណេះដឹងផ្នែកការសរសេរអក្សរអារ៉ាប់ ដែលស្នាដៃទាំងនេះ អាចអនុញ្ញាតអោយពួកយើងចាត់ទុកលោកជាថ្នាក់ដឹកនាំ បង្គោលម្នាក់ដែលត្រឹមត្រូវសំរាប់ចំណេះដឹងដ៏មហាសាលនៃច្បាប់សាសនាអ៊ីស្លាម ដែលចំនុចទាំងនេះវាមានតាំងពីដើមមកម្លេះជាមួយនឹងការឆ្លាតវៃ តែមួយដែលគេកត់ត្រាទុកនៅក្នុងឯកសារអ៊ីស្លាមសំរាប់គ្រប់ជំនាន់ ។

**អ៊ីណាស ៖** ប៉ុន្តែមុននឹងពួកយើងឈានដល់ការរំលឹកពីជីវប្រវត្តិរបស់មេដឹកនាំទី៥នោះខ្ញុំមានបំណងចង់លើកយកពាក្យពេចន៏ ដែលមានតំលៃបំផុតរបស់



លោកអាលីមកបញ្ជាក់ប្រាប់ ។ លោកអាលីបាននិយាយថា៖(វិជ្ជាប្រសើរជាងទ្រព្យសម្បត្តិ វិជ្ជាការពាររូបអ្នក តែរូបអ្នកការពារទ្រព្យសម្បត្តិ វិជ្ជារីកចំរើនដោយការអនុវត្ត ទ្រព្យសម្បត្តិថយចុះដោយការចំណាយ វិជ្ជាជាអ្នកកាត់ក្តីតែលុយកាក់ជារបស់ដែលត្រូវគេកាត់ក្តី អ្នករកលុយកាក់ត្រូវថយអំណាចនៅពេលអស់លុយ អ្នកស្រលាញ់អ្នកចេះដឹង គេនឹងស្រលាញ់រូបគាត់វិញទ្រព្យសម្បត្តិបាត់បង់ តែអ្នកមានចំណេះដឹងមិនបាត់បង់ឡើយ រូបកាយពួកគេបាត់មែន តែទង្វើរបស់ពួកគេស្ថិតក្នុងដួងចិត្តមនុស្សជារៀងរហូត ។

# អ៊ូម៉ើរកូនអាប់ឌុលអាហ្ស៊ីស

## (៩៧-៩៩ ម.ស/៧១៧-៧២០ គ.ស)

**អាប់ឌុររ៉ស់ម៉ាន:** នៅក្នុងសម័យរបស់អ៊ូម៉ើរអាល់ខត្តប លោកបានរៀបចំអោយមានការចុះត្រួតពិនិត្យគ្រប់ទីកន្លែង ពេលយប់មួយនោះ លោកចាប់ផ្តើមខណៈនោះលោកបានឮស្ត្រីម្នាក់និយាយទៅកាន់កូនស្រីរបស់នាងថា:កូនទៅយកទឹកដោះ( ទឹកដោះពពែ) លាយជាមួយទឹកមកអោយម្តាយ ។ កូនបានឆ្លើយប្រាប់ម្តាយវិញថា:ថ្នាក់ដឹកនាំគឺអ៊ូម៉ើរអាល់ខត្តបបានហាមឃាត់ការយកទឹកដោះទៅលាយបន្លំជាមួយទឹក ។ ម្តាយរបស់នាងបានតបថា: ពេលនេះអ៊ូម៉ើរនៅឯណា? ធ្វើភ្លាមទៅ? កូនស្រីបានឆ្លើយថា: ពិតមែនថាពេលនេះអ៊ូម៉ើរអវត្តមានពីទីនេះមិនអាចឃើញពួកយើងមែន តែម្ចាស់របស់ អ៊ូម៉ើរ ( អល់ឡោះ) ឃើញពួកយើងគ្រប់សកម្មភាពទាំងអស់ ។

**ហ៊ូសាម:** ឱអាប់ឌុររ៉ស់ម៉ាន! បញ្ហាដែលអ្នកលើកមកដូចប្លែក! តើអ្នកភ្លេចឬយ៉ាងណាបានជាវិលទៅនិយាយពីប្រវត្តិរបស់អ៊ូម៉ើរអាល់ខត្តប អាល់ហ្វារូកទៅវិញ? ។ អ្នកត្រូវដឹងថាពួកយើងបានពណ៌នារួចហើយពីជីវប្រវត្តិរបស់អាល់ហ្វារូកនោះ ដូចគ្នាដែរជីវប្រវត្តិរបស់ឧស្មាននិងអាលីគឺពួកយើងបានពណ៌នារួចហើយ ប្រហែលជាពេលនោះអ្នកអវត្តមានពីពួកយើង!

**អាប់ឌុររ៉ស់ម៉ាន :** បើអ្នកមិនប្រញាប់ពេកទេ អ្នកច្បាស់ជាបានយល់ជាមិនខាន ព្រោះខ្ញុំត្រៀមពន្យល់អោយល្អ តែមិនថ្វីទេ សូមអល់ឡោះអនុគ្រោះដល់រូបអ្នក សង្ឃឹមថាអ្នកនឹងមិននិយាយកាត់ខ្ញុំទៀតទេ។ ខ្ញុំបានពណ៌នាពី



ក្មេងស្រីដែលបានប្រកែក មិនព្រមយកទឹកដោះទៅលាយជាមួយទឹកខ្ញុំនិយាយមិនទាន់ចប់ទេពីព្រោះអ្នកបាននិយាយកាត់ពាក្យសំដីខ្ញុំ ។ តែឥឡូវខ្ញុំបន្តទៀតខ្ញុំសូមបញ្ជាក់ថា:ស្រីនោះជាជីដូនរបស់ថ្នាក់ដឹកនាំដែលយុត្តិធម៌គឺលោកអ៊ូម៉ើរកូនអាប់ឌុលអាហ្ស៊ីស ។

**ហ៊ូសាម :** សូមអ្នកអភ័យទោសអោយខ្ញុំផង ខ្ញុំសង្ឃឹមថា: អ្នកនឹងទទួលនូវការសុំទោសពីខ្ញុំ ចុះអ្វីទៅជាទំនាក់ទំនងអ៊ូម៉ើរកូនអាល់ខត្តបជាមួយក្មេងស្រីនោះ?

**អាប់ឌុររ៉ម៉ាន:** មិនជាអ្វីទេ! ពួកយើងជាបងប្អូននឹងគ្នា( នៅក្នុងសាសនាតែមួយ) ខ្ញុំក៏សូមអរគុណច្រើនចំពោះអ្នកផងដែរ ដែលអ្នកបានដាស់តឿនរំលឹកដល់រូបខ្ញុំអោយមានការយកចិត្តទុកដាក់ប្រុងប្រយ័ត្ននិងស្វែងយល់នូវអ្វីដែលពួកយើងបានសិក្សាស្រាវជ្រាវពាក់ព័ន្ធទៅនឹងប្រវត្តិ ដ៏មានសារៈសំខាន់ទាំងនេះ។ និយាយបន្តទៀត: គឺនៅពេលដែលអ៊ូម៉ើរបានឮ ស្ត្រីជាម្តាយនិយាយទៅកាន់កូនស្រីរបស់នាង( អោយយកទឹកដោះពពែលាយជាមួយទឹក) ហើយកូនស្រីបានប្រកែក ស្រាប់តែអ៊ូម៉ើរបានប្រញាប់ប្រញាល់ទៅជួបកូនប្រុសរបស់លោកឈ្មោះអាស៊ីម ហើយនិយាយប្រាប់កូនថា: កូនរៀបការជាមួយក្មេងស្រីនោះទៅ ព្រោះនាងជាក្មេងស្រី ដែលពោរពេញដោយពរជ័យ ។ អាស៊ីមក៏យល់ព្រម រៀបអាពាហ៍ពិពាហ៍ជាមួយក្មេងស្រីនោះ។ អ្នកទាំងពីរក៏បានកូនស្រីម្នាក់ ដាក់ឈ្មោះថា"ឡៃឡា" ។ គេបានដាក់ងារឡៃឡាថា"អ៊ុមមុលអាស៊ីម" ។ ក្រោយមកអ៊ុមមុលអាស៊ីមបានរៀបការជាមួយអាប់ឌុល

អាហ្ស៊ីសកូនម៉ារវ៉ាន ហើយអ្នកទាំងពីរបានកូនប្រុសម្នាក់ដាក់ឈ្មោះថាអ៊ូម៉ើរ កូនអាប់ឌុលអាហ្ស៊ីស ។

**ហ្វារ៉ហ៏:** ខ្ញុំចង់បន្ថែមបន្តិចលើបញ្ហានេះ សង្ឃឹមថាវាអាចផ្តល់ជាប្រយោជន៏ដល់ពួកអ្នក ហើយរូបខ្ញុំក៏មានសេចក្តីសោមនស្សរីករាយផងដែរ ខ្ញុំបានចូលរួមចំណែកជាមួយអ្នកទាំងអស់គ្នា ខ្ញុំចង់និយាយថា: នៅយប់មួយនោះ លោកអ៊ូម៉ើរអាល់ខត្តបក្រោកពីដំណេករួចនិយាយសួរថា: "អ្នកដែលមានស្នាមរបួសនៅលើថ្ងាស ហើយនឹងគ្រប់គ្រងលោកីយ៏នេះប្រកបដោយភាពយុតិធម៌នោះជានរណា?

## កំណើតរបស់អ៊ូម៉ើរអាប់ឌុលអាហ្ស៊ីស

**ម៉ាស់ម៉ូដ:** លោកអ៊ូម៉ើរបានចាប់កំណើតក្នុងឆ្នាំ ៦១ឬ៦៣ម.ស ។

**ហ៊ូសាម:** មុននឹងយើងនិយាយពីថ្ងៃកំណើតរបស់លោកនោះគឺយើងត្រូវស្វែងយល់ពីជីវប្រវត្តិរបស់លោកជាមុនសិន ។

**ណាដា :** លោកម៉ាវ៉ានកូនហាគីមទទួលតំណែងឋានៈជាមេដឹកនាំ ។ បន្ទាប់មកម៉ាវ៉ានក៏បានបញ្ជាអោយស្រុកស្ហាមទទួលស្គាល់និងស្វាគម៏កូនប្រុសទាំងពីររបស់លោកគឺអាប់ឌុលម៉ាលិក និងអាប់ឌុលអាហ្ស៊ីសជាអ្នកស្នងតំណែងបន្ទាប់អំពីលោក ។ លោកអាប់ឌុលអាហ្ស៊ីសបានក្លាយជាមេដឹកនាំក្នុងតំណែងបន្ត( សំរាប់អនាគត) និងជាមេដឹកនាំទទួលខុសត្រូវលើប្រទេសអេហ្ស៊ីប ។ អាប់ឌុលអាហ្ស៊ីស ក៏ចាប់ផ្តើមទៅរស់នៅក្នុងវាំង ។ អាប់ឌុលអាហ្ស៊ីសមាន



ក្រោលសេះមួយ ថ្ងៃមួយអ៊ូម៉ើរហ៊្គិនអាប់ឌុលអាហ្ស៊ីសបានចូលទៅក្នុងក្រោលនោះស្រាប់តែមានសេះមួយក្បាលធាក់គាត់ ធ្វើអោយគាត់របួសចំក្បាលមានឈាមហូរស្រក់មកលើផ្ទៃមុខរបស់លោក ។ ឪពុករបស់លោកគឺអាប់ឌុលអាហ្ស៊ីសហ៊្គិនម៉ារវ៉ានបានមកដល់ ដោយឃើញស្នាមរបួសនៅលើថ្ងាសរបស់កូនគាត់ លោកបាននឹកឃើញពាក្យសំដីរបស់អ៊ូម៉ើរអាល់ខត្តបថា: ពីពូជពង្សរបស់ខ្ញុំនឹងមានបុរសម្នាក់មានស្នាមរបួសនៅក្បាល (ចង់និយាយសំដៅទៅលើអ៊ូម៉ើរហ៊្គិនអាប់ឌុលអាស្ស៊ីស) ហើយរូបគេនឹងត្រូវគ្រប់គ្រងលោកីយ៏នេះប្រកបដោយភាពយុត្តិធម៌ ។ ពេលនឹកដល់រឿង អាប់ឌុលអាហ្ស៊ីសញញឹមរួចអោបកូនរបស់លោក( អ៊ូម៉ើរហ៊្គិនអាប់ឌុលអាស្ស៊ីស) រួចនិយាយទៅកាន់កូនទាំងក្តីរំភើបថា: បើកូនមានទុកព្រួយដូចត្រកូលអ៊ូម៉ៃយ៉ះមែននោះគឺកូននឹងទទួលបានសុភមង្គលមិនខាន ។

**ឪពុក:** អ៊ូម៉ើរហ៊្គិនអាប់ឌុលអាហ្ស៊ីសតែងតែស្រគត់ស្រគំនឹកគិតដល់ថ្ងៃដែលអល់ឡោះបង្កើតឡើងវិញ ហើយនឹកគិតដល់ការវិនិច្ឆ័យទោស លោកមានព្រឺស្បែករួចលោកយំដោយក្តីរន្ធត់ពីព្រោះតែការកោតខ្លាចអល់ឡោះ ។ខណៈដែលម្តាយរបស់លោកឈ្មោះឡៃឡា ចូលមករកកូនស្រាប់តែអ្នកស្រីឃើញកូនកំពុងតែយំ អ្នកស្រីបានសួរកូនថា:ហេតុអ្វីបានជាកូនយំ!? កូនឆ្លើយប្រាប់ម្តាយថា:ម្តាយជាទីស្រលាញ់! ខ្ញុំបាននឹកគិតដល់សេចក្តីស្លាប់ ខ្ញុំអត់ទ្រាំមិនបានក៏យំទៅ ។

**ម៉ាស់ម៉ូដ:** តើភាពរន្ធត់ និងការកោតខ្លាចចំពោះអល់ឡោះ ប្រៀបបាននឹង

ភាពរន្ធត់និងការកោតខ្លាចរបស់ជីតាលោកគឺអ៊ូម៉ើរអាល់ខត្តបដែរឬទេ?

**ម៉ាស់ម៉ូដះ** គឺមិនខុសទេ! ជាការពិតណាស់រឿងរ៉ាវប្រកបដោយមោទនៈនិងថ្លៃថ្នូររបស់ អ៊ូម៉ើរ កូនរបស់អាប់ឌុលអាហ្ស៊ីសក្នុងកិច្ចការគ្រប់គ្រង ។ អ៊ូម៉ើរអាប់ឌុលអាហ្ស៊ីសបានសំណូមពរម្តាយរបស់លោក អោយរំលឹកណែនាំលោកបន្ថែមទៀត ធ្វើយ៉ាងណាអោយសកម្មភាព របស់លោកបានដូចជីតារបស់លោកគឺអ៊ូម៉ើរអាល់ខត្តបអាល់ហ្វារូកក្នុងកិច្ចបំរើអ្នកក្រីក្រខ្វះខាតនិងអ្នកនៅក្រោមឱវាទ ។ លោកអ៊ូម៉ើរហ្គិនអាប់ឌុលអាហ្ស៊ីសក៏ទៅជួបជីតារបស់លោកផងដែរគឺអាប់ឌុលឡោះកូនអ៊ូម៉ើរដើម្បីសាកសួរអំពីរឿងនេះ ។អាប់ឌុលឡោះកូនអ៊ូម៉ើរបានពណ៌នាពីដំណើរជីវិតរបស់អ៊ូម៉ើរហ្គិនខ្គតបប្រាប់ដល់អ៊ូម៉ើរហ្គិនអាប់ឌុលអាហ្ស៊ីស ។

**ហ្វាទីម៉ះ** ឥឡូវនេះពួកយើងត្រូវវិលត្រលប់ទៅស្វែងយល់ពីជីវប្រវត្តិរបស់អ៊ូម៉ើរហ្គិនអាប់ឌុលអាហ្ស៊ីសវិញ អម្បាញ់មិញ ពួកយើងនិយាយដល់កន្លែងដែលអ៊ូម៉ើរហ្គិនអាប់ឌុលអាហ្ស៊ីសចូលចិត្តការរៀនសូត្រ និងស្រាវជ្រាវច្បាប់នៅក្នុងសាសនាអ៊ីស្លាម ។

## ការរស់នៅក្នុងម៉ាឌីណះ

**អ៊ីណាសៈ** ឱបងប្អូន! ប្រាកដណាស់ខ្ញុំបានអាននៅក្នុងសៀវភៅរបស់អាប់ឌុលអាហ្ស៊ីសកូនម៉ារវ៉ានបានបង្ហាញថា:លោកម៉ារវ៉ានកូនហាគីមដែលជាមេដឹកនាំគឺពេលដែលលោកបានធ្វើដំនើរទៅកាន់ប្រទេសអេហ្ស៊ីបដើម្បីអោយគេសច្ចាទទួលស្គាល់មេដឹកនាំ ។ លោកបានទុកកូនប្រុសរបស់លោកអាប់ឌុលអាហ្ស៊ីស



អោយគ្រប់គ្រងនៅអេហ្ស៊ីប ។បន្ទាប់មកទៀតលោកបានផ្តាំផ្ញើថាអ្នកដែលត្រូវទទួលការដឹកនាំបន្តទៀតគឺអោយអាប់ឌុលម៉ាលិក ហើយបន្ទាប់ពីអាប់ឌុលម៉ាលិកគឺអោយទៅបងប្អូនរបស់ខ្លួនគឺអាប់ឌុលអាហ្ស៊ីសជាអ្នកបន្តវេនគ្រប់គ្រងបន្ទាប់ ។

**ណាជា:** នៅពេលអាប់ឌុលម៉ាលិកកូនម៉ារវ៉ានក្លាយជាមេដឹកនាំ លោកក៏បានប្រគល់អោយប្អូនប្រុសរបស់លោកអាប់ឌុលអាហ្ស៊ីសគ្រប់គ្រងនៅអេហ្ស៊ីបបន្ត ។ លោកអ៊ូម៉ើរហ្គិនអាប់ឌុលអាហ្ស៊ីសបានស្នើសុំឪពុករបស់លោកអោយអនុញ្ញាតដល់លោកធ្វើដំនើរទៅម៉ាទីណះ ដែលជាទីកន្លែងនិងជាទីកដីរបស់រ៉ស៊ូលុលឡោះក្នុងបំណងស្វែងរកចំនេះវិជ្ជា និងបានជួបពពួកអាល់អាន់សរ៍ទាំងអស់ដែលពួកគេធ្លាប់បានជួយគាំទ្ររ៉ស៊ូលុលឡោះ ។

**ហ្វារ៉ហ៌ :** អ៊ូម៉ើរអាប់ឌុលអាហ្ស៊ីសនិយមសំលៀកបំពាក់សរសៃពីសូត្រ ។ ពេលមួយលោកបានយកសំលៀកបំពាក់ផលិតចេញ ពីសរសៃសូត្រកាន់ជាប់នឹងដៃរបស់លោករួចនិយាយថា: វាស្អាតណាស់!បើវាមិនធ្វើអោយអ្នកពាក់ក្លាយជាកោងកាចទេនោះ ។

**ហ្ស៊ីយ៉ាដះ** អល់ឡោះជាម្ចាស់ដ៏ស្អាតស្អំ! នេះជារឿងមួយគួរអោយស្ញប់ស្ញែងណាស់ បើពាក់សូត្រនឹងរស់នៅបែបត្រកូលខ្ពង់ខ្ពស់ ព្រោះវាអាចធ្វើអោយគាត់ផ្លាស់ប្តូរចរិកលក្ខណ:ពេលគាត់ក្លាយជាមេដឹកនាំ! ។

**មូហាំម៉ាត់:** អស្ចារ្យមែន! តាមពិតគាត់មិននិយមស្លៀកពាក់សរសៃសូត្រទេផ្ទុយទៅវិញគាត់ចូលចិត្តភាពថ្កុំថ្កើងជាងនេះនិងមានតំលៃជាងក្រណាត់សូត្រនេះទៅទៀត? ប៉ុន្តែហេតុអ្វីបានជាអ្នកហួសចិត្តចំពោះរូបគាត់ បើរូបគាត់ជា

មេដឹកនាំនោះ?

**មូហាំម៉ាត់:** ខ្ញុំមានចំណាប់អារម្មណ៍មួយថាក្រណាត់សរសៃសូត្រ វាជាប្រការម៉ាក្រូស(ប្រការដែលគួរបោះបង់) តែតាមពិតវាប្រការហារ៉ាំ (បំរាមដាច់ខាត) លើបុរសភេទ។

**ហ្សីយ៉ាដ:** នៅពេលបានឋានៈជាមេដឹកនាំនោះ លោករស់នៅជាលក្ខណៈជាអ្នកក្រីក្រលំបាកម្នាក់ ។ លោកប្រើសំលៀកបំពាក់សាមញ្ញ ទទួលទានតែបន្លែឆាជាមួយប្រេងប៉ុណ្ណោះ។

**ឪពុក:** លោកជាមេដឹកនាំដែលប្រកបដោយការទទួលខុសត្រូវ និងស្មោះត្រង់

**ហ៊ីសាម :** បងប្អូនទាំងអស់គ្នា ! ខ្ញុំមានចំណាប់អារម្មណ៍ខ្លាំងណាស់ចំពោះលោកអ៊ូម៉ើរកូនអាប់ឌុលអាហ្ស៊ីស ជាមេដឹកនាំដែលមានការលះបង់ខ្ពស់ក្នុងការស្វែងរកចំណេះវិជ្ជានិងជាអ្នកដាក់ខ្លួនដាក់កាយទទួលយកការណែនាំពីសំណាក់សាសនវិទូអ៊ីស្លាម ។លោកទទួលបានផ្លែផ្កានៃវិជ្ជាពេញខ្លួនបានក្លាយជាអ្នកមានចំណេះវិជ្ជាដ៏ខ្ពង់ខ្ពស់ម្នាក់ ។ខ្ញុំបានអានឯកសាររបស់លោក មូហាំម៉ាត់កូនកាអាប់អាល់គូរទូហ្ពីដែលលោកបានផ្តល់ការរំលឹកណែនាំដល់លោកអ៊ូម៉ើរកូនអាប់ឌុលអាហ្ស៊ីសដែលមានអត្ថន័យដូចខាងក្រោម:" សូមអ្នកកុំសេពគប់មិត្តភក្តិក្នុងចំណោមមិត្តភក្តិណាដែលមិននឹកនាដល់រូបអ្នកលើកលែងតែពេលណាដែលគេត្រូវការរូបអ្នកអោយសោះ ផ្ទុយទៅវិញសូមអ្នកសេពគប់មិត្តភក្តិណាដែលចេះជំរុញអ្នកអោយធ្វើកុសល្បល្អ ហើយអ្នកត្រូវខំអត់ធ្មត់អោយខាងតែបានបើប្រការនោះជាការពិត។



**ហ្វាទីម៉ះ:** សាសនវិទូអ៊ីស្លាមបានផ្តល់ដំបូន្មានរំលឹកដាស់តឿន អ៊ូម៉ើរកូនអាប់ឌុលអាហ្ស៊ីស លោកទទួលយកការដាស់តឿនរំលឹកទាំងនោះរហូតដល់ក្លាយជាអ្នកចេះដឹងជ្រៅជ្រះម្នាក់។ ទាំងនេះជាការប្រពៃខ្លាំងណាស់ចំពោះភាពទន់ភ្លន់សុភាពរាបសាររបស់លោក!។

## ស្រុកហ៊ុលវ៉ាននិងលោកអ៊ូម៉ើរអាប់ឌុលអាហ្ស៊ីស

**មូហាំម៉ាត់ :** បងស្រី! ជាការពិតណាស់ លោកអ៊ូម៉ើរជាបុរសមានលក្ខណៈទន់ភ្លន់សុភាពរាបសារ និងលើកតំកើងអ្នកមានចំណេះវិជ្ជាទាំងឡាយដែលកោតខ្លាចគោរពសក្ការៈអល់ឡោះជាម្ចាស់។ ពិតប្រាកដណាស់ មានពាក្យសរសើរដល់លោកអ៊ូម៉ើរថា:"ជាការពិតណាស់អ្នកមានចំណេះវិជ្ជាជាមួយនឹងលោកអ៊ូរម៉ើរចាត់ទុកជាគ្រូនិងសិស្ស។

**អះម៉ាត់ :** មុននឹងពួកយើងចូលទៅកាន់ប្រវត្តិដ៏ស្ញប់ស្ញែងរបស់ អ៊ូម៉ើរអាប់ឌុលអាហ្ស៊ីសយើងហាក់ដូចជាឃ្លាតឆ្ងាយបន្តិចហើយតែឥឡូវនេះខ្ញុំមានបំណងចង់បង្ហាញនូវចំណេះដឹងមួយដែលមានសារៈសំខាន់ដល់ពួកអ្នក ព្រោះមានអ្នកខ្លះក្នុងចំណោមពួកយើងក៏មិនទាន់បានដឹងនៅឡើយទេនោះគឺតំបន់ហ៊ុលវ៉ាន។

**ហ្សីយ៉ាដ:** ហ៊ុលវ៉ាន ជាស្រុកមួយនៅប្រទេសអេហ្ស៊ីបបច្ចុប្បន្ននេះមែនទេ?

**អះម៉ាត់:** ពិតមែនហើយ! លោកអាប់ឌុលអាហ្ស៊ីសកូនម៉ារវ៉ានធ្លាប់បានរស់នៅក្រុងហ៊ុលវ៉ានខ្ញុំចង់និយាយថាអ្នកកសាងស្រុកនេះគឺអ្នកគ្រប់គ្រងប្រទេស

អេហ្ស៊ីបនោះគឺលោកអាប់ឌុលអាហ្ស៊ីសកូនម៉ាវវ៉ាន ។ នៅទីនោះលោកបានកសាងនូវសមិទ្ធិផលជាច្រើនដូចជាៈកសាងម៉ាស្ជិតសួនច្បារកន្លែងទេសចរណ៍ ទីផ្សារជាច្រើនទៀត ។

**អ៊ីស្លាម** :បាទ! ពិតមែនហើយ លោកមានឈ្មោះ ល្បីល្បាញនៅក្នុងការរៀបចំកែរលំអអភិវឌ្ឍន៍ និងធ្វើអោយប្រទេសអេហ្ស៊ីបបានរីកចំរើនស្ទើរតែគ្រប់ទីកន្លែងទាំងអស់ ។

## ការបង្រួបបង្រួមជាតិ

**ហ៊ីសាម** : ជាការពិតណាស់បណ្តាមិត្តភក្តិសំលាញ់របស់ណាហ្ពីដ៏ឧត្តុងឧត្តម និងបណ្តាអ្នកបន្ទាប់ពីពួកគាត់ដ៏បរិសុទ្ធ ពួកគេទាំងអស់បានខិតខំប្រឹងប្រែងផ្សះផ្សាលើការបង្រួបបង្រួមទឹកដីតែមួយនៅគ្រប់កន្លែងបំណងផ្សព្វផ្សាយសាសនាអ៊ីស្លាមត្រង់នេះជាភស្តុតាងដ៏ពិសិដ្ឋបង្ហាញអោយពិភពលោក ដឹងថាសាសនាអ៊ីស្លាមមិនរីកដាលដោយសារដាវនោះទេ ជឿឬមិនជំនឿអាស្រ័យទៅលើបុគ្គល ។អល់ឡោះមានបន្ទូលនៅជំពូកហ៊ូដវាក្យខ័ណ្ឌ១១៨មានន័យថា "ប្រសិនបើម្ចាស់របស់អ្នក (មូហាំម៉ាត់) ចង់ច្បាស់ជាទ្រង់ធ្វើមនុស្សលោកទាំងមូលក្លាយជាប្រជាពលរដ្ឋតែមួយក្រុមមិនខាន គឺពួកគេនឹងមិនខ្វែងយោបល់គ្នា(ដូចសព្វថ្ងៃនេះឡើយ) ។ អល់ឡោះបានមានបន្ទូលនៅក្នុងជំពូកយូណូសវាក្យខ័ណ្ឌ៩៩ដែលមានន័យថាៈប្រសិនបើម្ចាស់របស់អ្នក(មូហាំម៉ាត់) ចង់ច្បាស់ជាមនុស្សម្នាទាំងអស់នៅលើផែនដីនេះមានសន្តិសុខមិនខានតើអ្នក



ចង់បង្ខំមនុស្សលោកទាំងអស់ អោយពួកគេមានជំនឿឬ?" ។

**អាប់ឌុររ៉ស់ម៉ាន** : លោកអ៊ូម៉ើរបានរស់នៅទឹកដីនៃប្រទេសអេហ្ស៊ីប និងតំបន់ហ៊ុលវ៉ាន មុនពេលលោករស់នៅស្រុកម៉ាឌីណះដែលជាប្រភពរស្មីនៃវិជ្ជានិងសាសនាអ៊ីស្លាម ។រីឯឪពុករបស់លោកបានបន្តរស់នៅប្រទេសអេហ្ស៊ីបក្រោយមកលោកអ៊ូម៉ើរបានទៅទស្សនៈកិច្ចប្រទេសអេហ្ស៊ីបផងដែរ ។

**ណាដា** : លោកបានធ្វើដំនើរទៅកាន់ស្រុកហ៊ុលវ៉ានដើម្បីរស់នៅទីនោះ ។ លោកពេញចិត្តទន្លេនីលរបស់ប្រទេសអេហ្ស៊ីប ហើយប្រជាជននៅទីនោះក៏ស្រលាញ់ពេញចិត្តសាសនាអ៊ីស្លាម ស្រលាញ់មាគ៌ារបស់ណាហ្ពីនិងស្រលាញ់បណ្តាមិត្តភក្តិដែលជាទីគាប់ចិត្តរបស់ណាហ្ពីផងដែរ ។

**ហ្វារ៉ហ៊ី** : ឪពុករបស់លោកអ៊ូរម៉ើរគឺអាប់ឌុលអាហ្ស៊ីសកូនម៉ាវវ៉ានល្បីខាងកិត្តិយសដ៏ឧត្តុងឧត្តម និងចិត្តមេត្តាធម៌ ហើយស្រលាញ់ចំនេះវិជ្ជា និងចូលចិត្តស្វែងយល់ពីច្បាប់សាសនាអ៊ីស្លាម មិនតែប៉ុណ្ណោះលោកក៏ជាអ្នកគោរពប្រតិបត្តិនិងកោតខ្លាចម្នាក់ ។ លោកបានរៀបចំអោយមានសិក្ខាសាលាសំរាប់ថ្នាក់សាសនវិទូ និងអ្នកជំនាញខាងកំណាព្យ លោកក៏ជាអ្នកជំរុញកូនចៅអោយដើរតាមសុជីវធម៌របស់អ៊ីស្លាមដ៏ឧត្តុង្គឧត្តមផងដែរ ។

**ហ្ស៊ីយ៉ាដ** : លោកអាប់ឌុលអាហ្ស៊ីសកូនម៉ាវវ៉ានបានបន្សល់ទ្រឹស្តីមួយថាៈ (អស្ចារ្យណាស់! អ្នកមានជំនឿមួយចំនួនគេប្រាកដក្នុងចិត្តថាៈ អល់ឡោះផ្តល់លាភសក្ការៈហើយគេក៏ប្រាកដក្នុងចិត្តដែរថាអល់ឡោះនឹងសងគេវិញនៅផលបុណ្យធំធេងមិនខាន) ។

**មូហាំម៉ាត់** :អត្ថន័យពិតរបស់វា គឺការចំណាយនៅក្នុងផ្លូវល្អ ផ្លូវកុសល និង មិនកំណាញ់ស្វិតឡើយ ។ ការចំណាយលើផ្លូវកុសល អល់ឡោះជាម្ចាស់នឹង សងវិញយ៉ាងធំធេង ហើយអល់ឡោះនឹងបន្ថែមឋានៈដ៏ខ្ពង់ខ្ពស់ដល់បណ្ដា អ្នកមានជំនឿនៅថ្ងៃបរលោកខាងមុខ ។

## អាពាហ៍ពិពាហ៍លោកអ៊ូម៉ើរ

**ហ៊ូសាម**ៈលោកអ៊ូម៉ើរកូនអាប់ឌុលអាហ្ស៊ីសបានរៀបអាពាហ៍ពិពាហ៍ជាមួយ កូនស្រីឪពុកមា( លោកអាប់ឌុលម៉ាលិកកូនម៉ារវ៉ាន )ខ្លួនគឺនាងហ្វាទីម៉ះកូន ស្រីអាប់ឌុលម៉ាលិក ។

**អះម៉ាត់** : នៅសម័យដែលដឹកនាំដោយលោកវ៉ាលីដ លោកបានតែងតាំង អ៊ូម៉ើរកូនអាប់ឌុលអាហ្ស៊ីសអោយគ្រប់គ្រងក្រុងម៉ាឌីណះ ។

**មូហាំម៉ាត់** : ក្រុងម៉ាឌីណះ គឺជាទឹកដីអល់ឡោះដែលជាទីស្រលាញ់សំរាប់ អ៊ូម៉ើរជាងគេ ។

**ហ្ស៊ីយ៉ាដ** : នៅពេលសឡាហ៍ស៊ូហ្វ៊ូររួច អ៊ូម៉ើរបានកោះហៅ សាសនវិទូផ្នែក ច្បាប់អ៊ីស្លាមនៅក្រុងម៉ាឌីណះមកជួបជុំគ្នា ។ ពួកគេមានគ្នាចំនួន១០រូប បីនាក់ក្នុងចំណោមពួកគេគឺជាពូជអំបូររបស់លោកអ៊ូម៉ើរ កូន ខត្តប ។ អ៊ូម៉ើរ បានសំណូមពរអោយពួកគេចូលរួមពិភាក្សា និងផ្ដល់ដំបូន្មានដល់លោកផង ។ លោកជាអ៊ីមុាំប្រចាំនៅម៉ាស្ជិតរបស់រ៉ស៊ូលុលឡោះ ។

## ឧត្តមភាពរបស់លោកអ៊ូម៉ើរអាប់ឌុលអាហ្ស៊ីស

**ហ៊ូសាម**ៈ ខ្ញុំមានពតិមានល្អៗ ដែលក្នុងនោះ ខ្ញុំបានដឹងពីភាពអស្ចារ្យរបស់



អ៊ូម៉ើរ គឺនៅក្នុងឆ្នាំដែលលោកបានទទួលតំណែងជាថ្នាក់ដឹកនាំនៅទីក្រុង ម៉ាឌីណះ លោកបានទៅធ្វើហាជ្ជី ឆ្នាំនោះផងដែរគឺជាឆ្នាំដែលជួបគ្រោះរាំង ស្ងួត ។ អ៊ូម៉ើរ ធ្វើការបួងសួងសុំពីអល់ឡោះស្រាប់តែទឹកភ្លៀងបង្អោរយ៉ាង ខ្លាំងបន្ទាប់ពីពេលដែលអល់ឡោះ ទទួលយកនូវការបួងសួងសុំរបស់លោក ។

**ហ្វាទីម៉ះ** : អល់ឡោះជាម្ចាស់! ខ្ញុំក៏មានរឿងអស្ចារ្យមួយផងដែរ ស្ដីពីភាព ទន់ភ្លន់ ការកោតខ្លាចចំពោះអល់ឡោះនិងការប្រគល់ខ្លួនរបស់លោកចំពោះ អល់ឡោះដ៏ឧត្តុងឧត្តមបំផុត ។ គ្រាមួយនោះ គឺនៅពេលដែលលោកកំពុង សឡាហ៍ ស្រាប់តែភ្លើងបានឆាបឆេះផ្ទះរបស់លោក ពេលនោះមានសំលេង ស្រែកថាៈភ្លើងបានឆេះផ្ទះលោកអ៊ូម៉ើរហើយ! តែលោកនៅតែបន្តសឡាហ៍ ទាល់តែចប់រួចរាល់ ។ លុះពេលគេសួរលោកក្នុងការមិនព្រមឈប់សឡាហ៍ នោះ លោកឆ្លើយថាៈ ភ្លើងនរកអវិចីយ៍វារំខានខ្ញុំជាងភ្លើងលោកីយ៍! ។

**ហ៊ូសាម** : ពេលលោកយកទឹកវូហ្ទុ លោកញ័រខ្លួន មុខឡើងស្លេកស្លាំងខណៈ នោះមានគេសួរលោក( បញ្ហាស្លេកស្លាំង) លោកមានប្រសាសន៍ថាៈតើពួកអ្នក ទាំងអស់គ្នាមានដឹងទេថាៈ ខ្ញុំឈរនៅចំពោះអ្នកណា? ។

**មូហាំម៉ាត់** : ឥឡូវនេះខ្ញុំមានការសោកស្ដាយខ្លាំងណាស់ ពីព្រោះខ្ញុំនូវរង់ចាំ យ៉ាងអន្ទះសារក្នុងបំណងចង់អោយពួកអ្នកស្ដាប់ខ្ញុំពីដំណើររឿងរបស់មេដឹក នាំអ៊ូម៉ើរកូនអាប់ឌុលអាហ្ស៊ីស ។

**ម៉ាស់ម៉ូដ** : នៅពេលលោកសូឡៃម៉ានហ្គិនអាប់ឌុលម៉ាលិកត្រូវបានគេតែង តាំងជាមេដឹកនាំ លោកក៏ជ្រើសរើសអ៊ូម៉ើរកូនអាប់ឌុលអាហ្ស៊ីសផងដែរ ។

លោកសូឡៃម៉ានត្រូវបានមនុស្សម្នាដាក់នាមអោយគាត់ថា"កូនសោនៃអំពើល្អ"លោកធ្លាប់បានដោះលែងឈ្លើយសឹកនិងអ្នកជាប់ពន្ធធនាគាជាច្រើននាក់

**ហ្ស៊ីយ៉ាដ :** មុនពេលពួកយើងបន្តសាច់រឿងមេដឹកនាំអ៊ូម៉ើរនោះ ពួកយើងរំលឹកពីកិច្ចការរបស់លោកនៅទឹកដីម៉ាឌីណះក្នុងអំឡុងពេលដែលលោកកាន់តំណែង ។

**អាប់ឌុរ៉ស់ម៉ាន:** យើងត្រូវវិលត្រលប់ទៅសាច់រឿងអ៊ូម៉ើរដែលជាមេដឹកនាំនៅម៉ាឌីណះ ។ពួកយើងសង្កេតឃើញថា: សច្ចៈភាពសុវត្ថិភាពសង្គម និងការអាណិតស្រលាញ់ត្រូវបានរីកសុះសាយ ។

**មូហាំម៉ាត់:**លោកបានសាងសង់មិស្ជិតណាប៊ីជាថ្មី បញ្ចូលថ្នាក់ដឹកនាំតំបន់អោយទៅរៀបចំទឹកដីស្រុកហ៊ីយើស(ទឹកដីនៅតំបន់អារ៉ាប់សាអ៊ូឌីត) ប្រើអោយពួកថ្នាក់ដឹកនាំតំបន់ជីកអណ្តូងទឹក និងសាងសង់ផ្លូវជាច្រើនទៀត ។

**អះម៉ាត់** :លោកអ៊ូម៉ើរមិនដែលធ្វេសប្រហែសពាក្យសំដីដ៏ម៉ឺងម៉ាត់របស់ពួកមេដឹកនាំនៃអំបូរអ៊ូមៃយ៉ះឡើយ ។

## ភាពជ្រះស្អាតពីការភូតកុហក

**ហ្វារ៉ហ៍:** ខ្ញុំនឹកឃើញរឿងមួយសំលាញ់! ពេលមួយអ៊ូម៉ើរបាននិយាយកិច្ចការមួយចំនួនជាមួយលោកវ៉ាលីដ ដែលជាមេដឹកនាំរបស់មូស្លីមពេលនោះលោកវ៉ាលីដ បាននិយាយទៅកាន់ អ៊ូម៉ើរ ថា:អ្នកកុហក (ក្នុងរឿងនោះ)លោកថាដូច្នេះក្រោយការទទួលដំណឹងពីការចោទប្រកាន់មកលើអ៊ូម៉ើរ ។ អ៊ូម៉ើរបាន



តបនឹងលោក វ៉ាលីដ វិញថា: ឱ លោកថ្នាក់ដឹកនាំខ្ញុំ! មិនដែលនិយាយកុហកចាប់តាំងតែពីខ្ញុំដឹងថា ការភូតកុហកនាំអោយអាប់ឱនកិត្តិយសដល់ខ្លួនអ្នកភូតកុហក ។

**អៃម៉ាន:** បន្ទាប់មកលោកវ៉ាលីដបានដកអ៊ូម៉ើរចេញពីអ្នកដឹកនាំប្រចាំស្រុកម៉ាឌីណះ ។ អ៊ូម៉ើរមានការព្រួយបារម្ភជាខ្លាំង ។

**ហ្វាទីម៉ះ :** ឥឡូវនេះពួកយើងត្រូវគ្រលេកមើលភាពភ្លឺស្វាងត្រចះត្រចង់នៃតួនាទីដឹកនាំអ្នកមានជំនឿរបស់អ៊ូម៉ើរ ។

## ភាពយុត្តិធម៌ដ៏ខ្ពង់ខ្ពស់របស់អ៊ូម៉ើរ

**ហ្ស៊ីយ៉ាដ :** ប្រទេសទាំងមូលត្រូវតែបានកែលំអរចនាសម្ព័ន តាមរយៈសច្ចៈយុត្តិធមិនៅពេលដែលគេប្រកាសថា លោកអ៊ូម៉ើរក្លាយជាមេដឹកនាំរបស់អ៊ីស្លាមរហូតគេអាចគង្វាលពពែជាមួយចចកបាន ។

**អាប់ឌុរ៉ស់ម៉ាន :** នៅពេលលោកអ៊ូម៉ើរក្លាយជាមេដឹកនាំ លោកមានការផ្លាស់ប្តូរឥរិយាបថយ៉ាងច្រើន ពោលគឺលោកមមាញឹកខ្លាំងរហូតឃ្លាតឆ្ងាយពីក្រុមគ្រួសារ និងពីមិត្តភក្តិរបស់លោក ។ លោកតែងតែទៅជួបរាល់អ្នកដែលជាទីស្រលាញ់របស់លោក ហើយលោកលះបង់អ្វីៗដើម្បីកិច្ចការរបស់អល់ឡោះជាម្ចាស់ ។

## ការជាស់តឿនរបស់កូនអ៊ូម៉ើរចំពោះឪពុកគេ

**អ៊ីស្លាម:** បងប្អូនទាំងអស់! ខ្ញុំនឹងនិយាយរឿងពិតមួយប្រាប់ដល់ពួកអ្នក :

រឿងមួយបានកើតឡើងពីលោកអាប់ឌុលម៉ាលិកកូនរបស់អ៊ូម៉ើរអាប់ឌុល អាហ្សីសជាមួយឪពុករបស់លោកដែលជាថ្នាក់ដឹកនាំ នេះចាត់ទុកជាតំលៃមួយចំពោះការគោរពកោតខ្លាចអល់ឡោះ និងការអនុវត្តន៏តាមមាគ៌ាដែលទ្រង់យល់ព្រម ។ គេនិយាយថាមានយប់មួយលោកអ៊ូម៉ើរនៅពេញមួយយប់មិនដេកសោះ លុះដល់ពេលព្រឹកលោកមានអារម្មណ៏នឿយហត់ជាខ្លាំង ។ លោកបានហៅកូនប្រុសរបស់លោកអាប់ឌុលម៉ាលិកមកជួប រួចនិយាយទៅកាន់កូនថា: ឪពុកចង់ដេកបន្តិចដើម្បីឪពុកក្រោកមកសឡាហ៏ស្ហ៊ូរ បន្ទាប់មកឪពុកនឹងធ្វើការកាត់ក្តីផ្តល់អ្វីដែលគេបំពានទៅអោយម្ចាស់គេវិញ ។ ខណ:នោះកូនប្រុសរបស់លោកគឺអាប់ឌុលម៉ាលិកបាននិយាយទៅកាន់ឪពុកថា: ឱលោកថ្នាក់ដឹកនាំ! លោកសុខចិត្តដេកមុនលោកផ្តល់អ្វីដែលគេបំពានទៅអោយម្ចាស់គេវិញអញ្ចឹងឬ ? តើនរណាធានាថាលោកនឹងមានជីវិតរស់នៅរហូតដល់ពេលរសៀលនោះ ? ឮដូចនោះលោកអ៊ូម៉ើរក្រោកឈរទៅអោបថើបកូនរួចវាចារថា: ការសសើរទាំងឡាយសំរាប់អល់ឡោះជាម្ចាស់ដែលទ្រង់បានផ្តល់អោយកូនរបស់ខ្ញុំ បានរួមចំណែកជួយខ្ញុំលើរាល់កិច្ចការសាសនារបស់ខ្ញុំ ។ សូមអល់ឡោះផ្តល់ជោគជ័យតាមរយ:កូនប្រុសរបស់ខ្ញុំអាប់ឌុលម៉ាលិកផងចុះ! ។

**អ៊ីស្លាម** : ពាក់ពន្ធ័អំពីរឿងនេះ ដូចពាក្យសុភាសិតពិពណ៌នាអោយដឹងថា: "ពិតមែនហើយកូនតោកើតមកអំពីមេតោ" ។



**អាប់ឌុររ៉ម៉ាន** : អល់ឡោះម្ចាស់របស់យើងបានមានបន្ទូលនៅជំពូកអាល់អ៊ិម៉្រន វាក្យខ័ណ្ឌ៣៤ដែលមានន័យថា:"(ពួកគេ) មានពូជអំបូរតៗគ្នា " ។

## ពពែត្រូវគេឃ្វាលជាមួយឆ្កែចចក

**ហ៊ីសាម** : បងប្អូនទាំងអស់គ្នា ! នេះជារឿងមួយចំឡែកដែលនឹកស្មានមិនដល់ដែលវាបានកើតមាននៅក្នុងសម័យអ៊ូម៉ើរកូនអាប់ឌុលអាហ្សីស ។ជាការពិតណាស់មានសេចក្តីរាយការណ៍ដោយម៉ាលិកកូនឌីណើរអោយដឹងថា:នៅពេលដែលលោកស្នងតំណែងជាមេដឹកនាំនោះ គឺសត្វឆ្កែចចកត្រូវគេឃ្វាលជាមួយសត្វពពែ " ។

**មូហាំម៉ាត់**: អល់ឡោះដ៏បរសុទ្ធ ! សត្វឆ្កែចចកដើររកស៊ីជាមួយសត្វពពែ ! វាមិនស៊ីពពែទេដោយសារភាពយុត្តិធម៌របស់អ៊ូម៉ើរ !

**ណាជា** : នៅពេលលោកអ៊ូម៉ើរកូនអាប់ឌុលអាហ្សីសក្លាយជាមេដឹកនាំ ប្រជានុរាស្ត្របានរៀបចំក្បួនដង្ហែសំរាប់លោក តែលោកបានបដិសេធន៏មិនព្រមហើយលោកបែរទៅជិះសេះរបស់ខ្លួនឯងវិញ លោកក៏បានបដិសេធន៏ផងដែរការអោយមានអង្គរក្សការពារសុវត្ថិភាពជូនលោក ។

## ការលះបង់និងភាពទន់ភ្លន់របស់អ៊ូម៉ើរកូនអាប់ឌុលអាហ្សីស

**អះម៉ាត់** : ឱអល់ឡោះម្ចាស់! ប្រសើរអ្វីម្លេះទេ ចំពោះលក្ខណ:សុភាពរាបសារ ទន់ភ្លន់របស់អ៊ូម៉ើរអាប់ឌុលអាហ្សីស ។ វាជាគំរូល្អឥតខ្ចោះ វាជាសក្ខីកម្ម វាជាការទន់ភ្លន់ វាជាការកោតខ្លាចចំពោះអល់ឡោះបំផុត ។

**ហ្វាទីម៉ះ** :លោកអ៊ូម៉ើរក្លាយជាមេដឹកនាំនៅពេលលោកមានអាយុ៣៥ឆ្នាំ។ ការដឹកនាំរបស់លោកមានរយៈពេលខ្លីក៏ពិតមែន តែភាពយុត្តិធម៌ ក្តីមេត្តា និងជីវប្រវត្តិរបស់លោក ស្ថិតក្នុងអារម្មណ៍ប្រជាពលរដ្ឋរបស់លោកជារៀងរហូត។

**ហ្វារ៉ហ៊ៈ** : លោកអ៊ូម៉ើរក្លាយជាអ្នកដឹកនាំបានត្រឹមតែ២ឆ្នាំ និង៥ខែប៉ុណ្ណោះ លោកទទួលមរណភាពត្រឹមអាយុ៣៩ឆ្នាំប៉ុណ្ណោះ។

**ណាដាៈ**ជានិច្ចកាលលោកអ៊ូម៉ើររស់នៅតែក្នុងគេហដ្ឋានរបស់លោក។លោកមិនដែលផ្លាស់ប្តូរទីកន្លែងទៅរស់នៅវិមានមេដឹកនាំនោះទេ។ ផ្ទុយទៅវិញលោកអ៊ូម៉ើរបានយកមាសពេជ្រ គ្រឿងអលង្កាពីភរិយារបស់លោកទៅដាក់ធ្វើជាសម្បត្តិរួមសំរាប់តម្រូវការមូស្លីមីន លោកក៏ធ្វើដូចគ្នានេះដែរជាមួយសាច់ញាតិរបស់លោក។ លោកមិនបរិភោគអ្វីក្រៅអំពីអាហារបន្លែឆាជាមួយប្រេងនោះឡើយ ហើយលោកបានបោះបង់កំណាត់សំលៀកបំពាក់ជាក្រណាត់សូត្រជារៀងរហូត។

## លោកអ៊ូម៉ើរនិងស្ត្រីក្រីក្រ

**ម៉ាស់ម៉ូដ :** ខ្ញុំមានរឿងមួយ គឺពាក់ពន្ធ័នឹងស្ត្រីក្រីក្រតោកយ៉ាកម្នាក់បានធ្វើដំណើរមកពីប្រទេសអេហ្ស៊ីប ដើម្បីសុំជំនួយឧបត្ថមពីស្បៀងអាហាររួមរបស់មូស្លីមីន។ នៅពេលគេនាំស្ត្រីរូបនោះទៅគេហដ្ឋានរបស់ថ្នាក់ដឹកនាំ។ ស្ត្រីរូបនោះក៏ចូលទៅក្នុងគេហដ្ឋាន ស្រាប់តែស្ត្រីម្នាក់នេះមានអារម្មណ៍ភ្ញាក់



ផ្អើលជាខ្លាំងនៅពេលនាងបានឃើញស្ថានភាពនៅក្នុងផ្ទះ។

**អះម៉ាត់ :** តើមានអ្វីកើតឡើង? តើស្ត្រីម្នាក់នោះបានឃើញអ្វីខ្លះដែលបានធ្វើអោយស្ត្រីម្នាក់នោះភ្ញាក់ផ្អើល?

**អាប់ឌុររ៉ស់ម៉ានៈ** វាគ្មានសំភារៈបរិក្ខារអ្វីសោះ វាគ្មានរបស់មានតំលៃអ្វីលើកកំពស់មេដឹកនាំនិងភូមិគ្រឹះរបស់លោកសោះ។ ផ្ទុយទៅវិញស្ត្រីរូបនោះប្រទះឃើញតែកន្ទេលចាស់មួយក្រាលនៅលើដីវាគ្មានអ្វីដែលអាចបង្ហាញថាមានអ្នករស់នៅក្នុងភូមិគ្រឹះនេះសោះ!។ បងប្អូនជាទីស្រលាញ់! ស្ត្រីរូបនោះបាន និយាយថាៈ រូបភាពបែបនេះតើលោកមេដឹកនាំនឹងផ្តល់ជំនួយដល់រូបខ្ញុំពីណាមក?បើផ្ទះរបស់លោករលុះរលួយហើយគាត់ក្រជាងរូបខ្ញុំទៅទៀតនោះ!

**អ៊ីស្លាមៈ** ភរិយារបស់អាប់ឌុលអាហ្ស៊ីសឈ្មោះហ្វាទីម៉ះបាននិយាយទៅកាន់ស្ត្រីនោះថាៈ សូមរង់ចាំបន្តិចសិនលោកនឹងយកប្រាក់ពីឃ្លាំងសម្បត្តិរួមរបស់មូស្លីមមកជូនអ្នក។

**ហ្វាទីម៉ះ** : រីឯរូបខ្ញុំវិញនឹងនិយាយរឿងមួយប្រាប់ពួកអ្នកអំពីលោកអ៊ូម៉ើរ។ អ្នកបំរើម្នាក់កំពុងបណ្តើរសេះស្រាប់តែបានជួបអ៊ូម៉ើរ ពេលនោះអ៊ូមើរសួរថាៈ "តើមនុស្សម្នាយ៉ាងម៉េចដែរ? " អ្នកបំរើនោះឆ្លើយថាៈ "មនុស្សម្នាទាំងអស់បានសំរាកអស់ហើយ លើកលែងតែរូបលោក រូបខ្ញុំ និងសេះមួយក្បាលនេះទេដែលមិនទាន់សំរាក។

## ភាពថ្កុំថ្កើង និងសុភាពរាបសាររបស់អូម៉ើរ

**អាប់ឌុររ៉ស់ម៉ាន :** នេះគឺជារឿងពិតមួយផ្សេងទៀតដែលបានបង្ហាញភាព

ឧត្តុង្គឧត្តម និងភាពទន់ភ្លន់របស់លោក។ មានសេចក្តីរាយការណ៍អំពីរជាក កូនហៃវ៉ះបានអោយដឹងថាៈ"មានយប់មួយខ្ញុំនៅជាមួយមេដឹកនាំ គឺអ៊ូម៉ើរ កូនអាប់ឌុលអាហ្ស៊ីស។ ចង្កៀងវាថយពន្លឺ ខ្ញុំក៏ងើបទៅចាក់ប្រេងថែម ។ ខណៈនោះ លោកមានប្រសាសន៏មកខ្ញុំថាៈមិនសមទេ ព្រោះអ្នកជាភ្ញៀវ របស់ខ្ញុំ។ បន្ទាប់មកលោកក៏ងើបចាក់ប្រេងបំពេញចង្កៀងដោយខ្លួនលោក រួចនិយាយថាៈពេលខ្ញុំក្រោកឈរក៏ខ្ញុំនៅជាអ៊ូម៉ើរហើយពេលណាខ្ញុំរួចការងារ ក៏ខ្ញុំនៅតែជាអ៊ូម៉ើរ "។

**អ៊ីស្លាម :** ពួកយើងបាននិងកំពុងតែទទួលបាននូវភាពភ្លឺស្វាងតាមរយៈជីវប្រវត្តិរបស់លោកមេដឹកនាំជំនាន់ទី ៥ គឺលោកអ៊ូម៉ើរកូនអាប់ឌុលអាហ្ស៊ីស។ រូបលោកពិតជាអ្នកមានចំណេះវិជ្ជាខ្ពស់និងពូកែយល់ទោះជាយ៉ាងនេះក្តីលោក នៅតែផ្លាស់ប្តូរមតិយោបល់ជាមួយសាសនវិទូ និងសុំការណែនាំពីសាសនវិទូ អ៊ីស្លាមទាំងនោះទៀតផង។ លោកអ៊ូម៉ើរបានសួរលោកមូហាំម៉ាត់កូនកាអាប់ ថាៈសូមពណ៌នាប្រាប់ខ្ញុំមើលដូចម្តេចហៅថាយុត្តិធម៌នោះ? លោកមូហាំម៉ាត់ បញ្ជាក់ថាៈ"សូមចាត់ទុកខ្លួនឯងជាឪពុកចំពោះមនុស្សណាដែលមានអាយុតិច ជាងខ្លួន ហើយសូមចាត់ទុកខ្លួនឯងជាកូន ចំពោះមនុស្សណាដែលមានវ័យ ចំណាស់ជាងខ្លួននិងសូមចាត់ទុកខ្លួនឯងជាបងប្អូនចំពោះមនុស្សដែលមានវ័យ ស្មើនឹងខ្លួនសូមប្រើទណ្ឌកម្មទៅតាមក៏រិត នៃកំហុសនិងខ្លួនប្រាណរបស់ពួកគេ សូមអ្នកកុំដាក់ទណ្ឌកម្មគេក្នុងពេល ដែលអ្នកមានកំហឹងព្រោះវានាំអោយរូប



អ្នកមានកំហុសហើយក្លាយទៅជារំលោភបំពានអ្នកដទៃជាក់ជាមិនខាន។

**ម៉ាស់ម៉ូដៈ** បងប្អូនទាំងអស់!ខ្ញុំមានការភ្ញាក់ផ្អើលជាខ្លាំងនឹងពាក្យសំដីដែល បញ្ជាក់ប្រាប់លោកអ៊ូម៉ើរ ហើយខ្ញុំមានបំណងចង់អោយពួកអ្នកទាំងអស់ចូល រួមជាមួយខ្ញុំក្នុងការស្វែងយល់ពីទ្រឹស្តីមួយនេះ? គឺលោកអ៊ូម៉ើរបាននិយាយ ថាៈ គ្មានអ្វីឈឺចាប់ជាងអវិជ្ជានោះទេ ហើយក៏គ្មានជំងឺណាអាក្រក់ជាងការ មានទោសនោះដែរដូចនេះសូមពួកអ្នករក្សានៀកម៉ាត់(លាភសក្ការៈ)របស់ អ្នកតាមរយៈ នៃការដឹងគុណ ហើយសូមពួកអ្នករក្សាវិជ្ជាតាមរយៈ នៃការ កត់ត្រា"។

**ម៉ាស់ម៉ូដ :**បងប្អូនទាំងអស់! ដូចខ្ញុំបានអាននូវចំណេះដឹងផ្សេងទៀតនៅក្នុង សៀវភៅមួយឈ្មោះអាល់មូជិដឪឌូន ហើយជានិច្ចកាលខ្ញុំតែងតែស្វែងរក ប្រភពរបស់វាអោយបានកាន់តែច្បាស់ថែមទៀត នោះគឺត្រង់ចំនុចដែល លោកអ៊ូម៉ើរ បានបញ្ជាអោយគេរៀបចំចងក្រងសៀវភៅស្តីអំពីមាគិារបស់ ណាហ្គី ដ៏ឧត្តុងឧត្តម ដើម្បីរក្សាទុកអោយមានសុវត្ថិភាព ដូចនោះដែរលោក បានយកចិត្តទុកដាក់យ៉ាងខ្លាំង ចំពោះការផ្សព្វផ្សាយចំណេះវិជ្ជាទូទៅវិជ្ជា ពេទ្យនិងទស្សនៈវិជ្ជាជាដើម។

## លោកអ៊ូម៉ើរនិងការចងក្រងសៀវភៅស៊ុណ្ណះណាហ្គី

**ឪពុក :** កូនសំលាញ់! ឪពុកមានការខ្មាស់អៀនចំពោះកូន ដែលកូនខិតខំ ព្យាយាមស្វែងយល់និងអានឯកសារជាច្រើននោះ។

**ម៉ាស់ម៉ូដ:** ឪពុកជាទីស្រលាញ់! លោកឪពុកបានបង្ហាត់បង្រៀនដល់ខ្ញុំថា: "ពិតប្រាកដណាស់ ការអានគឺជាបញ្ញារបស់អល់ឡោះជាម្ចាស់។ អ្នកនាំវ៉ាហ៊ី មកអោយណាហ្វីនិងជារ៉ស៊ូលចុងក្រោយបង្អស់ គឺជាអ្នកស្មោះត្រង់បំផុត (ម៉ាឡាអ៊ីកាត់ជីបរ៉អ៊ីល)"។

**ឪពុក:** អ្នកកត់ត្រាប្រវត្តិសាស្ត្រជាច្រើនបានបញ្ជាក់អោយដឹងថា ជាការពិតណាស់លោកអ៊ូម៉ើរកូនអាប់ឌុលអាហ្ស៊ីស គឺជាមេដឹកនាំយកចិត្តទុកដាក់ខ្ពស់បំផុតក្នុងការប្រមូលផ្ដុំនិងរៀបចំចងក្រងស៊ុណ្ណះណាហ្វីទុកជាឯកសារ ដោយលោកបញ្ជាអោយសាសនវិទូទាំងអស់ប្រមូលផ្ដុំ និងរៀបចំចងក្រងហាហ្ទីសរបស់ណាហ្វីរក្សាទុកជាឯកសារបន្ទាប់មកលោក បានផ្ញើបណ្ដាឯកសារទាំងអស់នោះទៅកាន់អ្នកគ្រប់គ្រងតាមតំបន់ទាំងអស់មិនតែប៉ុណ្ណោះលោកក៏បានចូលរួមចំណែកក្នុងការកត់ត្រាហាហ្ទីសណាហ្វីមួយចំនួនផងដែរ។

**ម៉ាស់ម៉ូដ:** ឱ ឪពុកជាទីស្រលាញ់! កូនបានអានដោយមានការបញ្ជាក់ថា: នៅជំនាន់របស់លោកអ៊ិបនូសាអាត់ មានការចងក្រងឯកសារហាហ្ទីសជាផ្លូវការដោយឪពុករបស់អ៊ូម៉ើរអាប់ឌុលអាហ្ស៊ីស គឺលោកអាប់ឌុលអាហ្ស៊ីសកូនម៉ារ៉វ៉ានដែលជាមេដឹកនាំនៅប្រទេសអេហ្ស៊ីបមែនទេ! ។

**ឪពុក :** ត្រឹមត្រូវហើយ! ព្រោះលោកអ៊ិបនូហាជើរក៏បានបញ្ជាក់ដូចគ្នាផងដែរនៅក្នុងសៀវភៅហ្វាត់ហុលបារីថា: ចំណែកការចាប់ផ្ដើមរៀបចំចងក្រងហាហ្ទីសរបស់ណាហ្វីដើម្បីរក្សាទុកជាឯកសារ បានចាប់ផ្ដើមតាំងពីដើមសតវត្សទី១នៃមូហាំម៉ាត់សករាជមកម្លេះ គឺនៅក្នុងសម័យដឹកនាំដោយ



លោកអ៊ូម៉ើរកូនអាប់ឌុលអាហ្ស៊ីស។

**អ៊ីណាស:** អញ្ចឹងគេត្រូវកោតសរសើរដល់លោកអ៊ូម៉ើរកូនអាប់ឌុលអាហ្ស៊ីស ដែលបានព្យាយាម និងយកចិត្តទុកដាក់ចំពោះការផ្សព្វផ្សាយមាគ៌ាមូហាំម៉ាត់ និងបានបំបាត់ច្បាប់ក្លែងក្លាយចោលទាំងទង្វើ និងទ្រឹស្ដីខុសឆ្គងទាំងឡាយ។

**ម៉ាស់ម៉ូដ :** លោកអ៊ូម៉ើរពិតជាបានធ្វើការជំរុញដល់បណ្ដាសាសនវិទូអ៊ិស្លាមអោយមានចិត្តក្លាហាន រឹងមាំ និងយកចិត្តទុកដាក់អោយអស់ពីកំលាំងកាយកំលាំងចិត្តនៅក្នុងរឿងនោះ ដោយលោកបានដាក់បញ្ជាចំពោះពួកគេយ៉ាងតឹងរ៉ឹង ហើយលោកបានរៀបចំអោយមានការឧបត្ថម្ភយ៉ាងពេញចិត្តដល់សាសនវិទូទាំងអស់ក្នុងបំណងលើកទឹកចិត្តដល់ពួកគេអោយមានការយកចិត្តទុកដាក់កត់ត្រានិងរៀបចំហាហ្ទីសណាហ្វីអោយបានត្រឹមត្រូវ។

## មោទនៈភាពរបស់អ៊ូម៉ើរចំពោះគូរអាននិងស៊ុណ្ណះណាហ្វី

**ឪពុក:** លោកអ៊ូម៉ើរកូនអាប់ឌុលអាហ្ស៊ីសបានសរសេរថា: បុគ្គលណាក៏ដោយមិនត្រូវយកទស្សនៈរបស់ខ្លួនមកពិចារណាលើគម្ពីរអាល់គួរអាន ឬលើមាគ៌ារបស់រ៉ស៊ូលុលឡោះឡើយ។ ការយល់ឃើញរបស់សាសនវិទូ គឺសំដៅលើតែចំណុចណាដែលគ្មានបញ្ជាក់នៅក្នុងគម្ពីរគួរអាននិងគ្មាននៅក្នុងមាគ៌ារ៉ស៊ូលុលឡោះតែប៉ុណ្ណោះ ។

**កូន១:** សូមអល់ឡោះសណ្ដោសប្រណីដល់លោកអ៊ូម៉ើរផងចុះ។ ពិតជាសក្ដិសមណាស់ដែលគេប្រសិទ្ធិនាមមេដឹកនាំទី៥នេះថាជាកំផែងមួយដ៏រឹងមាំនោះ។

## ការយំសោកដោយការខ្លាចអល់ឡោះ

**ឪពុកៈ**ឱកូនជាទីស្រលាញ់ទាំងអស់ ! ការសំរក់ទឹកភ្នែកដោយសារការកោតខ្លាចចំពោះអល់ឡោះជាពន្លឺមួយ ជាការជឿជាក់មួយ ជាសេចក្តីរឹងប៉ឹងមួយ ជាគោលជំនឿមួយ និងជាឋានៈខ្ពង់ខ្ពស់មួយផងដែរពោលគឺពេលណាហើយដែលខ្ញុំរបស់អល់ឡោះណាម្នាក់គេទទួលស្គាល់អ្នកបង្កើតមេឃទាំង៧ជាន់និងបង្កើតផែនដីទាំង ៧ ជាន់ ហើយនោះគឺរូបគេនឹងបង្កើនការសោកសង្រេងពីអនាគតរបស់គេ ហើយគេនឹងកាត់បន្ថយនូវអំពើបាបកម្មទាំងឡាយរបស់គេ ចិត្តគំនិត និងខ្លួនប្រាណរបស់គេកាន់តែមានភាពនឹងន៌និងទន់ភ្លន់ថែមទៀត ។

**ហ្វាទីម៉ះ** លោកអ៊ូម៉ើរយំច្រើនដោយបុព្វហេតុខ្លាចអល់ឡោះជាម្ចាស់ ។

**អ៊ីស្លាមៈ** នៅថ្ងៃមួយ លោកអ៊ូម៉ើរ បានសូត្រអាល់គូរអាន ត្រង់ជំពូកយូណូសវាក្យខណ្ឌ៦១ថាៈ អ្នកមិនអាចធ្វើគ្រប់កិច្ចការទាំងអស់ ឬសូត្រនូវវាក្យខ័ណ្ឌណាមួយអំពីគម្ពីរអាល់គូរអាន ហើយក៏គ្មាននរណាម្នាក់អាចធ្វើកិច្ចការល្អ ឬអាក្រក់បានក្រៅពីយើងធ្វើជាសាក្សីចំពោះពួកអ្នកនៅពេលដែលពួកអ្នកកំពុងធ្វើវានោះ ។ គ្មានអ្វីកំបាំង អំពីម្ចាស់របស់អ្នក បើទោះបីជាវត្ថុតូចនៅក្នុងដីនិងនៅលើមេឃាទោះជាតូចជាងនេះ ឬធំជាងនេះ ក៏ដោយក៏មានកំណត់ត្រានៅក្នុងចំណារដ៏ច្បាស់លាស់ដែរ ” ។ លោកបានទ្រហោរយំយ៉ាងខ្លាំង រហូតឮដល់អ្នកនៅក្នុងផ្ទះទាំងអស់ ហើយភរិយារបស់លោកឈ្មោះ**ហ្វាទីម៉ះ**ក៏បានលឺសំលេងយំរបស់ប្តី អ្នកស្រីក៏យំ និងអ្នកដទៃទៀតក៏នាំគ្នាទ្រហោរយំទាំងអស់គ្នា ។ លោកធ្លាប់សូត្រនៅក្នុងសឡាហ៍មួយនូវវាក្យខ័ណ្ឌ ២៤ នៃជំពូក



អាស្សហ្វហ្វាតៈ ”ហើយសូមបញ្ឈប់ពួកគេ( មុនពេលចូលឋាននរក) ពិតណាស់ពួកគេត្រូវគេសួរ( អំពីកិច្ចការលោកកិយ) ” លោកសូត្រវាក្យខណ្ឌនេះសារចុះឡើងៗហើយលោកបានទ្រហោរយំជាខ្លាំង ។

**ឪពុកៈ** ការហូរទឹកភ្នែកដោយការកោតខ្លាចអល់ឡោះ គឺជាផលបុណ្យមួយមកពីអល់ឡោះជាម្ចាស់ដែលបានផ្តល់អោយបុគ្គលណាដែលទ្រង់អាណិតស្រលាញ់ ។ អល់ឡោះបានលុបបំបាត់ភាពរឹងរូសរបស់បុគ្គលស្អាតស្អំ ដោយអោយពួកគេចេះបង្ហូរទឹកភ្នែកក្នុងន័យកោតខ្លាចចំពោះអល់ឡោះជាម្ចាស់ ។ មូលហេតុមួយដែលអាចនាំខ្លួនគេ អោយរួចផុតពីភ្លើងនរក គឺការសូត្រធម៌សរសើរចំពោះអល់ឡោះម្ចាស់ដោយភាពជ្រះថ្លា ។

**អ៊ីស្លាម** :អ្នកបំរើលោកអ៊ូម៉ើរបានរាយរ៉ាប់ប្រាប់ថាៈមានយប់មួយខ្ញុំបានដេកនៅផ្ទះអ៊ូម៉ើរ ។យប់នោះលោកយំយ៉ាងខ្លាំងរហូតរំខានខ្ញុំពីការដេក ។លុះព្រឹកឡើងលោកបានហៅខ្ញុំទៅជួបនិងសំណូមពរដល់ខ្ញុំថាៈមិនត្រូវអោយមានអ្នកណាម្នាក់ចូលមកជួបលោក ព្រោះលោកអស់កំលាំងនឿយហត់ដោយសារលោកយំច្រើននៅយប់មិញ ។ខណៈពេលនោះខ្ញុំក៏សួរលោកថាៈ ”យប់មិញខ្ញុំបានឃើញលោកយំយ៉ាងខ្លាំង ។ខ្ញុំមិនដែលឃើញលោកយំខ្លាំង ដូចយប់មិញទេ ។ ខណៈនោះ លោកបានមានប្រសាសន៏ទាំងយំថាៈ ”ខ្ញុំបាននឹកឃើញថ្ងៃដែលគេប្រមូលផ្តុំមនុស្សទាំងអស់អោយជួបជុំគ្នានៅចំពោះមុខរបស់អល់ឡោះជាម្ចាស់ ( លោកនិយាយដល់ចំនុចនេះ) លោកក៏សន្លប់បាត់ស្មារតីទៅ ។ ចាប់តាំងពីថ្ងៃនោះមកខ្ញុំមិនដែលឃើញលោកញញឹមសោះរហូតដល់លោកទទួលមរណៈភាព ។

## ការកោតខ្លាចចំពោះអល់ឡោះ

**ហ៊ូសាម :** បងស្រី! គេបាននិយាយថា គេមិនបានបង្កើតនរកមកសំរាប់អ៊ូម៉ឺរឡើយ។

**ឪពុក :** ការបង្ហូរទឹកភ្នែកដោយការកោតខ្លាចអល់ឡោះ គឺជាពន្លឺដ៏ត្រចះត្រចង់ សំរាប់ជនមានជំនឿចំពោះអល់ឡោះ នាជីវិតលោកីយ និងនៅថ្ងៃបរលោក។ វាជាភស្តុតាង និងសក្ខីភាពបញ្ជាក់ពីជំនឿ និងការកោតខ្លាចចំពោះទ្រង់។

**អ៊ីស្លាម :** លោកអ៊ូម៉ឺរ ពិតជាបានបង្ហូរទឹកភ្នែកគ្រប់ពេលវេលាដោយការកោតខ្លាចអល់ឡោះជាម្ចាស់ មានថ្ងៃមួយលោកបានសឡាហ៍ធ្វើជាអ៊ីមុាំគេ លោកបានសូត្រស៊ូរ៉ោះតឺកវៀរ ពេលនោះលោកបានបន្លឺសំលេងយំ ហើយអ្នកនៅក្នុងម៉ាស្ជិតក៏នាំគ្នាយំទាំងអស់គ្នាផងដែរ។

**ឪពុក :** កូនសំលាញ់ទាំងអស់គ្នា! ការបង្ហូរទឹកភ្នែកយំត្រូវតែជាចំណងផ្សាភ្ជាប់ចំពោះការកោតខ្លាចអល់ឡោះដូចទ្រង់មានបន្ទូលនៅក្នុងជំពូកអាររ៉ស ម៉ាន វាក្យខ័ណ្ឌ ៤៦ ដែលមានន័យថាៈ"ហើយសំរាប់ជនកោតខ្លាចនៅពេលប្រឈមចំពោះមុខអល់ឡោះ(នៅថ្ងៃកាត់ក្តី) គឺគេត្រូវបានទទួលឋានសួគ៌ចំនួន២ "។

◆ត្រូវដឹងថា :ការកោតខ្លាច(អល់ឡោះ)នៅពេលណាផ្សាភ្ជាប់ជាមួយនឹងក្តីសង្ឃឹមទៀតនោះគឺត្រូវបានភ័ព្វសំណាងទ្វេរដង។ជាក់ស្តែងក្នុងករណីនេះ



កើតមានលើលោកអ៊ូម៉ឺរដោយពិតប្រាកដគឺការកោតខ្លាចនិងក្តីសង្ឃឹមពេលគឺការបង្ហូរទឹកភ្នែកប្រកបដោយការកោតខ្លាច ចំពោះអល់ឡោះជាម្ចាស់ ។ អល់ឡោះមានបន្ទូលនៅក្នុងជំពូកអាល់អាន់ប៊ីយ៉ាក៏វាក្យខ័ណ្ឌ ៩០ មានន័យថាៈ(ហើយពួកគេបានបួងសួងចំពោះយើងដោយពេញចិត្ត និងចង់បានហើយពួកគេមានការកោតខ្លាចចំពោះយើង)។

**អ៊ីស្លាមៈ**គេបានពណ៌នាពីអ៊ូម៉ឺរថាៈ នៅពេលដែលលោកថ្លែងសន្ទរកថានៅថ្ងៃសុក្រ លោកតែងបារម្ភណ៍លើខ្លួនឯង ពីភាពអស្ចារ្យនៃវេាហាសព្ទ និងចំណេះដឹងដែលគាត់មាន។ ពេលដែលគាត់ខ្លាចទប់អារម្មណ៍មិនបាន លោកត្រូវផ្អាកការអធិប្បាយបន្តិចមុននឹងបន្តទៅមុខទៀត ដូចគ្នាដែរ ពេលលោកសរសេរ អ្វីមួយលោកហែកវាចោលសិន ហើយលោកបានបួងសួងសុំពីអល់ឡោះថាៈ" ឱអល់ឡោះជាម្ចាស់! ខ្ញុំសុំចំពោះទ្រង់មេត្តាបញ្ចៀសរូបខ្ញុំពីអំពើអាក្រក់ដែលកើតពីខ្លួនខ្ញុំផង" ។

## យុត្តិធម៌និងសមធម៌

**ហ្វាទីម៉ះ :** ជាលក្ខណៈដ៏ប្រពៃផងដែរ ចំពោះអ្វីដែលខ្ញុំបានអានប្រវត្តិរបស់លោកបានបង្ហាញថាៈ "ពិតណាស់គ្រប់អ្នកពិការភ្នែកលោកបានរៀបចំអោយមានម្នាក់ជាអ្នកនាំផ្លូវនិងជាអ្នកថែរក្សាជនពិការនោះ និងរាល់អ្នកជំងឺម្នាក់ឬពីរនាក់ត្រូវមានអ្នកតាមបំរើម្នាក់ ហើយលោកបានសងបំណុលទាំងអស់របស់អ្នកជំពាក់បំណុលគេ លោកបានចិញ្ចឹមកុមារកំព្រា លោកបានរៀប

ចំអោយមានប្រាក់ខែដល់សាសនវិទូអ៊ីស្លាម ដើម្បីអោយពួកគាត់មានពេលគ្រប់គ្រាន់សំរាប់កិច្ចការសាសនារបស់ពួកគេ ។

**អាប់ឌុររ៉ស់ម៉ាន:** ការបំពេញភារកិច្ចដ៏ស្មោះត្រង់របស់អ៊ូម៉ើរចំពោះអល់ឡោះជាម្ចាស់ធំធេងណាស់!រហូតដល់អ្នកមានបានបរិច្ចាគទានហ្ស៊ាកាត់តែគ្មានអ្នកក្រីក្រទទួលយកឡើយ (ដោយសារវាគ្មានអ្នកខ្វះខាតសោះ) នៅជំនាន់របស់លោក ។

**ហ៊ូសាម** :មានភស្តុតាងបង្ហាញពីភាពយុត្តិធម៌និងស្មើភាពរបស់អ៊ូម៉ើរផងដែរ គឺនៅពេលដែលអធិរាជនៃប្រទេសរ៉ូម បានទទួលដំណឹងពីមរណៈភាពរបស់អ៊ូម៉ើរទ្រង់ហូរទឹកភ្នែករួចមានបន្ទូលទៅកាន់អ្នកនៅក្រោមឱវាទថា: ខ្ញុំសូមស្បថនឹងអល់ឡោះថា:អ្នកគ្រប់គ្រងដែលយុត្តិធម៌បានទទួលមរណៈភាពហើយប្រហែលជាគ្មានបុគ្គលណាយុត្តិធម៌ដូចលោកឡើយ ។ អធិរាជអង្គនេះធ្លាប់បានបញ្ជូនពេទ្យពិសេសដើម្បីព្យាបាលជំងឺជូនអ៊ូមើរផងដែរ ។

**អាប់ឌុររ៉ស់ម៉ាន :** មេដឹកនាំអ៊ូម៉ើរកូនអាប់ឌុលអាហ្សីស នៅក្នុងវ័យយុវ វ័យខណៈពេលដែលលោកត្រូវបានគេតែងតាំងជាមេដឹកនាំ លោកបានសរសេរមួយច្បាប់ផ្ញើទៅកាន់អ្នកគ្រប់គ្រងនៃប្រទេស អេហ្ស៊ីបដោយសំណូមពរអោយថ្នាក់ដឹកនាំមានក្ដីករុណាដល់សត្វពាហនៈផង ព្រោះលោកបានទទួលដំណឹងថា: អ្នកដឹកទំនិញបានដាក់ទំនិញរបស់ខ្លួនអោយសត្វពាហនៈដឹកធ្ងន់លើសពីកំលាំងរបស់វា ។



## មរណៈភាពរបស់អ៊ូម៉ើរអាប់ឌុលអាហ្ស៊ីស

**ម៉ាស់ម៉ូត :** នៅព្រឹកនោះឆ្កែចចកបានស៊ីពពែមួយក្បាល!

**អាប់ឌុររ៉ស់ម៉ាន:** លោកអ៊ូម៉ើរកូនអាប់ឌុលអាហ្ស៊ីសបានទទួលមរណៈភាពខណៈពេលបញ្ចប់សាច់រឿងសត្វពពែនិងឆ្កែចចក ។

**ហ្វាទីម៉ះ :** ឱបងប្អូន! តើគេចង់និយាយពីរឿងខរ៉ហ្វឺឬ? ខ្ញុំគិតថាវាជាប្រវត្តិពិត?

**អះម៉ាត់** :ទេ! តាមពិតវាជាប្រវត្តិយ៉ាងពិតប្រាកដ តែភាពយុត្តិធម៌ និងការលះបង់ររបស់អ៊ូម៉ើរគ្មានអ្នកប្រដូចនឹងលោកឡើយ ។

**មូហាំម៉ាត់ :** ពួកយើងត្រូវបញ្ចប់ប្រវត្តិរបស់មេដឹកនាំអ៊ីស្លាមត្រឹមនេះ ហើយត្រូវបួងសួងសុំឌូអាអោយលោកអ្នកដឹកនាំ:( ឱម្ចាស់របស់ខ្ញុំ! សូមទ្រង់ផ្ដល់សុវត្ថភាពនៃសាសនារបស់ពួកយើងដល់ពួកយើងផង និងសូមផ្ដល់ដល់ពួកយើងនូវសេចក្ដីសុខក្នុងកិច្ចការប្រតិបត្តិចំពោះទ្រង់ ហើយសូមទ្រង់ទទួលយល់ព្រមដល់ពួកយើងផង ។

**ពួកកូន៧ទាំងអស់:** សូមម្ចាស់ជាអ្នកគ្រប់គ្រងពិភពទាំងមូលទទួលយកនូវសំណូមពរទាំងនេះផងចុះ ។

រៀបចំដោយគណៈកម្មការបកប្រែ និងបោះពុម្ពសៀវភៅ

នៃសមាគមសំរបសំរួលសង្គមនៃប្រទេសគុយវ៉ែត

សហការជាមួយសមាគមសប្បុរសធម៌ដើម្បីអភិវឌ្ឍន៍កម្ពុជា

**ដកស្រង់ចេញពីសៀវភៅ**


١- القرآن الكريم

អាល់គួរអានុលកើរីម

٢- سيرة ابن هشام ( السيرة النبوية) لابن هشام.

ស៊ីរ៉ស់អ៊ិបនូ ហ៊ីស្ហាម (ស៊ីរ៉ស់ ណាពើវីយ៉ះ) លីអ៊ិបនូ ហ៊ីស្ហាម

٣- فتح الباري ....ابن حجر العسقلاني

ហ្វាត់ហ៊ុលពើរី(អ៊ិបនូហាជើរអាសកឡើនី)

٣-تاريخ الخلفاء وأمراء المؤمنين القائمين بأمر الدولة ..جفال الدين السيوطي

តើរៀហ អាល់ឃូឡើហ្វើក៏ វ៉ាអ៊ូម៉ារ៉ក អាល់មុមីនីន

អាល់កអ៊ីមីនពីអាំរិតឌៅឡះ...ជើឡើ លុដ្ឌីន អាសស៊ូយូទី

٥-خلفاء الرسول ..خالد محمد خالد

ឃូឡើហ្វើក៏ អើររ៉ស៊ូល ...........ខលីត មូហាំម៉ាត់ ខលីត